ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jul-2013, 12:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២០៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យ៉ូវ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោក ហ្វីលីព រ៉ូជឺ *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ឃីត រេយ៍ន័រ*(Mr. Keith RAYNOR)*

លោក វ៉េង ហ៊ាត់

លោក វីល្លៀម ស្មីត*(Mr. William Smith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផនៈ**

លោក  គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

លោក វ៉េន ពៅ

លោក ឡៅ ជុនធី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការៈ**

លោក អ៊ុំ អរុណ

លោកស្រី ស្លួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោកស្រី ឯក ហេន (TCW-164) | ខ្មែរ |
| លោក ស៊ុម អាឡាត់ (TCW-689) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ឯក ហេន** (TCW-164)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ១០
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ....................ទំព័រ ១៤
សួរដោយលោក ឃីត រេយ៍ន័រ ផ្ដើមពី....................ទំព័រ ៣៣
សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្ដើមពី ....................ទំព័រ ៤៦
សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្ដើមពី....................ទំព័រ ៥៣
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៥៧
សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី ....................ទំព័រ ៦៥

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ុំ អានឡាត់** (TCW-689)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៨៤
សួរដោយលោក វីល្លៀម ស្មីត ផ្ដើមពី....................ទំព័រ ៨៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:២៥]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានកំណត់ទុកសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-164។

ក្រឡាបញ្ជីសវនាការលោក ដាវ អាសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាប រាយការណ៍ជូនលោកប្រធាន។ នៅក្នុងសវនាការថ្ងៃនេះ គ្រប់ភាគីមានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលាសវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងដោយសារមូលហេតុសុខភាព។

សូមកត់សម្គាល់ផងដែរ មេធាវី -- សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។

ដូចលោកប្រធានបជម្រាបជូនសវនាការអម្បាញ់មិញ គឺថ្ងៃនេះតាមកាលវិភាគនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-164។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយកាលពីថ្ងៃម្សិលមិញ និងបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានចំណងញាតិលោកហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នោះឡើយ។ ហើយគាត់មានវត្តមានរួចជាស្រេចរង់ចាំការកោះហៅចូលក្នុងបន្ទប់សវនាការ។

នាថ្ងៃនេះផងដែរ មានសាក្សីបម្រុងដែលមានរហស្សនាម TCW-689 ដែលសាក្សីបម្រុងរូបនេះបានធ្វើសម្បថរួចហើយផងដែរ និងបានបញ្ជាក់ថា មិនមានជាប់ចំណងញាតិលោកហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីណាមួយឡើយ។សូមអរគុណលោកប្រធាន។

[០៩:០៦:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរលោក លោកស្រីទាំងអស់។

ខ្ញុំមានចំណុចពីរសូមលើកជូនអង្គជំនុំជម្រះនៅព្រឹកនេះ មុនចាប់ផ្ដើមសវនាការ។ ចំណុចមួយគឺទាក់ទងទៅនឹងសាក្សីរូបនេះ និងចំណុចមួយទៀត គឺអំពីសាក្សីសម្រាប់ថ្ងៃស្អែក។

ចំពោះសាក្សីនៅថ្ងៃនេះ កាលពីរសៀលម្សិលមិញ យើងបានទទួលអ៊ីម៉ែលមួយពីខាងសហព្រះរាជអាជ្ញា ដែលក្នុងអ៊ីម៉ែលនោះសរសេរថា "ឯកសារខ្លះនឹងត្រូវយកមកបង្ហាញនៅចំពោះមុខសាក្សីរូបនេះ ហើយឯកសារខ្លះ គឺជាឯកសារថតចម្លង"។ ខ្ញុំមិនជាបញ្ហាអីជាមួយនឹងរូបថតដែលត្រូវយកមក -- ហើយនិងរូបថតខ្លះខ្ញុំមិនបញ្ហាអ្វីទេ ជាមួយនឹងការបង្ហាញរូបថត គឺឯកសារ E3/1662 -- 6.2 ដែលមាន៧០ទំព័រ ដែលមិនទាន់ -- ៣៧០ទំព័រ ដែលមិនទាន់ដាក់នៅលើអ៊ីនធឺហ្វេសនៅឡើយទេ តាំងពីម៉ោងដប់ពីរម្សិលមិញមកម្ល៉េះ។

[០៩:០៨:២១]

យើងខ្ញុំមានភាពបត់បែនបានទេពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារ។ ចំពោះមុខសាក្សីរូបនេះ យើងខ្ញុំមិនមានបញ្ហាក្នុងរឿងនេះទេ។ ហើយតាមដែលខ្ញុំយល់នោះគឺថាការយើងត្រូវតែមានឯកសារដាក់នៅលើអ៊ីនធឺហ្វេស នៅម៉ោងដប់ពីរពីម្សិលមិញ ដែលជាកាលបរិច្ឆេទផុតកំណត់។

ឯកសារ E3/166.2 យើងខ្ញុំយល់ឃើញថា អង្គជំនុំជម្រះក៏មានភាពបត់បែន អនុញ្ញាតឲ្យយើងខ្ញុំបង្ហាញដែរ។ យើងខ្ញុំមានភាពយឺតយ៉ាវ សូមជម្រាបជូន។ ប៉ុន្តែប្រសិនណាបើអង្គជំនុំជម្រះយល់ឃើញថាវិធានពាក់ព័ន្ធនឹងបញ្ហានេះ គឺជាវិធានដាច់ខាត ឬក៏តឹងរ៉ឹង គឺថាអាស្រ័យទៅលើអង្គជំនុំជម្រះ ក៏ប៉ុន្តែខ្ញុំសូមលើកឡើងតែពីរចំណុចនេះមុនចាប់ផ្ដើមសាក្សីរូបនេះ។ ចំណុចទី២ ទាក់ទង់ទៅនឹងសាក្សីថ្ងៃស្អែក អង្គជំនុំជម្រះបានជ្រាបហើយ យើងខ្ញុំបានស្នើសុំយ៉ាងជាក់លាក់ដែលសុំឲ្យសាក្សីរូបនេះ ចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែសាក្សីរូបនេះ គឺថាមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា។

ហើយដូចដែលអង្គជំនុំជម្រះជ្រាបហើយ គឺជាសាក្សីដែលស្នើសុំនៅក្នុងបញ្ជីអ្នកជំនាញនិងសាក្សី។ យើងខ្ញុំមានការបញ្ជាក់ពីអង្គជំនុំជម្រះថា គឺសហព្រះរាជអាជ្ញាចាប់ផ្ដើមតាំងសំណួរមុនគឺ TCW-689 ហើយខាងមេធាវីការពារក្ដីនឹងចាប់ផ្ដើមតាំងសំណួរតាមក្រោយ។ ដូច្នេះយើងខ្ញុំចង់ដឹងឲ្យបានមុន តាមដែលអាចធ្វើទៅបាន។ សូមអរគុណលោកប្រធាន។

[០៩:១០:១៤]

**កញ្ញា សុង ឆរ័ន្ត៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ពាក់ព័ន្ធទៅនឹងចំណុចឯកសារនេះផងដែរ ខ្ញុំសូមអនុញ្ញាតឆ្លើយតបជាមួយនឹងមេធាវីការពារក្ដីលោក នួន ជា ថាជាក់ស្ដែងនៅក្នុងអំឡុងពេលដែលតំណាងសហព្រះរាជអាជ្ញារៀបចំសំណួរដើម្បីសាកសួរលើសាក្សីរូបនេះ សហព្រះរាជអាជ្ញាបានប្រទះឃើញនូវព័ត៌មានដែលសំខាន់មួយចំនួនពាក់ព័ន្ធទៅនឹងរូបថត ដែលមានទំនាក់ទំនងសាច់ញាតិជាមួយនឹងសាក្សីរូបនេះ ហើយនិងរូបថតផ្សេងទៀតដែលជាអ្នកដែលសាក្សីរូបនេះធ្លាប់ស្គាល់ ធ្លាប់ធ្វើការជាមួយ។

តំណាងសហព្រះរាជអាជ្ញានៅក្នុងអំឡុងពេលនៃការរៀបចំសំណួរដើម្បីសាកសួរសាក្សីរូបនេះបានប្រទេះឃើញថា ខ្លួនអាចស្រាវជ្រាវរករូបថតទាំងអស់នេះបានតាមបណ្ណាល័យសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនៅក្នុងអំឡុងពេលនៃការស្រាវជ្រាវនោះ សហព្រះរាជអាជ្ញាបានធ្វើការទំនាក់ទំនងជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយទើបតែទទួលបាននូវរូបថតនេះពីមជ្ឈ-មណ្ឌលឯកសារកម្ពុជាកាលពីល្ងាចម្សិលមិញម៉ោងប្រហែលប្រាំសាមសិបនាទី។

ហើយដោយសារតែតំណាងសហព្រះរាជអាជ្ញាយល់ឃើញថា ឯកសារដែលជារូបថត ដែលនឹងដាក់ស្នើសុំបង្ហាញទៅដល់សាក្សីរូបនេះមានសារៈសំខាន់ដើម្បីជួយដល់អង្គជំនុំជម្រះស្វែងរកការពិតនិងយុត្តិធម៌នៃរឿងក្ដីនេះ និងសាក្សីរូបនេះក៏ត្រូវបានបង្ហាញនូវរូបថតមួយរបស់សាច់ញាតិរបស់គាត់នៅក្នុងអំឡុងពេលនៃការសម្ភាសជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជារួចម្ដងទៅហើយ។

[០៩:១១:៥៨]

ហើយជាក់ស្ដែងរូបថតដែលជាសាច់ញាតិរបស់សាក្សីរូបនេះនៅមិនទាន់មានលេខ D ឬក៏លេខ E នៅឡើយទេ។ ប៉ុន្តែយើងខ្ញុំនឹងមិនសួរព័ត៌មានលម្អិតក្រៅពីបង្ហាញរូបថតនេះដល់សាក្សីដើម្បីសួរបញ្ជាក់ថា តើសាក្សីរូបនេះធ្លាប់ស្គាល់ ឬក៏មានទំនាក់ទំនងជាមួយនឹងអ្នកដែលមានរូបនៅក្នុងរូបថតឬ

អត់នោះទេ។ ប៉ុន្តែជាក់ស្តែងនៅក្នុងរូបថតមួយទៀត យើងខ្ញុំទើបតែរកឃើញកាលពីព្រឹកមិញនេះមុនពេលសសវនាការ ហើយយើងខ្ញុំក៏ស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកភស្តុតាងមួយនេះដែរ គឺរូបថតដែលមានលេខ D108/32.3 ដល់ P1184។

ជាក់ស្តែងទាក់ទងទៅនឹងឯកសារដែលលោកមេធាវី នួន ជា បានលើកឡើង គឺជាឯកសារ E3/1662។ ឯកសារនេះមានជាង៣០០ទំព័រក៏ពិតមែន ប៉ុន្តែយើងខ្ញុំនឹងដកស្រង់តែខ្លឹមសារដែលមាននៅលើឯកសារនេះត្រង់លេខ ERN 00171490 ដើម្បីសួរបញ្ជាក់ទៅនឹងឈ្មោះរបស់បុគ្គលដែលសាក្សីរូបនេះធ្លាប់ស្គាល់តែប៉ុណ្ណោះ។ ហើយជាក់ស្តែងនៅក្នុងអំឡុងពេលរៀបចំនេះ សាក្សីដែលត្រូវនឹង ត្រូវបានកោះហៅមកចូលរួមបំភ្លឺនៅក្នុងសវនាការថ្ងៃនេះ គឺយើងខ្ញុំបានទទួលដំណឹងបញ្ជាក់ថាគាត់នឹងត្រូវបានកោះហៅនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។ ហេតុដូច្នេះអំឡុងពេលនៃការរៀបចំ គឺមានរយៈពេលខ្លីដែលយើងខ្ញុំមិនអាច*អាប់ឡូត* ឯកសារទាំងអស់នេះនៅក្នុងអ៊ីនធីហ្វេស បាន។

ហេតុដូច្នេះយើងខ្ញុំស្នើសុំដាក់ឯកសារនេះតាមវិធាន៨៧(៤) ដើម្បីឲ្យអង្គជំនុំជម្រះទទួលយកភស្តុតាងនេះ។ សូមអរគុណ។

[០៩:១៤:១០]

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសហភាតារបស់ខ្ញុំកំពុងតែបំភ្លៃព័ត៌មានដល់តុលាការហើយ។ សហព្រះរាជអាជ្ញាដែលមិនអាចដឹងអំពីអាទិភាពនៃរូបថតនេះជាមុននោះ នេះមិនត្រឹមត្រូវទេក្នុងការនិយាយថារូបថតទាំងអស់នេះត្រូវបានបង្ហាញទៅសាក្សីនៅថ្ងៃ០៦ មករា ឆ្នាំ២០១៣ -- អ៎! ២០០៣ ពីព្រោះថានៅពេលនោះសាក្សីនិយាយថា គាត់ធ្លាប់បានឃើញរូបថត មានរូបថតនោះមកហើយ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានបង្ហាញរូបថតនុ៎ងទៅគាត់ទេ តាមពិតបង្ហាញពីប្រវត្តិរូបបងប្រុសរបស់គាត់ទៅគាត់ទេ។ អ៊ីចឹងមិនត្រឹមត្រូវទេ។

ចំណុចទី២ ចាប់ពីថ្ងៃទី០៦ មករា ២០០៣នេះមក គាត់និយាយថា នៅពេលណាមួយ គាត់ទទួលបានរូបថត ក៏ប៉ុន្តែនៅពេលដែលជួប ស៊ី.ឌី.ខេម នោះ គាត់មិនទទួលបានរូបថតនៅពេលនោះទេ។ ហើយរូបថតនោះ ស្ថិតនៅក្នុងសំណុំរឿង ឌុច ទេ។ អ៊ីចឹងបានន័យថា រូបថតនេះ គាត់ --ព្រះរាជអាជ្ញាអាចទទួលរូបថតនេះបាន ហើយដោយមិនចាំបាច់ទៅជួបមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីទទួលបានឯកសារនេះទេ ព្រោះវាមាននៅក្នុងសំណុំរឿង០០១ របស់ ឌុច ហើយៗ។

[០៩:១៥:៤១]

អ៊ីចឹងខ្ញុំសូមគាំទ្រការកត់សម្គាល់របស់លោក កូប៉េ ថាខាងព្រះរាជអាជ្ញាធ្វើមិនទាន់ពេលវេលា កាលពីម្សិលមិញនេះ ថ្ងៃត្រង់ក្នុងការដាក់ឯកសារនៅក្នុងអ៊ីនធីហ្វេស ហើយបើជូនដំណឹងដល់យើងអំពីឯកសារនេះបីបួនម៉ោងក្រោយ ហើយដែលត្រូវជូនដំណឹងយើងពីមុនមកនោះមិនព្រមធ្វើ។ ហើយឥឡូវនេះ ឥឡូវមកនិយាយអំពីវិធាន៨៧(៧)នេះ -- (៤) នេះ មិនសមស្របទេ ហើយខាងការពារក្ដីសូមឲ្យបង្ហាញជាលាយលក្ខណ៍អក្សរ។ អ៊ីចឹងខ្ញុំសូមជំទាស់ទៅនឹងការប្រើប្រាស់រូបថតនេះ ដោយសារមិនបានជូនដំណឹងយើងជាមុន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបន្ថែមចំណុចបញ្ជាក់តូចមួយ ចម្លើយរបស់សហព្រះរាជអាជ្ញាហាក់បញ្ជាក់ឲ្យឃើញថា យើងកំពុងនិយាយអំពីរូបថតទាក់ទងទៅនឹងស-២១។ ខ្ញុំមិនដឹងថាតើរូបថតទាំងនេះ និងឯកសារពាក់ព័ន្ធស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះ ឬក៏អត់ទេ។ យើងហាក់បីដូចជាថា វិសាលភាពនៃសវនាការនេះ គឺថាវាមានបញ្ហាទៅនឹងបញ្ហាដែលខ្ញុំ និងសហការីរបស់ខ្ញុំនេះបានលើកឡើងរួចទៅហើយ។

[០៩:១៧:២១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកតំណាង -- លោកស្រីតំណាងសហព្រះរាជអាជ្ញា!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយខ្លីទេ ពាក់ព័ន្ធទៅនឹងរូបថតដែលបានប្រគល់ឲ្យសាក្សីនៅអំឡុងពេលដែលគាត់សម្ភាស ឬក៏ក្រោយមកទៀតនោះ គឺដាក់ស្ដែងរូបថតនោះ គឺមានភ្ជាប់ជាមួយនឹងប្រវត្តិរូប។ ហេតុដូច្នេះ ខ្ញុំនឹងមិនអាននូវប្រវត្តិរូបទាំងមូលនោះទេ ខ្ញុំនឹងបង្ហាញតែសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញតែរូបថត ដើម្បីសួរបញ្ជាក់ទៅលើសាក្សីប៉ុណ្ណោះ ថាតើរូបថតនេះ ជាអ្នកដែលគាត់មានទំនាក់ទំនងជាមួយ ឬយ៉ាងណាតែប៉ុណ្ណោះ? ហើយដាក់ស្ដែង សាក្សីនេះត្រូវបានជូនដំណឹងដោយអង្គជំនុំជម្រះថានឹងត្រូវកោះហៅមកផ្ដល់សក្ខីកម្ម គឺនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

ហើយយើងខ្ញុំពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីស្វែងរកនូវភស្តុតាងទាំងអស់នេះ រហូតដល់ ទើបតែទទួលបានអ៊ីម៉ែលពី ឌី.ស៊ី.ខេម ដើម្បីបញ្ជាក់ថា រូបថតមាននៅក្នុងបណ្ណាល័យសាធារណៈរបស់

ឌី.ស៊ី.ខេម ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងព័ត៌មានដែលសាក្សីនេះបានផ្តល់នៅក្នុងសក្ខីកម្មដែលគាត់ផ្តល់ជាមួយនឹងអ្នកសម្ភាសនៅ ឌី.ស៊ី.ខេម។ ហើយជាក់ស្តែងរូបថតអស់ទាំងនេះ គឺធ្លាប់ -- រូបថតគឺធ្លាប់បានស្នើសុំដោយអង្គជំនុំជម្រះកាលពី ការធ្វើ ការសាកសួរលើសាក្សីឈ្មោះ គឹម វុន រួចម្តងមកហើយ ហើយអង្គជំនុំជម្រះក៏ធ្លាប់បានសម្រេចនៅលើភស្តុតាងជារូបថតនេះដែរ។ ហេតុដូច្នេះ យើងខ្ញុំនៅតែរក្សាជំហរដើម្បីស្នើសុំអង្គជំនុំជម្រះទទួលយកភស្តុតាងនេះ។ សូមអរគុណ។

[០៩:១៨:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៣:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះមានសំណួរពីរបី សួរទៅសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី។ គឺថាហាក់បីដូចថាវាមានឯកសារពីរប្រភេទ។ ប្រភេទទី១ គឺជារូបថត ហើយដែលរូបថតខ្លះគឺជាឯកសារថ្មី។ តើវាអ៊ីចឹងមែនទេ?

**កញ្ញា សុង ឆវ័ន្ត៖**

ជម្រាបលោកស្រីចៅក្រម មានឯកសារពីរប្រភេទ។ ឯកសារទី១ គឺឯកសារ E3/1662 នេះជាបញ្ជីអ្នកទោសដែលបានរៀបចំឡើងដោយសហព្រះរាជអាជ្ញាកាលពីឆ្នាំ២០០៨។ ហើយឯកសារទី២ គឺរូបថត។ រូបថតមានចំនួនពីរសន្លឹក។ រូបថតទី១ ជារូបថតដែលមិនទាន់មានលេខ D ឬលេខ E នៅឡើយ។ ហើយរូបថតទី២ ជារូបថតដែលមានលេខ D108/32.3 ដល់ P1184។ រូបថតនេះជាឯកសារដែលមានភ្ជាប់នៅក្នុងសំណុំរឿង០០១ ដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង០០១ រួចហើយ។

[០៩:២៥:១៩]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះខ្ញុំសួរតែរូបថតទេនៅពេលនេះ។ តើរូបថតទាំងពីរប្រភេទហ្នឹងគឺជាឯកសារថ្មី គឺជាឯកសារដែលមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ហើយពីមុននោះឯកសារទាំងពីរប្រភេទ -- រូបថតទាំងពីរប្រភេទមិនទាន់ដាក់ជា E3 នៅឡើយទេ។ ឥឡូវយើងទុកឯកសារ ស-២១ មួយអន្លើសិន

និយាយតែពីបញ្ហារូបថតសិនបានហើយ? សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាសលោកស្រី រូបថតទាំងនោះនៅមិនទាន់មានលេខ E នៅឡើយទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ហើយមានរូបថតពីរ អ៊ីចឹងមែនទេ?

**កញ្ញា សុង ឆវ័ន្ត៖**

ចាសលោកស្រី រូបថតមានពីរសន្លឹក។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីឯកសារ E3/1662 ជាបញ្ជីអ្នកទោស ស-២១ ដែលបានដាក់ -- ដែលតុលាការបានលើកយកមកនិយាយតាំងពីមុនម្ដងរួចហើយ។ តើអ៊ីចឹងមែនទេ?

[០៩:២៦:៣១]

**កញ្ញា សុង ឆវ័ន្ត៖**

ចាសលោកស្រី ពិតជាត្រឹមត្រូវ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ។ ចំពោះមេធាវីការពារក្ដីលោក វ៉ិចទ័រ កូប៉េ។ ពីមុនលោកថាមិនមានបញ្ហាអ្វីជាមួយនឹងការបង្ហាញឯកសារពីរសន្លឹកនេះទេ។ តើលោកជំទាស់ទៅនឹងរូបថតទាំងពីរដែលថាជាឯក-សារថ្មី តាមវិធាន៨៧(៤)ដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម ខាតវ៉ាយថ៍ ខ្ញុំមិនជំទាស់ទេ។ ខ្ញុំមានភាពបត់បែនពាក់ព័ន្ធទៅនឹងរូបថតទាំងនេះ។ ខ្ញុំយល់ឃើញថា នាពេលខាងមុខនេះ គឺថាតុលាការគាត់នឹងមានភាពបត់បែនទៅនឹងឯកសារដទៃទៀតដែរ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះឯកសារវែងគឺថាយើងបានដឹងទាំងអស់គ្នាហើយ។ ហើយបើទោះណាមិនបានដាក់នៅក្នុងអ៊ីនធឺហ្វេសដែលអង្គជំនុំជម្រះបានបញ្ជាក់យ៉ាងខ្លាំង ដែលវានេះជាការគួរសមមួយហើយ។ អង្គជំនុំជម្រះសុំទាមទារថា បើសិនណាជាមានការជំទាស់ណាមួយចំពោះការប្រើប្រាស់ឯកសារនេះ គឺការជំទាស់

ណាមួយជាសារវន្ត សូមលោកលើកឡើង។

[០៩:២៨:០៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម ខាតវ៉ាយច៍ ខ្ញុំមិនជំទាស់ទេ។ ដោយសារយើងខ្ញុំ ពេលខ្លះក៏មានការរៀបចំរួចរាល់ហើយនៅនាទីចុងក្រោយដែរ។ ដូច្នេះយើងខ្ញុំមានភាពបត់បែនដល់ម៉ោងដប់ពីរ។ ដូច្នេះនេះជាជំហររបស់យើងខ្ញុំ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

អរគុណ។ ដូច្នេះអង្គជំនុំជម្រះនឹងយកបញ្ហានេះមកពិចារណា។

លោក វែកគែន! លោក វែកគែន ខ្ញុំមានសំណួរដូចគ្នាចំពោះលោក។ តើលោកជំទាស់ទៅនឹងរូបថតពីរសន្លឹកដែលជារូបថតថ្មីគឺស្ថិតនៅក្រោមវិធាន៨៧(៤) ដែរឬទេ?

**លោក អាកទូរ វែកគែន៖**

បាទលោកស្រីចៅក្រម។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

*(គ្មានការបកប្រែ)*

[០៩:២៨:៥៨]

**លោក អាកទូរ វែកគែន៖**

ដោយសារខ្ញុំយល់ឃើញថាឯកសារហ្នឹងមានតាំងពីរយូរណាស់មកហើយ ហើយសហព្រះរាជអាជ្ញាបានសុំឱ្យសាក្សីទាំងអស់នេះមកបង្ហាញខ្លួននៅទីនេះ។ ហើយរយៈពេលរាប់សប្ដាហ៍ រាប់ខែមកហើយដែលគេនិយាយថាសាក្សីទាំងអស់នេះ គឺជាសាក្សីដែលជាសាក្សីដ៏សំខាន់បំផុតក្នុងចំណោមសាក្សីទាំង១០ ទាំង២០។ អ៊ីចឹងគេមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈ។ អ៊ីចឹងខ្ញុំយល់ឃើញថាខាងយើងវិញនេះ គឺថាយើងមានមធ្យោបាយតិចតួច ហើយមានការលំបាកច្រើនក្នុងការដាក់ឯកសារហើយយើងពិបាកធ្វើ។ អ៊ីចឹងខ្ញុំយល់ថាការបត់បែននេះមិនគួរណាមានតែខាងយើងទេ ខាងការពារក្ដីទេត្រូវមានភាពបត់បែននោះ ត្រូវខាងនុ៎ងក៏មានភាពបត់បែនផងដែរ។ ហើយអ៊ីចឹងចង់និយាយថា បើសិនជាមូលហេតុមួយទៀតហ្នឹងគឺថាខាងអ្នកស្រីហ្នឹង សាក្សីហ្នឹងគាត់ទទួលបានរូបថតហ្នឹងតាំងពីយូរណាស់មកហើយ គាត់ដឹង។

[០៩:៣០:០៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

បញ្ហាទី២ គឺបញ្ជីអ្នកទោសស-២១ E3/1662 ជាឯកសារដែលបានយកមកយោងជាច្រើនលើកច្រើនសាហើយនៅក្នុងសវនាការនេះ។ តើលោកមានការជំទាស់ជាសារវន្តណាមួយទៅហ្នឹងការសួរដេញដោលទៅលើរូបថតទាំងនេះទេ ដោយសារមិនទាន់បានដាក់នៅលើ អ៊ីនធឺហ្វេស ប្រចាំថ្ងៃនៅឡើយនោះ?

**លោក អាកទួរ វែកគែន៖**

ខ្ញុំមិនយល់ស្របទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណ។

**អ្នកបកប្រែ៖**

អម្បាញ់មិញមេធាវី គាត់និយាយថាគាត់មិនជំទាស់ទេ។

[០៩:៣០:៥៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៣:៣១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា ចំពោះសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាក្នុង ការដាក់ឯកសារដេញដោលនៅព្រឹកនេះ ឯកសារទី១ គឺឯកសារ E3/1662 គឺជាឯកសារដែលមានលេខ E3 ហើយភាគីធ្លាប់បានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះកន្លងមកហើយ។ ហើយអម្បាញ់-មិញនេះ គឺភាគីការពារក្តីក៏មិនជំទាស់លើបញ្ហានេះដែរ។ ដូច្នេះអង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឲ្យៗតំណាងសហព្រះ រាជអាជ្ញាផ្អែកលើមូលដ្ឋានឯកសារនេះក្នុងការពិភាក្សាដេញដោល ចំពោះកិច្ចពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ។ ហើយដោយឡែកបញ្ហារូបថតចំនួនពីរសន្លឹកដែលស្នើសុំដាក់ពិភាក្សាដេញដោល ពិតហើយ! ឃើញថាតំណាងសហព្រះរាជអាជ្ញាមិនបានបំពេញលក្ខខណ្ឌសមស្របទៅតាមវិធាន៨៧(៤) នោះទេ។ ប៉ុន្តែដោយសាររូបថតទាំងនេះគឺមានការពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សីហើយ និងពាក់ព័ន្ធទៅនឹងបញ្ហានានាដែលជាអង្គហេតុនៅក្នុងការពិភាក្សាដេញដោលស្តាប់សក្ខី-

កម្មសាក្សីរូបនេះ។ ដូច្នេះអង្គជំនុំជម្រះមានភាពបតបែនគឺអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាអាចយកឯកសារទាំងពីរនេះមកពិភាក្សាដេញដោលចំពោះសាក្សីនេះបាននៅក្នុងកិច្ចពិភាក្សាព្រឹកនេះ។

[០៩:៣៥:០៧]

ហើយដោយឡែក គឺឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តីលោក នួន ជា អំពីបញ្ហាសវនាការស្តាប់សក្ខីកម្មសាក្សីនៅថ្ងៃស្អែក គឺសាក្សី TCW-689។ ដោយសារសាក្សីរូបនេះ គឺមានសំណើសុំទាំងពីរគឺទាំងសហព្រះរាជអាជ្ញា ហើយទាំងមេធាវីការពារក្តី នួន ជា។ ហើយជាគោលការណ៍ គឺប្រសិនបើភាគីណាស្នើសុំមុន គឺអង្គជំនុំជម្រះផ្តល់ឲ្យភាគីនោះជាអ្នកតាំងសំណួរដេញដោលចំពោះសាក្សីរូបនោះមុនភាគីដទៃទៀតនៃរឿងក្តី។

ហើយគោលការណ៍ទី២ ដែលយើងបានអនុវត្តកន្លងមកក្នុងករណីមានការស្នើសុំទាំងពីរ ទាំងសងខាង គឺទាំងសហព្រះរាជអាជ្ញាហើយនិងទាំងមេធាវីការពារក្តីនោះ គឺសាក្សីរូបនោះ យើងផ្តល់ឱកាសឲ្យក្រុមសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនោះមុនភាគីការពារក្តី។

បាទ អានេះជាការកំណត់សម្គាល់។ ហើយចំពោះសាក្សីដែលមានរហស្សនាម TCW-689 គឺយើងអនុវត្តដូចករណីដែលយើងធ្លាប់អនុវត្តកន្លងមក គឺឲ្យខាងភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខសួរមុន ហើយចំណែកឯខាងមេធាវីការពារក្តី គឺចាប់ផ្តើមសួរពីមេធាវីការពារក្តី នួន ជា មុនមេធាវីការពារក្តីលោក ខៀវ សំផន បាទ។

បាទ ជាបន្តទៅនេះ សូមមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៣៨:០៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកស្រីសាក្សី តើលោកស្រីឈ្មោះអី?

**លោកស្រី ឯក ហេន៖**

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន។ នាងខ្ញុំឈ្មោះ ឯក ហេន។

**ស៖** អរគុណលោកស្រី ឯក ហេន។ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** នាងខ្ញុំអាយុ ៥៦ឆ្នាំ។

**ស៖** អរគុណលោកស្រី ហើយលោកស្រី ឯក ហេន សូមជម្រាបថា លោកស្រីសូមបង្អង់បន្តិច បន្ទាប់ពីលោកស្រីស្តាប់នៅសំណួរដែលសួរចំពោះលោកស្រី ដើម្បីទុកឱកាសឲ្យខាងអ្នកបកប្រែភាសាហ្នឹងបានបកប្រែភាសាលោកស្រីទៅជាពីរភាសាផ្សេងទៀត មានភាសាបារាំង និងភាសាអង់គ្លេស ដើម្បីប្រើប្រាស់នៅក្នុងកិច្ចដំណើរការសវនាការយើងនេះ។

ហើយចុះទីលំនៅសព្វថ្ងៃ លោកស្រីរស់នៅទីកន្លែងណា?

[០៩:៣៩:១១]

**ឆ៖** សព្វថ្ងៃ ទីលំនៅរបស់ខ្ញុំសព្វថ្ងៃរស់នៅក្នុងភូមិអង្គរជ័យក្រោម ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម។

**ស៖** បាទ អរគុណ ហើយលោកស្រីប្រកបមុខរបរធ្វើអ្វី?

**ឆ៖** មុខរបរនាងខ្ញុំធ្វើចម្ការ។

**ស៖** អរគុណ។ ចុះឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតលោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់នាងខ្ញុំឈ្មោះ ផន ម្តាយឈ្មោះ លន់។

**ស៖** ចុះស្វាមីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ស្វាមីនាងខ្ញុំឈ្មោះ សុង ផល។ ខ្ញុំមានកូនបួននាក់។

[០៩:៤០:១៨]

**ស៖** អរគុណលោកស្រី ឯក ហេន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកស្រីអាចដឹង គឺលោកស្រីមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលដែលអង្គជំនុំជម្រះបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តីនេះទេ ហើយក៏មិនជាប់ញាតិលោកហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបដែរ គឺលោក នួន ជា និងលោក ខៀវ សំផន។ ហើយថាលោកស្រីបានធ្វើសម្បថរួចហើយកាលពីម្សិលមិញនៅនឹងមុខអ្នកតាដំបងដែកនៅអ.វ.ត.ក នេះ។ តើជាការពិតដែរឬទេ?

**ឆ៖** វាជាការពិត។

**ស៖** អរគុណលោកស្រី ឯក ហេន។ ជាបន្តទៅនេះ យើងសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ច

ក្នុងនាមលោកស្រីនៅជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ លោកស្រី ឯក ហេន ក្នុងនាមលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនការចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏ការធ្វើឲ្យ -- សុំឲ្យលោកស្រីធ្វើអត្ថាធិប្បាយ ឬអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចក្នុងនាមលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកស្រីត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។ លើកលែងតែក្នុងករណីឆ្លើយតបទៅនឹងសំណួរ ឬក៏ការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពខ្លួនឯងដូចយើងជម្រាបអំពីសិទ្ធិខាងលើ។

[០៩:៤២:០១]

ហើយលោកស្រីត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ធ្លាប់បានមានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគីឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

តើលោកស្រី ឯក ហេន ដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ ឬទេ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ?

**ឆ៖** ចាស ខ្ញុំធ្លាប់ជួបសម្ភាសពីរដងដែរ។

**ស៖** លោកស្រីចាំថាធ្វើនៅទីកន្លែងណា ហើយនៅពេលណាទេ លើកទី១ ហើយនិងលើកទី២?

**ឆ៖** ចាស លើកទី១ គាត់បានទៅដល់ផ្ទះនាងខ្ញុំនៅភូមិកំណើតខ្ញុំ នៅឆ្នាំ៩៣។ កាលនោះ គាត់យកប្រវត្តិរូបទៅស្រាវជ្រាវពីអ្នកមានទោសនៅគុកទួលស្លែងចាស។ នាងខ្ញុំមានបងប្រុសមួយនៅមានឈ្មោះនៅគុកទួលស្លែងចាស។ គាត់យកប្រវត្តិរូបនោះទៅឲ្យខ្ញុំ។ កាលដើមឡើយខ្ញុំអត់ទាន់បានដឹង ដល់គាត់យកទៅឲ្យ គឺខ្ញុំបានឃើញប្រវត្តិរូប និងរូបថតរបស់គាត់ត្រូវគេសម្លាប់នៅគុកទួលស្លែងចាស។

[០៩:៤៣:៤៥]

**ស៖** ចុះលើកទី២ តើធ្វើកិច្ចសម្ភាសន៍ហ្នឹងជាមួយលោកស្រីនៅថ្ងៃខែឆ្នាំណា? លោកស្រីចាំទេ ហើយធ្វើនៅកន្លែងណា?

**ឆ៖** ចាស លើកទី២ក៏នៅផ្ទះនឹងខ្ញុំដែរ ប៉ុន្តែនៅក្នុងឆ្នាំ កាលនោះ ខ្ញុំអាយុ៥២ ឥឡូវ៥៦។ គិត

ទៅ៤ឆ្នាំហើយចាស។ គាត់ទៅសម្ភាសនៅផ្ទះខ្ញុំតែម្តង។

**ស៖** លោកស្រីចងចាំទេថាឆ្នាំ២០០៨, ២០០៩, ឬក៏២០១០? ឥឡូវនេះ ២០១៣ ឆ្នាំឥឡូវនេះ ដល់ឆ្នាំ២០១៣ ហើយ។

**ឆ៖** កាលនោះ ឆ្នាំ២០០៨ ចាស។ ឆ្នាំ២០០៨។ ធ្វើបាន៥ឆ្នាំហើយ។

**ស៖** តើលោកស្រីដឹងច្បាស់ទេ រវាងអ្នកដែលសម្ភាសលើកទី១ហ្នឹង គេប្រាប់លោកស្រីថាម៉េច? ហើយអ្នកសម្ភាសលើកទី២ហ្នឹង គេប្រាប់លោកស្រីថាម៉េច? លោកស្រីអាចញែកបានដែរទេ? ព្រោះហាក់ដូចជាខុសគ្នា ពីព្រោះយើងសួរអំមិញ គឺកិច្ចផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទើបតែបង្កើតឡើងហើយធ្វើសកម្មភាពនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយ -- ឆ្នាំ២០០៧ ចាប់ផ្តើម ២០០៦, ២០០៧ ទេ ហើយចំណែកឯមុននឹង គឺទំនងជាមិនមែនជាអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទេ។ អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង ដែលថាធ្វើនៅក្នុងអំឡុងឆ្នាំ២០០៨នេះ តើគាត់ធ្វើ ទៅធ្វើសម្ភាសជាមួយលោកស្រីប៉ុន្មានលើក?

[០៩:៤៥:៤៨]

**ឆ៖** ក្នុងឆ្នាំ២០០៨ហ្នឹង ដូចជាទៅម្តងដែរ តែម្តងទេ។

**ស៖** ហើយកន្លងមកលោកស្រីដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងពួកបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆ៖** ទៅសម្ភាស ដូចជា ខ្ញុំដូចអត់ចងចាំដែរ តែផ្នែកខាងស្រាវជ្រាវ ខាងសម្ភាសហ្នឹងទៅដល់ផ្ទះនាងខ្ញុំតែម្តង។

**ស៖** អរគុណលោកស្រី ហើយលោកស្រីចេះអក្សរខ្មែរច្បាស់លាស់ទេ?

**ឆ៖** នាងខ្ញុំអក្សរក៏មិនសូវជាច្បាស់លាស់ ព្រោះរៀនបានតិចពេក។ កាលខ្ញុំនៅរៀន គឺរដ្ឋប្រហារ ខ្ញុំបានអាយុត្រឹម១៣-១៤ឆ្នាំ គឺឈប់។

**ស៖** ចុះមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកស្រីបានពិនិត្យមើល ឬក៏បានអាន ឬក៏ស្តាប់ការអានពីសំណាក់ណាម្នាក់ឲ្យលោកស្រីស្តាប់នូវកំណត់ហេតុកត់ត្រានូវកិច្ចសម្ភាសន៍ដែលលោកស្រីបានធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលលោកស្រី

បាននិយាយអំមិញថា ការធ្វើកាលអំឡុងឆ្នាំ២០០៨ ដើម្បីរំឭកការចងចាំដែរឬទេ?

[០៩:៤៧:៣១]

**ឆ៖** ចាស ខ្ញុំឱ្យបងស្រីខ្ញុំគាត់អានឱ្យខ្ញុំស្តាប់។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំ ថាតើលោកស្រីអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលផ្តល់ ដែលលោកស្រីផ្តល់កិច្ចសម្ភាសន៍ ដែលលោកស្រីបានពិនិត្យ និងបានអាននោះ តើវាត្រឹមត្រូវ ឬក៏ស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកស្រីបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៅក្នុងអំឡុងឆ្នាំ២០០៨ ដែលបានធ្វើនៅផ្ទះលោកស្រីនោះដែរឬទេ?

**ឆ៖** ចាស ពិតជាដូចខ្ញុំនិយាយមែន ចាស។ ខ្ញុំនិយាយ--

**ស៖** សូមអញ្ជើញៗបន្ត!

**ឆ៖** ខ្ញុំនិយាយតែត្រឹមត្រូវពីការខ្ញុំចងចាំកន្លងផុតមក។ ខ្ញុំអត់មាននិយាយខុសពីការចងចាំទេចាស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយតំណាងសហព្រះរាជអាជ្ញា រួមនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ ក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:៤៩:០២]

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម និងអង្គសវនាការសាជាថ្មី។ សូមជម្រាបផងដែរ លោកស្រីសាក្សី ឯក ហេន។ នាងខ្ញុំឈ្មោះ សុង ឆវ័ន្តជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយសហការីអន្តរជាតិរបស់ខ្ញុំលោក ឃីត រេយ៍ន័រ ជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ យើងខ្ញុំទាំងពីរថ្ងៃនេះមានសំណួរមួយចំនួនដើម្បីសាកសួរលោកស្រី ដើម្បីឱ្យលោកស្រីជួយបង្ហាញការពិត ដើម្បីស្វែងរកយុត្តិធម៌នៅក្នុងរឿងក្តីនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ជាបឋម ខ្ញុំចង់ជម្រាបសួរលោកស្រីថា តើលោកស្រីមានបងប្អូនបង្កើតប៉ុន្មាននាក់?

**លោកស្រី ឯក ហែន៖**

**ឆ៖** នាងខ្ញុំមានបងប្អូនបង្កើតបីនាក់។ ប្រុសពីរ ស្រីមួយ ចាស។ បងទី១ ឈ្មោះ ពិន ហឿន។ ទី២ ឈ្មោះ ពិន ស៊ន។ នាងខ្ញុំឈ្មោះ ហែន។

**ស៖** តើបងប្រុសរបស់លោកទាំងពីរហ្នឹងមានឈ្មោះហៅក្រៅ ឬឈ្មោះដែលប្រើនៅក្នុងបដិវត្តន៍ដែរទេ?

[០៩:៥០:២៤]

**ឆ៖** ចាស មាន។ បងប្រុសនាងឈ្មោះដើមឈ្មោះ ហឿន ឈ្មោះគាត់បដិវត្តន៍ឈ្មោះ សឿន។ បងទី២ ឈ្មោះដើមឈ្មោះ ហៃ ឈ្មោះបដិវត្តន៍ឈ្មោះ ស៊ន។ នាងខ្ញុំឈ្មោះដើមឈ្មោះ ហែន ឈ្មោះមួយទៀតឈ្មោះ ជា ចាស។

**ស៖** ចាស សូមអរគុណលោកស្រី។ តើបងប្អូនរបស់លោកស្រីនៅមានជីវិតរស់រានទាំងអស់គ្នាក្រោយរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ ឬក៏មានអ្នកបាត់បង់ ឬក៏ស្លាប់ខ្លះដែរ?

**ឆ៖** បងប្អូននាងខ្ញុំបានស្លាប់ ឪពុកខ្ញុំក៏ត្រូវស្លាប់នៅសង្គ្រាមសម័យ៧០, ៧១, ៧២ ចាស។ ឪពុកខ្ញុំស្លាប់នៅឆ្នាំ៧១ ក្រោយមកទៀតបងប្រុសនាងខ្ញុំស្លាប់នៅឆ្នាំ៧៤ សល់ពីនោះទៀតបែកខ្ញែកគ្នាអស់ចាស។

**ស៖** លោកស្រីថាបងប្រុសលោកស្រីបានស្លាប់នៅឆ្នាំ១៩៧៤នោះ តើបងប្រុសឈ្មោះអី ឬបងប្រុសទីប៉ុន្មានដែរ?

**ឆ៖** បងប្រុសទី២ គាត់ស្លាប់នៅសមរភូមិព្រែកព្នៅចាស។

**ស៖** ចុះបងប្រុសទី១ របស់លោកស្រី ដែលឈ្មោះ ហឿន ហៅ សឿន នោះ គាត់ស្លាប់នៅក្នុងឆ្នាំណាដែរ លោកស្រីនៅចាំទេ?

[០៩:៥២:៣៦]

**ឆ៖** បងប្រុសឈ្មោះ ហឿន ហៅ សឿន ហ្នឹងនាងខ្ញុំអត់ដឹងទេ។ កាលណោះខ្ញុំទៅ៧៩ ខ្ញុំបានទៅដល់ជំរំ ខ្ញុំបកពីជំរំវិញថាមកបោះឆ្នោត។ ដូច្នេះមានផ្នែកខាងស្រាវជ្រាវយកប្រវត្តិរូបហ្នឹងទៅឲ្យនាងខ្ញុំដល់ផ្ទះ។ ចាស ប្រវត្តិរូបហ្នឹងមានឈ្មោះគាត់ ឈ្មោះដើម ឈ្មោះបដិវត្តន៍ គាត់មានពាក់ស្លាកលេខ១ គាត់បានស្លាប់នៅក្នុងគុកទួលស្លែងចាស។

**ស៖** អរគុណលោកស្រី។ ខ្ញុំនឹងចូលព័ត៌មានលម្អិតពាក់ព័ន្ធនឹងបងប្រុសលោកស្រី ប៉ុន្តែមុននឹង

ចូលដល់ព័ត៌មាននេះ ខ្ញុំចង់សួរព័ត៌មានទូទៅថា ថាបងប្រុសទាំងពីររបស់លោកស្រីហ្នឹងមានធ្លាប់ចូលធ្វើកងទ័ពខ្មែរក្រហមទេ? ហើយបើសិនបើធ្លាប់ ចូលនៅក្នុងភូមិភាគមួយណាដែរ?

**ឆ៖** បងប្រុសនាងខ្ញុំចូលធ្វើកងទ័ពនៅភូមិភាគឧត្តរ។ ឪពុកខ្ញុំក៏គាត់នៅភូមិភាគឧត្តរ គាត់ស្លាប់នៅភូមិភាគរឧត្តរ នៅខាងស្វាយទាប។ ឯបងប្រុសនាងខ្ញុំចូលធ្វើកងទ័ពនៅភូមិភាគឧត្តរដែរ។

**ស៖** ចុះលោកស្រីចាំទេថា នៅក្នុងភូមិភាគឧត្តរហ្នឹងមានគេហៅឈ្មោះលេខកូដ ឬក៏លេខតំបន់លេខភូមិភាគលេខប៉ុន្មានដែរ ចាំទេ?

**ឆ៖** ជំនាន់នោះភូមិភាគឧត្តរ គេហៅថាភូមិភាគ៣០៤។ គាត់នៅកងទ័ពភូមិភាគ៣០៤ ចំណែកកងពលរបស់គាត់ខ្ញុំមិនចាំ ចាសភ្លេចអស់ហើយ។ គាត់នៅភូមិភាគ៣០៤ចាស។

**ស៖** ចុះគាត់នៅភូមិភាគ៣០៤ ហ្នឹងមានតំណែង ឬក៏តួនាទីអ្វីដែរនៅក្នុងភូមិភាគនោះ?

[០៩:៥៥:០៥]

**ឆ៖** គាត់ជាកងទ័ព គាត់ជាមេបញ្ជាការ គាត់ជាកងពល -- កងវរៈសេនាធំ ហ្នឹងបងប្រុសឈ្មោះហឿន។ ឯបងប្រុសទី២ ឈ្មោះ ហៃ ហ្នឹងគាត់ជាយុទ្ធជនធម្មតាទេចាស។

**ស៖** ចាសសូមអរគុណ។ តើលោកស្រីរស់នៅក្នុងភូមិណា ឬក្នុងតំបន់ណាដែរនៅពេលដែលប្រទេសកម្ពុជាត្រូវបានរំដោះដោយកងទ័ពខ្មែរក្រហមឆ្នាំ១៩៧៥?

**ឆ៖** បើនិយាយត្រឹមពី៧៥មក ក្រុមគ្រួសារនាងខ្ញុំត្រូវបែកខ្ញែកគ្នាទាំងអស់។ ខ្ញុំនៅផ្ទះ ក្រោយមកខ្ញុំក៏ចូល -- គេបានបញ្ជូនខ្ញុំទៅលើកទំនប់នៅ ហៅថាបឹងកាង១ បឹងកក់ ជិតជីហែ ចាស។ ដល់ពេលទៅ ជំនាន់នោះខ្ញុំនៅស្ទើរដែរ រែកដីមិនរួច ទៅបានតែ៣ថ្ងៃ។ នាងខ្ញុំស្ម័គ្រចិត្តទៅយុទ្ធនារី។ ខ្ញុំថានៅសមរភូមិក្រោយវាពិបាក ដូច្នេះទៅមុខម្តង បើស្លាប់ក៏ស្លាប់ចុះ។ ដាច់ចិត្តទៅៗសមរភូមិ។ ជំនាន់ហ្នឹងគេបញ្ជូនខ្ញុំទៅនៅស្រុកកញ្ជៀចចាស ហាត់ជាយុទ្ធនារី។ ក្រោយមកទទួលមិនទាន់បានទៅវ៉ៃឯណាផង គ្រាន់តែថាបានដឹកជញ្ជូន តែក្រោយមកបានរំដោះទីក្រុងភ្នំពេញ ថ្ងៃ១៧មេសា នាងខ្ញុំបានជួយដកស្នងប្រជាជនបានចំនួន២ ឬ៣ខែ។ ក្រោយមកបានគេបញ្ជូននាងខ្ញុំមកភ្នំពេញចាស។ មកដល់ភ្នំពេញស្ងាត់ជ្រងំ--

[០៩:៥៧:០៨]

**ស៖** ចាស លោកស្រី អរគុណ។ ខ្ញុំនឹងសួរបន្តលោកស្រី យើងខ្ញុំនឹងសួរលោកស្រីមួយដំណាក់កាលម្តងៗ។ លោកស្រីបានបញ្ជាក់ថា លោកស្រីត្រូវបានគេបញ្ជូនទៅលើកទំនប់នៅបឹងកាង។ ខ្ញុំចង់

សួរបញ្ជាក់ថា តើនៅពេលដែលគេបញ្ជូនលោកស្រីទៅលើកទំនប់នៅបឹងកាងនោះ មានមនុស្សប៉ុន្មាននាក់ចេញពីភូមិលោកស្រីទៅ ហើយមនុស្សទាំងអស់នោះ ជាក្មេង ឬក៏ជាមនុស្សចាស់ ជាមនុស្សប្រភេទណាដែរ?

**ឆ៖** កាលពីជំនាន់នុ៎ង លើកទំនប់គេយកតាមភូមិ។ នារីៗមានចូល នារីអាយុ១៦ឆ្នាំ គេចាប់ពីអាយុ១៦ឆ្នាំទៅ ដឹងតែចូលនារីបានហើយ។ ដូច្នេះគេរើសពីអាយុ១៦ឡើងទៅ ទៅលើកទំនប់នៅបឹងកាងនាងខ្ញុំអាយុ១៦ឆ្នាំកាលហ្នឹង ១៦, ១៧ហ្នឹងទៅលើកទំនប់។ យកតាមភូមិ ក្នុងមួយភូមិយកពីរនាក់។ ចុះមកភូមិ មួយស្រុកទៅ ទៅជុំគ្នានៅកន្លែងទំនប់ បានន័យថាច្រើន។

[០៩:៥៨:២៧]

**ស៖** ចាស សូមអរគុណ។ ចុះពេលដែលប្រមូលប្រជាជនតាមភូមិទៅលើកទំនប់ហ្នឹង តើពេលដែលប្រមូលបានហ្នឹង គេធ្វើដំណើរពីភូមិទៅលើកទំនប់នៅបឹងកាងហ្នឹង គេមានការដឹកជញ្ជូន ឬក៏ត្រូវដើរដោយថ្មើរជើងទៅដែរ?

**ឆ៖** ចាសជំនាន់នោះ អត់មានឡាន អត់មានអីទេ គឺដើរទៅថ្មើរជើង កាន់បង្គីទៅខ្លួនឯងតែម្ដង។ ម្ចាស់ការខ្លួនឯងតែម្ដង យកទៅលើកនៅកន្លែងហ្នឹង។ មានបង្គីពីរ ដងរែកមួយយកទៅ ដើរទៅឆ្ងាយផងមិនមែនជិតឯណា។

**ស៖** តើចម្ងាយពីភូមិលោកស្រី ទៅកន្លែងលើកទំនប់ហ្នឹងមានចម្ងាយប៉ុន្មានដែរ? ហើយលោកស្រីដឹងទេថាអ្នកណាជាអ្នកសម្រេចប្រមូល ឬក៏បញ្ជូនមនុស្សឱ្យទៅលើកទំនប់ហ្នឹង?

**ឆ៖** ចាស ជំនាន់នោះនៅតាមភូមិគេមានប្រធាននារី ប្រធានយុវជន ដូច្នេះគេចាត់តាំងយើងតែម្ដង។ គេចាត់តាំងថាឈ្មោះហ្នឹងត្រូវទៅ ត្រូវតែទៅតែម្ដងចាស។

[០៩:៥៩:៥៧]

**ស៖** លោកស្រីបានបញ្ជាក់មុននេះថា ពេលដែលប្រមូលប្រជាជនតាមភូមិហ្នឹង គឺដល់ពេលប្រមូលបានទៅមានប្រជាជនច្រើន។ ចុះពេលទៅដល់កន្លែងលើកទំនប់ហ្នឹងមានប្រជាជនដែលទៅពីភូមិហើយ តើពេលទៅដល់កន្លែងលើកទំនប់ហ្នឹងមានមនុស្សនៅកន្លែងហ្នឹងហើយឬនៅ? ហើយមានប្រហែលជាប៉ុន្មានដែរ លោកស្រីនៅចាំបាទេ? ប្រហាក់ប្រហែលក៏បានដែរទេ?

**ឆ៖** ទីកន្លែងលើកទំនប់គឺមានមនុស្សច្រើន។ គេនៅទីនោះកំពុងតែលើក យើងទៅដល់ថែមទៀតបើនិយាយទៅមិនមែនរាប់រយទេ គឺរាប់ពាន់តែម្ដង។ ចាស កំពុងតែលើកទំនប់ជំនាន់នោះយន្តហោះមក

នាំគ្នាក្រាបទៅ យន្តហោះទៅបាត់នាំគ្នាងើបធ្វើការទៀតទៅចាស។ ហើយទៅទីនោះអត់មានវិលមកវិញទេ គ្រប់១០ថ្ងៃបានវិលមកវិញ។ ដូច្នេះ មូសក៏ខាំ កន្លែងដេកក៏អត់មាន។ ដូច្នេះធ្វើឲ្យនាងខ្ញុំទ្រាំមិនបាន សំខាន់គឺមូសខាំដេកមិនបានហ្នឹងតែម្តង។

**សៈ** តើជាក់ស្តែងគេតម្រូវឲ្យលោកស្រីធ្វើការអ្វីខ្លះដើម្បីលើកទំនប់ហ្នឹង? ការងារហ្នឹងធ្វើអីខ្លះ?

[១០:០១:២៣]

**ឆៈ** ចាស ការងារលើកទំនប់គឺមានធ្វើអ្វី គឺរែកដីហ្នឹងហើយ។ រែកដីឡើងចាក់ទំនប់ទៅ លើកទំនប់ខ្ពស់ រែកឡើងទៅ។

**សៈ** តើការងារហ្នឹងមានការលំបាកខ្លាំងដែរឬទេ?

**ឆៈ** ការងារនោះបើនិយាយទៅវាលំបាកដែរ រែកដី យើងជាស្រី នារីកំពុងតែអាយុ ១៦, ១៧ រែកដី វាល់ៗល្ងាច យប់សម្រាកមិនបានមូសខាំ បឹងកក់ៗ បឹងកាងហ្នឹង គឺជាបឹងសុទ្ធតែកក់ យប់ឡើងមូស ច្បូតចាស។

**សៈ** ចាស លោកស្រីខ្ញុំចង់សួរបញ្ជាក់ពីឆ្នាំបន្តិច មុននេះលោកស្រីថាបន្ទាប់ឆ្នាំ១៩៧៥ គេប្រមូលឲ្យប្រជាជនទៅលើកទំនប់។ ចង់ដឹងថាលោកស្រីចាំខែ ឬថ្ងៃណាឲ្យពិតប្រាកដ ថាលោកស្រីចេញពីភូមិដើម្បីទៅលើកទំនប់ហ្នឹង?

[១០:០២:៥៤]

**ឆៈ** កាលនោះចុងឆ្នាំ៧៤ ដើមឆ្នាំ ៧៥ ចាស ព្រោះខ្ញុំទៅអត់មានវិលមកវិញផង។ ខ្ញុំទៅហួសទៅតែម្តង ខ្ញុំផ្ញើតែបង្គី និងដងរែកមកផ្ទះវិញ។ ខ្ញុំទៅបានតែ៣ថ្ងៃ ខ្ញុំក៏ហួសទៅធ្វើយុទ្ធនារីទៅ។

**សៈ** តើលោកស្រីចាប់ផ្តើមចេញទៅធ្វើយុទ្ធនារីហ្នឹងនៅក្នុង នៅមុនរំដោះ ១៧ មករា ៧៥ ឬក៏បន្ទាប់ពីរំដោះ១៧ មេសា ៧៥? ហើយទៅធ្វើហ្នឹង ទៅធ្វើនៅកន្លែងណាដែរ ទៅធ្វើយុទ្ធនារីហ្នឹង?

**ឆៈ** នាងខ្ញុំចេញទៅឆ្នាំ ខ្ញុំទៅហ្នឹងចុងឆ្នាំ៧៤ ដើមឆ្នាំ៧៥ មុនរំដោះ១៧ មេសា ។ នាងខ្ញុំទៅជាយុទ្ធនារីគឺនៅក្នុងស្រុកកញ្ជៀច ហាត់រៀននៅក្នុងស្រុកកញ្ជៀច ខេត្តព្រៃវែងចាស។ ខ្ញុំនៅក្នុងក្រុមទី៣ កងតូចទី២ គទី១៣ ចាស។

**សៈ** លោកស្រីនៅចាំទេថា នៅក្នុងភូមិភាគណាដែរ?

**ឆៈ** កាលនោះ ខ្ញុំទៅនៅក្នុងភូមិភាគបូព៌ា ហៅថាតំបន់២០៣ ចាស។

**សៈ** តើលោកស្រីទទួលបានការបណ្តុះបណ្តាល ឬហាត់យុទ្ធនារីហ្នឹង រយៈពេលប៉ុន្មានដែរ?

[១០:០៥:០៦]

**ឆ៖** នាងខ្ញុំហាត់ជាយុទ្ធនារីនៅក្នុងភូមិស្វាយចេក ស្រុកកញ្ជៀចហ្នឹង គឺអស់រយៈពេល៦ខែ ទើបចប់។

**ស៖** ហើយពេលហាត់ជាយុទ្ធនារីហ្នឹង តើអ្នកណាជាអ្នកបណ្តុះបណ្តាលលោកស្រី?

**ឆ៖** កាលដែលចេញទៅហ្នឹង គឺមានគេចាត់តាំងជាកងជាក្រុមអីចឹង គេមានកងរយកងអីគេហ្នឹង គេអ្នកហាត់ បង្ហាត់បង្រៀនយើងចាស មានតាមក្រុម តាមកងអីចឹងទៅ។

**ស៖** តើលោកស្រីនៅចាំឈ្មោះអ្នកដែលបង្ហាត់លោកស្រីទេ? ហើយលោកស្រីនៅចាំទេថា តំបន់២០៣ហ្នឹង អ្នកណាជាអ្នកគ្រប់គ្រង?

**ឆ៖** អង្គាល់នោះ នៅក្នុងក្រុមទី៣ កងតូចទី២ កងធំទី១៣។ យុទ្ធនារីភូមិភាគបូព៌ា តំបន់២០៣ ក្តោបក្តាប់ដោយ សោ ភឹម ចាស។ គណៈភូមិភាគគឺ សោ ភឹម។

**ស៖** តើ សោម ភឹម មានដែលចុះមកបង្ហាត់បង្រៀនលោកស្រីដោយផ្ទាល់ ឬក៏មានអ្នកផ្សេងមកបង្ហាត់បង្រៀន?

**ឆ៖** សោ ភឹម គាត់ជា បើនិយាយទៅគាត់ជាគណៈភូមិភាគ ដូច្នេះមិនអាច -- ពួកខ្ញុំក៏មិនដែលស្គាល់ដែរ តែគ្រាន់តែឮឈ្មោះថា គណៈភូមិភាគបូព៌ាឈ្មោះ សោម ភឹម តែជាអ្នកតូចៗដូចជាកងរយកងអីអ្នកបង្ហាត់បង្រៀនទេ។ តែចំណែកគេអ្នកធំគេមិនដែលស្គាល់ពួកនាងខ្ញុំនោះទេ ចាស។

[១០:០៧:០៩]

**ស៖** ចុះនៅក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាល ឬក៏ហាត់ជាកងយុទ្ធនារី ៦ខែហ្នឹង គេមានដែលបង្រៀនលោកស្រីពីរឿងរ៉ាវពាក់ព័ន្ធនឹងវៀតណាម ឬក៏ត្រូវធ្វើដូចម្តេចជាមួយពួកយួនទេ?

**ឆ៖** ជំនាន់នុំងដូចជាអត់មាន។ អត់មានពាក់ព័ន្ធរឿងថា ជាមួយវៀតណាមជាមួយអីអត់មានទេ ចាស។ អត់មាន។

**ស៖** ចុះការបណ្តុះបណ្តាល ឬការបង្រៀនពាក់ព័ន្ធជាមួយនឹងសត្រូវ ឬខ្មាំង ឬក៏អ្នកក្បត់ទាំងអស់នោះ តើមានធ្លាប់ដែលបានទទួលការបណ្តុះបណ្តាលទេ?

**ឆ៖** ចាស អត់មានទេ ចាស។

**ស៖** ក្រោយពីលោកស្រីបញ្ចប់វគ្គបណ្តុះបណ្តាល ៦ខែ នៅភូមិភាគបូព៌ា តើលោកស្រីបានចាកចេញទៅធ្វើការនៅកន្លែងណាដែរ ហើយនៅក្នុងឆ្នាំណា?

**ឆ៖** នាងខ្ញុំនៅក្នុងភូមិភាគបូព៌ា ក្រោយមករំដោះ ១៧ មេសា បានចំនួន បានប្រហែល ៤ខែ ត្រូវគេបញ្ជូនមកដល់ទីក្រុងភ្នំពេញ។ ស្នាក់នៅទីក្រុងភ្នំពេញបាន១អាទិត្យ ត្រូវគេបញ្ជូនទៅរហូតដល់កំពង់សោមទៀតចាស។

**ស៖** តើគេបញ្ជូនលោកស្រីទៅកំពង់សោមហ្នឹង បញ្ជូនទៅធ្វើអ្វីដែរ? ហើយទៅដល់ទីនោះ លោកស្រីចាំទេថា កន្លែងហ្នឹងឈ្មោះអី?

**ឆ៖** ជំនាន់នុ៎ង ពួកខ្ញុំគឺជាវាលែងជាកងទ័ពនារីអីទៀតហើយ វាទៅជាកងចល័ត។ គេចង់បញ្ជូនទៅបោសសម្អាតនៅកំពង់សោម នៅកាកសំណល់បែកបាក់ជំនាន់នោះ ស្វាត់ជ្រងំពួកខ្ញុំទៅបោសសម្អាតទីកន្លែងទទួលភ្ញៀវនៅកំពង់សោម នៅកន្លែងរោងចក្រស្រាបៀរ គិតទៅប្រមែប្រមូលសម្អាតទាំងអស់ចាសនៅទីកំពង់សោម។

[១០:០៩:៥៥]

**ស៖** លោកស្រីថា កន្លែងទទួលភ្ញៀវដែលគេតម្រូវឲ្យពួកលោកស្រីបោសសម្អាត តើកន្លែងទទួលភ្ញៀវនោះជាកន្លែងរបស់អ្នកណាដែរ លោកស្រីដឹងទេ?

**ឆ៖** ជំនាន់នោះគឺមានឈ្មោះហៅថាលោក១ ញ៉ែម កន្លែងទទួលភ្ញៀវកំពង់សោមមានលោកញ៉ែម អ្នកបញ្ជាឲ្យពួកនាងខ្ញុំបោសសម្អាត ចាស។

**ស៖** ខ្ញុំចង់សួរលោកស្រីថា តើកន្លែងដែលទទួលភ្ញៀវហ្នឹង លោកស្រីដឹងទេថា គេទុកដើម្បីទទួលភ្ញៀវណា ឬក៏របស់អ្នកណាដែរ?

**ឆ៖** បើនិយាយបញ្ហាហ្នឹង នាងខ្ញុំអត់បានដឹងទេ នាងខ្ញុំបានត្រឹមថាដើរបោសសម្អាតឲ្យស្អាតទាំងអស់។ កន្លែងណាភក់ជ្រាំ គឺលុប កន្លែងណាព្រៃគឺឆ្ការជម្រះឲ្យស្អាតចាស។

**ស៖** ចាសអរគុណ។ តើលោកស្រីធ្លាប់ធ្វើការនៅស្រែអំបិលទេ?

[១០:១១:០៤]

**ឆ៖** កន្លងមក ខ្ញុំនៅកំពង់សោម។ ស្អាតអស់ហើយ ទើបគេបញ្ជូននាងខ្ញុំទៅស្រែអំបិលចាស។ ទៅស្រែអំបិល គើបអំបិលដាក់បាវចាស។ ដាក់បាវលីដាក់ឡានចាស។ ជំនាន់នុ៎ងសុទ្ធតែនារី គើបអំបិលដាក់បាវ លីដាក់ឡាន ក្នុងមួយបាយដាក់៦០គីឡូ។ នាងខ្ញុំលីឡើងឡាន ដាក់ក្តារបន្ទះដើរស្ទូឡើងឡានចាស។

**ស៖** តើលោកធ្វើការនៅស្រែអំបិលនោះអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ធ្វើការនៅស្រែអំបិល កើបអំបិលអស់នៅកំពង់កណ្ដាល ត្រើយកោះ រហូតដល់កំពង់ណុងសេះស និងរោងចក្រ -- នៅស្រែអំបិលកំពង់ត្រាចមួយទៀត។ ទាល់តែប្រមូលអស់រលីងទើបនាងខ្ញុំត្រឡប់មកវិញ។ អស់រយៈកាល៣ខែ។

**ស៖** នៅក្នុងអំឡុងពេល៣ខែដែលលោកស្រីធ្វើការនៅស្រែអំបិលហ្នឹង តើស្ថានភាពធ្វើការ និងស្ថានភាពរស់នៅហ្នឹងយ៉ាងណាដែរ? លំបាក ឬក៏ងាយស្រួលយ៉ាងណាដែរ?

**ឆ៖** បើនិយាយពីការងាយស្រួល មិនងាយស្រួល គឺលំបាក។ នារីលីសែង មិនធម្មតាឯណា។ លីសែង លើកដូចកម្មករកំពង់ផែ លើកឡើងដាក់លើស្នាលីឡើងឡាន។ បានន័យថាយ៉ាប់។

[១០:១៣:១២]

**ស៖** តើលោកស្រីដឹងទេថា អ្នកណាជាអ្នកគ្រប់គ្រងនៅស្រែអំបិលហ្នឹង? មានឈ្មោះអីដែរ?

**ឆ៖** បើនិយាយពីអ្នកគ្រប់គ្រងស្រែអំបិល អ្នកស្រែអំបិល អ្នកគេផលិតផ្សេង។ ពួកខ្ញុំជាកងចល័តដើរប្រមែប្រមូលនេះ គឺផ្សេង អត់មានពាក់ព័ន្ធគ្នាទេ គេអ្នកនៅខាងផលិតអំបិល គេគិតតែផលិតយើងអ្នកកើបគឺគិតតែកើប។ កើបហើយត្រូវត្រឡប់មកវិញ។ ដូច្នេះ ពួកខ្ញុំជាកងគេ មេបញ្ជាការគេអត់មានទៅទេ គេបញ្ជាឲ្យយើងជាកងចល័តហ្នឹងនាំគ្នាទៅប្រមូលមកតែម្ដងចាស។

**ស៖** តើអ្នកណាជាមេបញ្ជាការនៅពេលនោះ? នៅស្រែអំបិលហ្នឹង?

**ឆ៖** កាលនោះទៅតាមកងរយចាស។ កងរយទៅពីរកងរយ។ នាងខ្ញុំទៅពីរកងរយចាស ទៅកើបអំបិលហ្នឹង ហើយផ្នែកខាងដឹកជញ្ជូន ពួកដឹកជញ្ជូនជើងគោក គេអ្នកបើកឡាន ពួកខ្ញុំអ្នកកើប អ្នកជញ្ជូនចូលចាស។ បើរឿងរកអ្នកទទួលខុសត្រូវមានតែកងរយចាស។

[១០:១៤:៣២]

**ស៖** ចាសអរគុណ។ ចុះលោកស្រីថាធ្វើការនៅស្រែអំបិលហ្នឹង៣ខែ បន្ទាប់ពីចាកចេញពីស្រែអំបិលហ្នឹង តើលោកស្រីទៅធ្វើការនៅកន្លែងណាដែរ ហើយនៅក្នុងឆ្នាំណា លោកស្រីចាំទេ?

**ឆ៖** នៅក្នុងឆ្នាំ៧៦ដែរ។ នាងខ្ញុំបានត្រឡប់ចូលមកភ្នំពេញវិញ ត្រូវបញ្ជូនមកទីក្រុងភ្នំពេញវិញ។ ខ្ញុំមកដល់ទីក្រុងភ្នំពេញ គេបានបញ្ជូនខ្ញុំទៅនៅកន្លែងកាត់ដេរមជ្ឈិម ចាស។

**ស៖** កន្លែងកាត់ដេរមជ្ឈិមហ្នឹងមានទីតាំងនៅកន្លែងណាដែរ លោកស្រីចាំ ឬក៏ស្គាល់ទីតាំងទេ?

**ឆ៖** កាត់ដេរមជ្ឈិមហ្នឹង គឺជាកាត់ដេរ គេហៅថាកាត់ដេររដ្ឋ។ ដេរសម្លៀកបំពាក់ទូទៅ នៅផ្សារអូរឫស្សីតែម្ដង ចាស។ ផ្សារអូរឫស្សីពីដើម ក្នុងកណ្ដាលផ្សារអត់មានដូចសព្វថ្ងៃទេ គឺមានតែ

កន្លែងលក់។ គឺសម័យនោះ កណ្ដាលផ្សារជាកន្លែងពួកខ្ញុំហូបបាយ ចាស សម័យហ្នឹង។ ឯផ្ទះជុំវិញហ្នឹងជាផ្ទះដេរ។ ផ្ទះខាងជួរនេះក៏ដេរៗ ជួរផ្ទះខាងនោះគឺកាត់ ចាស។ ពួកនាងខ្ញុំនៅកន្លែងកាត់ដេរហ្នឹងរហូតចាស។

[១០:១៦:០៩]

**ស៖** តើលោកស្រីនៅកន្លែងកាត់ដេររបស់មជ្ឈិម ឬក៏អង្គការ ឬក៏កន្លែងកាត់ដេររដ្ឋហ្នឹងរយៈពេលប៉ុន្មានដែរ? ឬក៏ដល់ថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** បើនិយាយទៅ កន្លែងកាត់ដេរគឺតាំងពីចូល តាំងពី៧៦ ចុងឆ្នាំ៧៦ ខ្ញុំដេររហូតដល់ឆ្នាំ៧៩ តែម្ដង។ ដល់ថ្ងៃ០៧ មករា តែម្ដង។

**ស៖** តើកន្លែងកាត់ដេររបស់រដ្ឋ ឬរបស់មជ្ឈិមហ្នឹង គេមានឈ្មោះហៅថាជាអង្គភាពអ្វីដែរទេ?

**ឆ៖** កាត់ដេរមជ្ឈិមគឺជាកន្លែងកាត់ដេរធំមួយ គេហៅថា កាត់ដេរមន្ទីរគ-៩ ចាស។ មន្ទីរគ-៩ ហ្នឹង ជាសាខារបស់មន្ទីរ៨៧០ ចាស។

**ស៖** ហេតុអ្វីបានជាលោកស្រីមន្ទីរគ-៩ ជាសាខាមួយរបស់មន្ទីរ៨៧០?

**ឆ៖** នាងខ្ញុំដឹង ព្រោះនាងខ្ញុំនៅធ្វើការទីនោះ គឺឮប្រធានមន្ទីរគ-៩ ហ្នឹង គាត់និយាយរ៉ាយរាប់ប្រាប់អ៊ីចឹងចាស។ ព្រោះជំនាន់ហ្នឹង អាចប្រជុំប្រាប់អ៊ីចឹងដែរ។

**ស៖** លោកស្រីរំឭកដល់ប្រធាន គ-៩។ តើប្រធាន គ-៩ហ្នឹង គាត់ឈ្មោះអ្វី? ហើយពេលហ្នឹងគាត់ប្រាប់លោកស្រីថាយ៉ាងម៉េច?

[១០:១៨:២៦]

**ឆ៖** គាត់ជាប្រធានមន្ទីរ គឺទៅមន្ទីរគ-៩ ហ្នឹង គឺកន្លែងក្ដោបក្ដាប់ធំ។ កន្លែងកាត់ដេរទាំងអស់ហ្នឹងលើគាត់ ចាស។ ប៉ុន្តែគាត់បានលើកឡើងថា ជាសាខាជាមួយមន្ទីរ៨៧០ដែរ អ៊ីចេះ។ ចំណែកនាងខ្ញុំអត់ដឹងទេណា៎ ប៉ុនឮគាត់ឡើងថា គាត់និយាយថាអ៊ីចឹង ចាស។

**ស៖** ចាស សូមអរគុណលោកស្រី។ ចុះនៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅក្នុងអង្គភាពកាត់ដេរជាសាខាមួយរបស់មជ្ឈិមហ្នឹង តើម៉ោងពេលធ្វើការយ៉ាងម៉េចដែរ? ហើយស្ថានភាពរស់នៅពេលនោះយ៉ាងម៉េចដែរ?

**ឆ៖** កាលពីជំនាន់នុ៎ង ការងារពលកម្មគឺងើបម៉ោងបួន។ មួយការងារសង្គមនិយម មួយការងារស្នូល។ ការងារសង្គមនិយម គឺការងារងើបពីយប់ ទៅស្រោចបន្លែ ដាំបន្លែ។ ត្រឡប់មកវិញ មុជទឹកមុជ

អីហើយ ចូលកាត់ការងារស្ទូល គឺកាត់ដេរតែម្តង ចាស។

**ស៖** ចាប់ផ្តើមចូលធ្វើការងារស្ទូលហ្នឹង ពីម៉ោងប៉ុន្មាន ហើយដល់ម៉ោងប៉ុន្មានដែរ? ហើយស្ថានភាពរស់នៅពេលធ្វើការនៅទីនោះយ៉ាងម៉េចដែរ? ការហូបចុក? ការស្នាក់នៅ?

[១០:២០:១៥]

**ផ៖** ការងាររស់នៅកន្លែងកាត់ដេរ បើនិយាយទៅបើយើងធ្លាប់យូរៗទៅ វាទៅជាធម្មតា។ ដូចគេថាយើងធ្វើអ្វីមួយដូចថាមុនដំបូងថាពិបាកណាស់ ធ្វើមិនកើតទេ ងើបពីយប់ ពិបាកដេកមិនឆ្អែតអ៊ីចឹងដល់យូរៗទៅដល់ម៉ោងស្ទុះតែម្តង។ ចាស ដល់ម៉ោងបួនហ្នឹងគឺគេរ៉ៃជួងហើយ ជួងស្ទូលកង់ឡានមួយដាក់នៅជ្រុងកែងផ្សារអូរឫស្សីហ្នឹង រ៉ៃម៉ឺងៗ ស្ទុះងើបទាញប៉ោតទៅស្រោចបន្លែ។ បកមកវិញការងារស្ទូលម៉ោងប្រាំពីរចូល ម៉ោងប្រាំបួនឈប់១៥នាទី ចូលវិញម៉ោងដប់មួយគឺឈប់ ចាសសម្រាកហូបបាយ។

**ស៖** ចុះលោកស្រីឈប់ធ្វើការនៅម៉ោងដប់មួយ ឬក៏ថ្ងៃត្រង់ហ្នឹងត្រូវបន្តការងារទៀតដែរ? ហើយបើសិនជាបន្តដល់ម៉ោងប៉ុន្មានដែរ?

[១០:២១:១៨]

**ផ៖** ម៉ោងដប់មួយហូបបាយហើយសម្រាកចាស។ ម៉ោងមួយចូលធ្វើការវិញ រហូតដល់ម៉ោងបួនសម្រាក ទាញប៉ោតទៅស្រោចបន្លែថែមទៀតចាស។ ព្រឹកក៏ស្រោច ល្ងាចក៏ស្រោច មកពីស្រោចវិញញ៉ាំបាយ បាយហើយដល់ម៉ោងធ្វើការដល់ម៉ោងប្រាំបួនយប់។

**ស៖** ចាសសូមអរគុណ។ ខ្ញុំចង់ដល់ប្រធានបទថ្មីមួយទៀត ពាក់ព័ន្ធទៅនឹងអ្នកដែលធ្លាប់ធ្វើការជាមួយលោកស្រី។ នៅក្នុងឯកសារ D94/8 ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមកពីតុលាការមួយនេះ។ នៅពេលដែលអ្នកស៊ើបអង្កេតសួរអ្នកស្រី នៅត្រង់ ERN ជាភាសាខ្មែរគឺ 00172064, និង ERN ជាភាសាអង់គ្លេសគឺ 00205048 ដល់ 49។

អ្នកស៊ើបអង្កេតបានសួរលោកស្រីដូច្នេះថា ខ្ញុំដកស្រង់ "តើក្នុងអង្គភាពអ៊ំមានបាត់ខ្លួនឬទេ?" លោកស្រីបានឆ្លើយថា ដកស្រង់ "ខ្ញុំឃើញមានការចាប់ខ្លួនមនុស្សឡើងឡានឃ្លុបបិទជិតដោយកងទ័ពមានអាវុធ។ មុនដំបូងគេចាប់មេៗ បន្ទាប់មកចាប់អនុ និងសមាជិកណាដែលមានការពាក់ព័ន្ធនឹងខ្សែឧត្តរ"។

[១០:២៣:២២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបដែលសហព្រះរាជអាជ្ញាតាំងសំណួរ គឺថាយើងកត់សម្គាល់ឃើញថា គឺថាគាត់បានផ្តល់នូវតម្រុយយ៉ាងទូលំទូលាយ ហើយគាត់សួរសំណួររបៀបបើកចំហ។ ហើយនៅពេលទៅដល់ចំណុចសំខាន់នៃការសួរសំណួរនោះ គឺថាយើងដូចជាថានាំឲ្យសាក្សីទាយស្មានទាំងស្រុង។

[១០:២៤:០៥]

ដូច្នេះ ខ្ញុំមិនដឹងថានៅពេលដែលយើងកោះហៅសាក្សីមក ហើយដើម្បីគ្រាន់តែអាននូវចម្លើយរបស់គាត់ ហើយសួរគាត់នាំមុខបែបនេះ គឺថាយើងមិនដឹងធ្វើយ៉ាងម៉េចទេ ដូចជាគ្មានប្រយោជន៍អីទេនៅពេលដែលយើងសួររបៀបនេះនោះ។ ដូច្នេះសូមឲ្យសហព្រះរាជអាជ្ញាសួរសំណួរជាលក្ខណៈបិទវិញនៅពេលដែលពាក់ព័ន្ធនឹងចំណុចទូទៅ ហើយសួរសំណួរបើកនោះគឺថានៅពេលដែលមានចំណុចពាក់ព័ន្ធសំខាន់។ ដូច្នេះធ្វើអ៊ីចឹងបានត្រឹមត្រូវ ហើយបើយើងធ្វើអ៊ីចឹងទៅដូចជាគ្មានន័យអីទេនៃការសួរសំណួររបស់គាត់បែបនេះនោះ។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធានខ្ញុំសូមឆ្លើយតបដោយខ្លីថា នីតិវិធីនៃការសួរសំណួរដោយដកស្រង់នូវចម្លើយដែលធ្លាប់បានផ្តល់ជាមួយអ្នកស៊ើបអង្កេតនេះ ត្រូវបានទទួលដោយអង្គជំនុំជម្រះ ហើយបានអនុវត្តជាច្រើនលើកជាច្រើនសានៅក្នុងតុលាការមួយនេះហើយ។ ហើយខ្ញុំក៏មិនយល់ហេតុអ្វីបានជាមេធាវីនៅតែបន្តជំទាស់ទៅនឹងរបៀបនៃការតាំងសំណួរបែបដូច្នេះ។ ហេតុដូច្នេះសុំអនុញ្ញាតលោកប្រធានបន្តនូវការតាំងសំណួរនេះ។

[១០:២៥:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២៦:២០]

**ប្រធានអង្គជំនុំ៖**

បាទសេចក្តីជំទាស់និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន នៅចំពោះសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ គឺមិនមានមូលដ្ឋានសមស្របទេ។ សេចក្តីជំទាស់មិនត្រូវទេ ដូច្នេះសេចក្តីជំទាស់មិនមានប្រសិទ្ធភាព។

ប៉ុន្តែទន្ទឹមនឹងនេះអង្គជំនុំជម្រះសូមរំឮកជម្រាបជូនដល់ខាងសហព្រះរាជអាជ្ញាផងដែរថា សូមរៀបចំនូវសំណួរដែលមានភាពពាក់ព័ន្ធឲ្យបានច្បាស់លាស់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១។ ហើយជាពិសេស គឺសំណើរបស់តំណាងសហព្រះរាជអាជ្ញាដែលបានស្នើសុំបន្ថែមនូវសាក្សីមួយចំនួនដែលនៅក្នុងសំណើនោះទាំងខ្លឹមសារនៃលិខិតដែលបង្ហាញអំពីសំណើ ក៏ដូចជាសំណើដែលបង្ហាញផ្ទាល់មាត់នៅក្នុងពេលកិច្ចប្រជុំរៀបចំសវនាការបានកំណត់នូវចំណុច ដែលកម្មវត្ថុនៃការរំលេច និងការលើកឡើងយ៉ាងច្បាស់លាស់នៅក្នុងសំណើរបស់ខ្លួនហើយ។

នេះជាមូលហេតុដែលអង្គជំនុំទទួលយក ហើយសម្រេចកោះអញ្ជើញសាក្សីដែលបន្ថែម ដែលភាគីស្នើសុំបន្ថែមមកស្តាប់សក្ខីកម្ម។

[១០:២៧:៣៥]

អ៊ីចឹងគឺមិនមែនការសួរពាសវាលពាសកាលតាមទៅនឹងកំណត់ហេតុដែលស្តាប់សក្ខីកម្មដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។ ដូចពីម្សិលមិញគឺយើងច្បិចតែមួយចំណុចណា មួយទំព័រណា ឬក៏ផ្នែកណាដែលពាក់ព័ន្ធសំខាន់ទៅនឹងអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម ឬក៏ការអនុវត្តគោលនយោបាយដូចសំណើប៉ុណ្ណោះ។ សូមរៀបចំនូវសំណួរឲ្យបានត្រឹមត្រូវ និងសមស្របឡើងវិញបាទ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាសអរគុណលោកប្រធាន។ ខ្ញុំនឹងធ្វើតាមការណែនាំ។

[១០:២៨:១៤]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រី ឯក ហេន ខ្ញុំនឹងដកស្រង់បន្ត ហើយមានសំណួរបន្តបន្ទាប់ចង់សួរលោកស្រីនៅត្រង់ ERN និងឯកសារដដែល។ ខ្ញុំសូមដកស្រង់ "ខ្ញុំឃើញមានការចាប់ខ្លួនមនុស្សឡើងឡានឃ្ពុបបិទជិតដោយកងទ័ពមានអាវុធ។ មុនដំបូងគេចាប់មេៗ បន្ទាប់មកចាប់អនុ និងសមាជិកណាដែលមាន

ការពាក់ព័ន្ធនឹងខ្សែឧត្តរ និងបូព៌ាដែលគេចោទថាក្បត់។ កែវ ជាប្រធានរោងចក្រត្រូវគេចាប់យកទៅបាត់នៅឆ្នាំ១៩៧៧ ដោយជាប់ខ្សែបូព៌ា"។ ខ្ញុំចង់សួរលោកស្រីថា តើលោកស្រីបានឃើញគេចាប់ឈ្មោះ កែវ នេះដោយផ្ទាល់ភ្នែកដែរឬទេ?

[១០:២៩:១៦]

**លោកស្រី ឯក ហេន៖**

**ឆ៖** កាលពីជំនាន់នុំុង ពួកខ្ញុំដែរ។ ផ្ទះជាប់ៗគ្នាអ៊ីចឹង ផ្ទះគាត់ ផ្ទះខ្ញុំក៏ជាប់គ្នាដែរ ពេលឡានមកពួកខ្ញុំក៏អត់ស្គាល់គេ។ ឡានគេមកឈប់អ៊ីចឹង គេមកហៅគាត់ទៅ យកទៅបាត់។ ប៉ុន្តែមិនដឹងថាយកទៅកន្លែងណាក៏ខ្ញុំអត់ដឹងដែរ។ ហើយឲ្យខ្ញុំស្គាល់គេ ក៏អត់ស្គាល់ ព្រោះកន្លែង -- ជំនាន់ហ្នឹងនៅកន្លែងណាគឺនៅកន្លែងនុំុង មិនអាចស្គាល់គ្នាឆ្ងាយៗបានទេ។ បានផ្ទះក្បែរៗគ្នាអ៊ីចឹង ស្គាល់។ ដល់ចូលមក គេមកហៅទៅអ៊ីចឹង យើងមើលទៅឃើញអ៊ីចឹងដែរ។ ប៉ុន្តែមិនដឹងថាគេយកទៅណា ក៏ខ្ញុំអត់ដឹងដែរ។ យូរៗបាត់ជាបន្តបន្ទាប់ ដូចខ្ញុំបាននិយាយអ៊ីចឹង។ តែឲ្យដឹងថាយកទៅកន្លែងណា ទៅនៅកន្លែងណា រួចយកទៅធ្វើម៉េច ខ្ញុំក៏អត់ដឹងដែរ បានត្រឹមតែឃើញ។

[១០:៣០:១៨]

**ស៖** ចាស ពេលដែលលោកស្រីបានឃើញគេចាប់ កែវ ដាក់ឡានឃ្លុបបិទជិតហ្នឹង តើពេលដែលគេមកចាប់គាត់យកទៅហ្នឹង ចាប់តែគាត់ម្នាក់ឯងទេ ឬក៏មានបុគ្គលផ្សេងដែលធ្វើការនៅក្នុងនោះត្រូវបានគេចាប់យកទៅដែរ?

**ឆ៖** ពេលដែលយកគាត់ទៅហ្នឹងគឺមិនមានច្រើនទេ។ ម្តងមួយ យូរៗទៅមួយទៀតទៅ។ ចាស អ៊ីចឹង។ ប៉ុន្តែមិនដឹងថាមូលហេតុអី ពួកខ្ញុំក៏អត់ដឹងដែរ។

**ស៖** តើខ្ញុំយល់ជាការត្រឹមត្រូវទេ មានន័យថានៅថ្ងៃដែលគេចាប់ កែវ យកទៅដាក់ឡានឃ្លុបបិទជិត ហើយយកទៅនោះ គឺចាប់យកតែ កែវ ម្នាក់ទេមិនមានអ្នកផ្សេងទៅជាមួយទេ នៅថ្ងៃនោះ?

**ឆ៖** ចាស គឺមានតែមួយ។

**ស៖** ចុះលោកស្រីស្គាល់ឈ្មោះ គុន ដែលធ្វើការនៅរោងចក្រកាត់ដេរជាមួយលោកស្រីដែរឬទេ?

**ឆ៖** ស្គាល់។

**ស៖** តើ គុន ហ្នឹងមានរឿងអ្វីកើតឡើងបន្ទាប់ពី កែវ ត្រូវបានគេចាប់ខ្លួនហើយ?

[១០:៣១:៥៣]

**ឆ៖** បើនិយាយថាមានរឿង ពួកខ្ញុំក៏គ្មានដឹងអីទាំងអស់ អត់មានដឹងគឺយើងធ្វើការគិតតែធ្វើការរឿងគេគឺដោយគេស្រេចតែគេ ដឹងគេទៅណាមកណាក៏យើងអត់ដឹង។ ដឹងថាបាត់ខ្លួនដឹងថាបាត់។

**ស៖** អ៊ីចឹងមានន័យថា គុន ក៏ត្រូវបានបាត់ខ្លួនពីកន្លែងកាត់ដេរដែលលោកស្រីធ្វើការដែរបន្ទាប់ពីកែវ បាត់ខ្លួន អ៊ីចឹងមែនទេ?

**ឆ៖** ចាស គាត់ត្រូវបាត់ខ្លួន។

**ស៖** ចាសអរគុណ។ លោកប្រធាននាងខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនូវភស្តុតាងជារូបថត D108/32.3 ដល់ P1184 ដែលបានអនុញ្ញាតដោយអង្គជំនុំជម្រះកាលពីព្រឹកមិញនេះ និងមានឯកសារជូនដល់សាក្សីផង ដើម្បីសួរបញ្ជាក់សាក្សីពាក់ព័ន្ធទៅនឹងភស្តុតាងមួយនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១០:៣៣:១៥]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រី ឯក ហេន សូមលោកស្រីពិនិត្យមើលរូបថតមួយនេះ ហើយសូមលោកស្រីបញ្ជាក់ប្រាប់អង្គសវនាការថា តើលោកស្រីធ្លាប់ស្គាល់មនុស្សនៅក្នុងរូបថតនេះដែរឬទេ?

**លោកស្រី ឯក ហេន ៖**

**ឆ៖** បើនិយាយទៅវាមិនច្បាស់ព្រោះជំនាន់នោះ ដូចថាវាយូរដែរហើយ ចងចាំមិនបាន។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនូវភស្តុតាងជាឯកសារមួយទៀត ដែលបានការអនុញ្ញាតពីលោកប្រធានកាលពីព្រឹកមិញពាក់ព័ន្ធនឹងរូបថតដែលទទួលពី ឌី.ស៊ី.ខេម។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**កញ្ញា សុង ឆវ័ន្ត៖**

សូមបញ្ជាក់ថា រូបថតនេះមិនមាននៅក្នុង -- មិនអាចយកមកបង្ហាញលើអេក្រង់កុំព្យូទ័របានទេ

ហេតុនេះ ខ្ញុំបានថតចម្លងដើម្បីចែកជូនភាគីនិងអង្គជំនុំជម្រះដើម្បីពិនិត្យ។

[១០:៣៥:៤០]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រី ឯក ហេន លោកស្រីពិនិត្យរូបថតនេះហើយ តើលោកស្រីស្គាល់បុគ្គលដែលមាននៅក្នុងរូបនេះដែរឬទេ?

**លោកស្រី ឯក ហេន៖**

**ឆ៖** នេះ រូបថតនេះ បើនិយាយទៅវាស្រដៀងនឹងបងរបស់ខ្ញុំ តែនេះវាមិនសូវច្បាស់ចាស។ ប៉ុន្តែឈ្មោះអីហ្នឹងដូចគ្នា។ ភិនភាគរបស់គាត់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីកំណត់ត្រាតុលាការ ខ្ញុំពិនិត្យឃើញថា ដើម្បីកត់ត្រាហ្នឹងគឺថា បង្ហាញជូនឯកសារមករូបថតទៅសាក្សីនោះ ខ្ញុំឃើញប្រហែលជាខ្ញុំមើលទៅខុស គឺថាសាក្សីមានរូបថតដោយមានអត្ថបទអក្សរនៅជុំវិញហ្នឹងផង។ ខ្ញុំមិនច្បាស់ ដូច្នេះសូមសហព្រះរាជអាជ្ញាជម្រាបខ្ញុំឲ្យបានយល់ផងបាទ។

[១០:៣៧:១៤]

**កញ្ញា សុង ឆវ័ន្ត៖**

សូមជម្រាបដល់មេធាវី ហើយនិងលោកប្រធានឲ្យបានជ្រាបថា តាមពិតឯកសារដែលខ្ញុំមានបំណងបង្ហាញសាក្សីគឺនៅក្នុងដៃសាក្សី ហើយឯកសារនេះមានឈ្មោះ និងរូបថតដែលបិទនៅកែងចុងដើម្បីបង្ហាញសាក្សី ហើយខ្ញុំបានព្រីនមួយចំនួនចេញមក ប៉ុន្តែដោយសារតែឯកសារនេះមិនបានត្រៀមគ្រប់គ្រាន់ដើម្បីបង្ហាញជូនសាក្សី។ មានរូបថតដូចគ្នាដែលបានកាត់ចេញដាក់នៅក្នុងឯកសារមួយដើម្បីបង្ហាញជូនសាក្សី តែរូបថតនេះគឺជារូបថតដូចគ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែបើនិយាយអំពីតម្លៃភស្តុតាងហ្នឹងគឺថា បើមានរូបថត ហើយមានអក្សរទៀតគឺជាវិធីមួយផ្សេង ប៉ុន្តែបើសិនជាសហព្រះរាជអាជ្ញាដាក់តែរូបថត សួរថាគាត់ឈ្មោះអី អាហ្នឹងជារឿងផ្សេង។ ដូច្នេះគឺថាគប្បីតែប្រើរូបថតដូចគ្នាដែលភាគី និងអង្គជំនុំជម្រះបាន។ អ៊ីចឹងមិនមានអត្ថប្រយោជន៍ទេនៅពេល

ដែលឲ្យរូបថតដោយភ្ជាប់ជាមួយនឹងអត្ថបទផងនោះ ដូចជានាំមុខដល់សាក្សីដូច្នោះដែរ។

[១០:៣៨:២៧]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកប្រធាន ខ្ញុំនឹងបន្តទៅមុខ ហើយដោយសារតែសាក្សីនៅស្រពេចស្រពិលជាមួយរូបថតនេះ។ ហេតុដូច្នេះខ្ញុំនឹងបន្តសំណួរទៅប្រធានបទតូចមួយផ្សេងទៀត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញទៅមុខទៀត!

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រី ឯក ហេន មុននេះលោកស្រីបានប្រាប់ដល់អង្គសវនាការ--

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអភ័យទោស ខ្ញុំសូមកាត់ម្តងទៀត។ ប៉ុន្តែត្រូវបង្ហាញភស្តុតាងឲ្យច្បាស់ សាក្សីត្រូវបានបង្ហាញរូបថតដោយមានអត្ថបទ ហើយមានឈ្មោះអ្នកដែលនៅក្នុងរូបថតនោះផង។ ដូច្នេះយើងមិនទាន់ដឹងច្បាស់ទេ ថាតើសាក្សីអាចកំណត់អត្តសញ្ញាណដូចម្តេចនឹងបាន បើមានពាក្យពេចន៍នៅលើនោះគ្រប់គ្រាន់ទៅហើយនោះបាទ?

[១០:៣៩:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤២:៣៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

ខ្ញុំយល់ថាសាក្សីបានទទួលរូបថតមួយ ដោយមានអត្ថបទភាសាខ្មែរនៅលើទំព័រជាមួយគ្នានោះ។ ហើយអត្ថបទនោះ ដែលរាប់បញ្ចូលឈ្មោះនៃមនុស្សនៅលើរូបថតនោះ តើអ៊ីចឹងដែរឬទេ?

**កញ្ញា សុង ឆវ័ន្ត៖**

ចាស ជាក់ស្តែងលោកស្រីចៅក្រម សាក្សីបានទទួលអត្ថបទមួយដែលមានរូបថត និងជាអត្ថបទ

ជាភាសាខ្មែរនៅជាមួយ។

[១០:៤៣:២៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ក្នុងករណីបែបនេះ លោកប្រធានបានស្នើខ្ញុំថាឲ្យនឹងសម្រេចថា ការជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា នោះ មានប្រសិទ្ធភាព។ ដោយហេតុថាការដាក់អត្ថបទដោយមានឈ្មោះនោះ គឺថាអាចនឹងផ្ដល់ទៅឲ្យសាក្សីនោះ គឺថាមិនអាចនឹងមានតម្លៃជាភស្តុតាងទេ គឺមិនអាចប្រើក្នុងការកំណត់ពីអត្តសញ្ញាណនោះទេ។

តើខ្ញុំសម្រេចប៉ុណ្ណឹងគ្រប់គ្រាន់ទេ លោកប្រធាន។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៤នាទី ដល់ម៉ោង ១១:០១នាទី)*

[១១:០១:១៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះអង្គជំនុំជម្រះ

ផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ផង ថាតើមានការចែករំលែកពេលវេលាយ៉ាងម៉េច រវាងតំណាងសហព្រះរាជអាជ្ញាជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរនេះ? ពីព្រោះនៅពេលវេលាតែមួយ១ម៉ោងទៀតទេ។

ទី២ សូមការសួរដេញដោល គឺឲ្យចំទៅនឹងអង្គហេតុដែលគោលបំណងនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះ អំពីតួនាទីរបស់ជនជាប់ចោទ តាមសំណើសុំរបស់ខ្លួនដែលបានដាក់សុំស្នើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែម ដែលបានលើកឡើងនៅក្នុងសំណើ ក៏ដូចជាសំណើផ្ទាល់ដែលបានលើកឡើងបង្ហាញនៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក។ សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ នាងខ្ញុំបានពិភាក្សាជាមួយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយពួកគាត់បានប្រាប់មកយើងខ្ញុំថា ពួកគាត់ត្រូវពេលវេលាប្រហែលជា២០នាទីប៉ុណ្ណោះ។ ហើយដោយសារតែព្រឹកនេះយើងបានចាប់ផ្តើមនូវពេលយឺតបន្តិច អ៊ីចឹងសហព្រះរាជអាជ្ញានឹងខិតខំបញ្ចប់ឲ្យទាន់ពេលវេលា។ ប៉ុន្តែប្រសិនបើមិនអាច ប្រហែលជាយើងខ្ញុំអាចស្នើសុំពេលវេលាបន្ថែម មិនលើសពី១០ទៅ១៥នាទីពីអង្គជំនុំជម្រះប៉ុណ្ណោះ។

[១១:០៣:៣០]

**ប្រធានអង្គជំនុំ៖**

ទំនងជាអង្គជំនុំជម្រះមិនអនុញ្ញាតទេ ដោយសារហេតុផលពេលវេលាដែលអង្គជំនុំជម្រះចែកជូនទៅ ការប្រើប្រាស់ពេលវេលាមិនមានប្រសិទ្ធភាពទេ។ ការសំណួរដេញដោលមិនទាន់ចំបញ្ហាដែលបានរំលេចលើកឡើងក្នុងន័យស្នើសុំឲ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីបន្ថែមនោះឡើយ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតសួរសាក្សីបន្ត។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រី ឯក ហេន លោកស្រីបានប្រាប់ថាលោកស្រីបានឃើញ កែវ ដែលជាប្រធានរោងចក្រហ្នឹងត្រូវបានគេចាប់ដោយផ្ទាល់ភ្នែក។ តើលោកស្រីនៅចាំ ឬបានដឹងទេថា កែវ ហ្នឹងគាត់មានឈ្មោះពេញអ្វីដែរ?

**លោកស្រី ឯក ហេន៖**

**ឆ៖** នាងខ្ញុំក៏មិនសូវបានជាស្គាល់ដែរ គ្រាន់ថាហៅថា បងកែវៗ គាត់ប្រធានរោងចក្រកាត់ដេរ។ នាងខ្ញុំអត់ដឹងថានាមត្រកូលគាត់យ៉ាងណាគឺអត់ដឹង។

**ស៖** ចាស សូមអរគុណ។ នៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅក្នុងរោងចក្រកាត់ដេរនោះ តើលោកស្រីនៅចាំ ឬក៏នឹកឃើញទេថាមនុស្សដែលនៅក្នុងរោងចក្រហ្នឹងបានបាត់បង់ ឬក៏បាត់ខ្លួនទៅប្រហែលជាប៉ុន្មានដែរ តាំងពីធ្វើការមក?

[១១:០៤:៥៥]

**ឆ៖** បើតាមខ្ញុំដឹង ខ្ញុំនៅកន្លែងនោះគឺឃើញបាត់អស់ បួននាក់។

**ស៖** ចុះនៅពេលដែលលោកស្រីឃើញមានមនុស្សបាត់ខ្លួន ឬក៏ឃើញគេចាប់មនុស្សដោយផ្ទាល់ភ្នែកអ៊ីចឹង តើពេលហ្នឹងលោកស្រីមានអារម្មណ៍ ឬក៏យល់ឃើញយ៉ាងណាដែរ?

**ឆ៖** ដោយឃើញផ្ទាល់ភ្នែកដូច្នេះ នាងខ្ញុំទាំងអស់គ្នាជាកម្មករចេះតែនាំគ្នាខ្សឹបខ្សៀវ ភ័យខ្លាចចាស នាំគ្នាភ័យខ្លាចដែរ តែការងារនៅតែធ្វើធម្មតាជារៀងរាល់ថ្ងៃដូចគ្នាចាស។

**ស៖** ចាស សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

ខ្ញុំសូមបញ្ចប់ការសាកសួរ ហើយសូមផ្ទេរវេទិកានេះបន្តទៅសហព្រះរាជអាជ្ញាអន្តរជាតិ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញ!

[១១:០៥:៥៩]

**លោក ឃីត រេយ៍ន័រ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តីទាំងអស់។ ជម្រាបសួរលោកស្រី ឯក ហេន។

លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារពីរជូនលោកស្រី ឯក ហេន។ ឯកសារ D1.3.3.2 ជាកំណត់ហេតុរបស់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសាររបស់សហការិយាល័យសហចៅក្រមស៊ើបអង្កេតគឺ E3/474 ។ សូមបង្ហាញឯកសារទាំងពីរនេះជូនទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អាកទួរ វែកគែន!

**លោក អាកទួរ វែកគែន៖**

បាទ សូមឲ្យសហព្រះរាជអាជ្ញាបញ្ជាក់លេខកូដឯកសារទី២ ម្តងទៀត យើងអត់ស្តាប់ៗអត់ទាន់ទេ ជាភាសាបារាំងអម្បាញ់មិញនេះ។

[១១:០៧:០៣]

**លោក ឃីត រេយ៍ន័រ៖**

បាទ ឯកសារទី២ គឺ E3/474 ជាកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី ឯក ហេន លោកស្រីបានទទួលឯកសារពីរនេះមកហើយ។ ឯកសារទី១ មានចំណងជើងថា "មជ្ឈមណ្ឌលឯកសារកម្ពុជា" ជាកំណត់ត្រាកិច្ចសម្ភាសន៍រវាងលោកស្រីដែលមានទីតាំងនិងកាលបរិច្ឆេទនៃការសម្ភាសថ្ងៃទី០៦ ខែសីហា ២០០៣ ហើយអ្នកសម្ភាសលោកស្រី ឈ្មោះ ឡុងដានី។ តើលោកស្រីអាចបញ្ជាក់បានទេ លោកស្រីស្គាល់ឯកសារហ្នឹងទេ?

*(សម្រាករយៈពេលខ្លី)*

[១១:០៩:០០]

**ប្រធានអង្គជំនុំ៖**

សូមឆ្លើយលោកស្រី តើលោកស្រីស្គាល់ឯកសារហ្នឹងដែរឬទេ? ធ្លាប់បានឃើញ បានអានឯកសារហ្នឹងដែរឬទេ?

**លោកស្រី ឯក ហេន៖**

**ឆ៖** នាងខ្ញុំធ្លាប់បានឃើញឯកសារហ្នឹងចាស។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** សូមអរគុណលោកស្រី។ ហើយឯកសារមួយទៀតដែលលោកស្រីបានទទួលដែរនោះ គឺកំណត់ហេតុស្តាប់ចម្លើយដែលគេសម្ភាសលោកស្រី ដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃតុលាការនេះ ហើយមើលទៅឃ្លាដំបូងបង្ហាញកាលបរិច្ឆេទនៅថ្ងៃទី០៥ មីនា ២០០៨។ សូមលោកស្រីជួយបញ្ជាក់ តើលោកស្រីបានទទួលឯកសារហ្នឹងហើយមានពេលអានឯកសារហ្នឹង ឬក៏មានអ្នកណាអានឲ្យលោកស្រីស្តាប់រួចហើយ ឬនៅមុនពេលលោកស្រីចូលមកចំពោះមុខតុលាការនេះ?

**ឆ៖** មើលជាប់គ្នារដឹកហ្នឹង មើលម៉េចដាច់។ នាងខ្ញុំគឺបានឲ្យបងស្រីនាងខ្ញុំ ព្រោះខ្ញុំ ភ្នែកខ្ញុំមើលទៅវាជាប់គ្នាទាំងអស់ចាស។ បានស្តាប់ គាត់អានឲ្យស្តាប់ដែរ។

[១១:១០:២៥]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមអានសម្រង់ចេញពីឯកសារនេះមួយពាក្យម្តងៗ ហើយសួរលោកស្រីថា តើលោកស្រីនៅតែប្រកាន់យកចម្លើយដែលលោកស្រីឆ្លើយជូនអ្នកស៊ើបអង្កេតនៃតុលាការនេះដែរ ឬក៏អត់នោះ? ឯកសារនេះគឺ E3/474 ទំព័រពាក់ព័ន្ធជាអង់គ្លេស 00205049, ខ្មែរ 00172064 ដល់ 65, បារាំង 00205054។

"សំណួរ៖ តើលោកស្រីធ្លាប់ស្គាល់ នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ដែរឬទេ? ឆ្លើយ៖ ខ្ញុំធ្លាប់ស្គាល់ នួន ជា និង ខៀវ សំផន ដោយសារគាត់មកធ្វើការប្រជុំ រៀនសូត្រនៅបុរីកីឡា បង្រៀនដល់បុគ្គលិកកម្មករ។ ខ្ញុំធ្លាប់ទៅរៀនសូត្រនៅបុរីកីឡាចំនួនពីរដង។ លើកទី១ នៅឆ្នាំ១៩៧៦ ដោយមាន ខៀវ សំផន ជាអ្នកដឹកនាំប្រជុំរៀនសូត្រនៅបុរីកីឡានេះ។ ចំពោះខ្លឹមសារប្រជុំមានដូចជាការនិយាយអំពីការខិតខំធ្វើការ ការសន្សំសំចៃ អំពីបញ្ហាហូបចុក។ ពេលនោះ ខៀវ សំផន ក៏បានលើកមកនិយាយអំពីបញ្ហាឈ្មោះ ប៉ង់ ដែលគាត់ប្រកាសប្រាប់ថាឈ្មោះ ប៉ង់ ជាប្រធានមន្ទីរ៨៧០នោះ ត្រូវបានគេចាប់ខ្លួនយកបាត់ទៅហើយ។ ដោយសារតែគាត់ជាអ្នកចូលដៃក្បត់ជាមួយនឹងយួន។ គឺពេលនោះហើយដែលខ្ញុំស្គាល់ឈ្មោះ ប៉ង់ ជាប្រធានមន្ទីរ៨៧០។ ខ្ញុំមិនដឹងថាមន្ទីរ៨៧០នោះ ធ្វើអ្វីទេ។ ខ្ញុំគ្រាន់តែដឹងថា អង្គភាពកាត់ដេររបស់ខ្ញុំជាសាខាមួយរបស់មន្ទីរ៨៧០ ដែលឈ្មោះ ប៉ង់ ធ្លាប់មកមើលការងារកម្មករធ្វើការនៅរោងចក្រខ្ញុំ។ ហើយ ខៀវ សំផន ធ្លាប់បានមកមើលកន្លែងខ្ញុំធ្វើការនៅឆ្នាំ១៩៧៦ ពេលនោះមកមើលចំពេលកម្មករកំពុងហូបបាយ។ ហើយគាត់បានយកស្លាបព្រាខ្ញុំភ្លក់សម្លដែលខ្ញុំកំពុង

ហូប។ ហើយគាត់សួរថា សម្លនេះឆ្ងាញ់ទេ? ខ្ញុំឆ្លើយថា ឆ្ងាញ់។ ខៀវ សំផន ធ្លាប់មកមើលរោងចក្របី ឬក៏បួនដងដែរ”។ បញ្ចប់ការដកស្រង់។

សំណួរដំបូងរបស់ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់សួរ!

[១១:១៣:៤៨]

**លោក អាកទួរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំដឹងថាសហព្រះរាជអាជ្ញាគាត់មានពេលកម្រិត ក៏ប៉ុន្តែខ្ញុំយល់ឃើញថា ព័ត៌មានដែលគាត់ផ្តល់ជូនសាក្សីរូបនេះនោះ គឺថាយកមកតែមួយដុំ កាត់យកមកស្រង់មកអ៊ីចឹង គឺថា យើងបានជំទាស់ជាច្រើនលើក ច្រើនដងមកហើយ គឺថាសុំឲ្យគាត់អានប្រតិចារឹកដើម្បីសុំការបំភ្លឺពីសាក្សី។ ហើយគាត់អានចម្លើយចង់២០បន្ទាត់ទៅហើយ ហើយឲ្យសាក្សីឆ្លើយ។ ដូច្នេះខ្ញុំគិតថាដូចជាមិនមានតម្លៃអីនោះទេនៅពេលដែលគាត់ធ្វើអ៊ីចឹងនោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការងាររបស់លោក!

**សួរដោយលោក ឃើត រេយ៍ន័រ៖**

**ស៖** លោកស្រី ឯក ហេន សំណួរទី១ ថាតើលោកស្រីនៅប្រកាន់យកចម្លើយដែលលោកស្រីឆ្លើយជូនអ្នកស៊ើបអង្កេតដែរឬទេ? ចាស ឬក៏ ទេ?

**លោកស្រី ឯក ហេន៖**

**ឆ៖** ចាស នាងខ្ញុំប្រកាន់ជាប់នូវចម្លើយដែលនាងខ្ញុំបាននិយាយចាស។

[១១:១៥:០៩]

**ស៖** ខ្ញុំសូមសួរលោកស្រីសំណួរមួយចំនួនបន្តទៅទៀត អំពីការរៀនសូត្រដែលដឹកនាំដោយ ខៀវ សំផន។ សំណួរដំបូងថា តើសរុបទាំងអស់មានមនុស្សប៉ុន្មាននាក់បានចូលរួមក្នុងវគ្គរៀនសូត្រនេះ?

**ឆ៖** ចាស វគ្គរៀនសូត្រនៅក្នុងបុរីកីឡាគឺមានចំនួនច្រើនប្រហែលជា ៤ ឬ៥00នាក់ ក្នុងបុរីកីឡាគឺមានចំនួនច្រើនចាស។

**ស៖** សូមអរគុណលោកស្រី។ តើមានអ្នកណាផ្សេងទៀតមកពីរោងចក្រនុំងទៅរៀនសូត្រនៅ

វគ្គរៀនសូត្រនេះជាមួយលោកស្រីដែរឬទេ?

**ធ៖** ចាស មានផ្នែកដឹកជញ្ជូនជើងគោក។

**ស៖** អ្នកណាដែលជាអ្នកប្រាប់ឲ្យលោកស្រីទៅរៀនសូត្រហ្នឹង?

**ធ៖** បើនិយាយទៅ ទៅនៅក្នុងក្រុមកងជាមួយ គេសុទ្ធតែចាត់តាំងទៅ។ ឧទាហរណ៍ក្រុមនេះទៅ៥នាក់ ក្រុមនេះទៅ៥នាក់អ៊ីចឹងទៅ។ បូកសរុបទៅគឺបានច្រើន ទៅរៀនសូត្រម្តង ដូរគ្នាចាស។

**ស៖** តាមដែលលោកស្រីដឹង តើមានកម្មករកាត់ដេរដទៃទៀតចូលទៅរៀនវគ្គរៀនសូត្រដទៃទៀតមុនលោកស្រីនោះដែរឬទេ?

**ធ៖** ចាស មាន។ មានវគ្គដូរគ្នាចាស។ គេចេញទៅយើងចូលមក។

**ស៖** នៅក្នុងវគ្គរៀនសូត្រដែលបង្រៀនដោយ ខៀវ សំផន ដែលលោកស្រីចូលរៀនន៎ុង តើវគ្គរៀនសូត្រហ្នឹងមានរយៈពេលប៉ុន្មានថ្ងៃដែល?

**ធ៖** ចាស រៀនតែ១ថ្ងៃទេចាស ព្រឹក ល្ងាចទៅផ្ទះវិញ។

[១១:១៧:៥៣]

**ស៖** តើវគ្គរៀនសូត្រហ្នឹងចាប់ផ្តើមនៅម៉ោងប៉ុន្មាន? ហើយបញ្ចប់នៅម៉ោងប៉ុន្មាន?

**ធ៖** វគ្គរៀនសូត្រចូលរៀននៅម៉ោងប្រាំពីរ ម៉ោងដប់ ឈប់។

**ស៖** សូមលោកស្រីជួយរៀបរាប់បន្តិចថា តើវគ្គរៀនសូត្រហ្នឹងគេបើទូលាយ គេបើកចំហដូចម្តេចដែរ?

**ធ៖** វគ្គរៀនសូត្រគឺបើកចំហទូលាយគឺមានមនុស្សច្រើនកុះករមិនមានគ្នាតិចទេ គឺមានគ្នាច្រើនកុះករ។

**ស៖** តើមានអ្នកណាចាប់ផ្តើមបើកវគ្គហ្នឹងដោយ -- តើវគ្គរៀនសូត្រនេះគេចាប់ផ្តើមបើកវគ្គហ្នឹងដោយរបៀបម៉េចដែរ?

**ធ៖** ចាប់ផ្តើមគឺគាត់ពន្យល់ណែនាំពួកកម្មករទាំងអស់ឲ្យខំប្រឹងធ្វើការដើម្បីជួយប្រទេសជាតិ។

**ស៖** ពេលដែលថា គាត់ហ្នឹង តើមនុស្សប្រុសម្នាក់ដែលលោកស្រីថាគាត់ហ្នឹង តើជាអ្នកណាដែលលោកស្រីនិយាយសំដៅហ្នឹង?

**ធ៖** នាងខ្ញុំនិយាយសំដៅទៅលើលោកអ៊ំ ខៀវ សំផន ចាស។

**ស៖** តើលោកស្រីត្រូវធ្វើអ្វីនៅក្នុងវគ្គរៀនសូត្រហ្នឹង គេឲ្យលោកស្រីធ្វើអ្វី?

[១១:២០:០៦]

**ឆ៖** វគ្គរៀនសូត្រគឺមានតែអង្គុយស្ដាប់គាត់និយាយលើកឡើងពីការតស៊ូ ពីការធ្វើការងារ ពួកនាងខ្ញុំអង្គុយស្ដាប់គាត់ចាស។

**ស៖** ពេលដែលគាត់និយាយអំពីការតស៊ូ តើគាត់និយាយស្អីខ្លះអំពីការតស៊ូហ្នឹង? តស៊ូជាមួយអ្នកណា? តស៊ូដើម្បីអ្វី?

**ឆ៖** តស៊ូគឺមិនមែនដើម្បីអ្នកណាទេ គឺដើម្បីខំប្រឹងធ្វើការ តស៊ូអត់ធ្មត់ ខំប្រឹងធ្វើការឲ្យទាន់ផែនការ ប្រៀបធៀនទៅនឹងប្រជាជនជំនាន់នុំុង គឺប្រជាជនគាត់ធ្វើស្រែបាន១ហិកតា ៣តោន។ ចំណែកយើងជាកម្មករក៏ខំប្រឹងឲ្យប្រៀបធៀបស្មើគ្នាដែរ គាត់ឲ្យខំប្រឹងដូច្នេះទេចាស។

**ស៖** នៅពេល ខៀវ សំផន និយាយហ្នឹង តើលោកស្រីគ្រាន់តែអង្គុយស្ដាប់ ឬក៏លោកស្រីកត់ត្រា ឬក៏មានអ្នកណាគេកត់ត្រានូវអ្វីដែលគាត់និយាយហ្នឹង?

**ឆ៖** រៀនជំនាន់នុំុងគឺ គេអ្នកចេះគេកត់ទុកទៅ ចំណែកអ្នកមិនចេះៗតែអង្គុយស្ដាប់ទៅចាស។ ភាគច្រើនគឺអត់សូវចេះ អ្នកចេះភាគតិចណាស់ ព្រោះអត់បានរៀនជំនាន់នុំុង នៅស្រែចម្ការ សង្គ្រាមមកគឺនៅស្ទើរណាស់ គឺរៀនអត់បានជ្រៅជ្រះទេ។

**ស៖** តើ ខៀវ សំផន គ្រាន់តែនិយាយចេញពីមាត់គាត់ ឬក៏គាត់មានប្រើប្រាស់ឯកសារអីដើម្បីបង្រៀនដែរ?

[១១:២២:២៨]

**ឆ៖** ដូចជាមិនមានឯកសារអ្វីសំខាន់ផង។ គាត់និយាយតែរឿងការងារ ឲ្យប្រឹងតស៊ូសាមគ្គីស្រលាញ់គ្នា ចេះរាប់អានគ្នា ជួយគ្នាណ៎ា។ គាត់មានយោបល់គឺល្អៗដែរចាស។ មិនមាននាំឲ្យយើងអីមានទំនាន់ទាស់ទែងគ្នាអី គាត់ឲ្យចេះសាមគ្គីគ្នាអីចឹងក្នុងក្រុម ក្នុងកងអីចឹងឲ្យជួយគ្នា ពលកម្មដើម្បីស្ដារសេដ្ឋកិច្ចប្រទេសជាតិ។ យើងកំពុងតែកើតពី -- រួចពីសង្គ្រាមនុះណ៎ា។

**ស៖** ក្នុងពេលរៀនសូត្រហ្នឹង តើលោកស្រីដឹងថា ខៀវ សំផន និយាយអស់រយៈពេលប៉ុន្មានម៉ោងដែរ?

**ឆ៖** បើនិយាយទៅ និយាយគឺមិនចាប់អារម្មណ៍ពីរឿងពេលម៉ោង គឺមួយស្របក់អីចឹងទៅឈប់សម្រាកអីចឹងទៅ អង្គុយអស់ចិត្តទៅ ចូលមួយសាទៀតអីចឹងទៅ ដល់ពេល ដល់ម៉ោងទៅហូបបាយហើយចាស។

**ស៖** ខ្ញុំសូមបញ្ជាក់ គឺមានវគ្គរៀនសូត្រដែល ខៀវ សំផន គាត់បង្រៀន គឺមានពេលឈប់សម្រាក បន្ទាប់ពីសម្រាក គាត់បន្តបង្រៀនតទៅទៀត ហើយបន្ទាប់មកឈប់សម្រាកពិសាបាយថ្ងៃត្រង់អ៊ីចឹងទេ?

**ផ៖** ចាស។

**ស៖** ចុះបន្ទាប់ពីបាយថ្ងៃត្រង់ហើយ តើគាត់ត្រូវបន្តនិយាយបង្រៀនតទៅទៀត ហើយឬក៏យ៉ាងម៉េច?

[១១:២៤:៣១]

**ផ៖** បន្ទាប់ពីបាយហើយ ចូលធ្វើការវិញ គឺគាត់ទៅកន្លែងគាត់បាត់ហើយ តែពួកនាងខ្ញុំដែលនៅគឺចែកជាក្រុមប្រជុំតាមក្រុមផ្សេងៗគ្នា។

**ស៖** នៅពេលដែលត្រូវបំបែកជាក្រុមតូចៗពិភាក្សា តើមានអ្នកដឹកនាំការពិភាក្សានេះដែរឬទេ ឬក៏មានតែកម្មករចែកជាក្រុមហើយ ចេះតែនាំគ្នាឯងនិយាយទៅ?

**ផ៖** ជំនាន់នោះ គឺចាត់តាំងជាក្រុម។ មានប្រធានក្រុមអ៊ីចឹងនាំប្រជុំ គេហៅថាប្រជុំឆ្លងជីវទស្សន៍ណា។ ជីវទស្សន៍ហ្នឹង គឺប្រជុំជាក្រុម លើកពាក់ព័ន្ធខ្លួនឯងចាស។

**ស៖** កម្មករដែលចូលរៀនសូត្រនៅក្នុងថ្ងៃហ្នឹង តើអង្គភាពណា ឬក៏ការិយាល័យមន្ទីរណាដែលកម្មករហ្នឹងគាត់មក? គាត់មកពីអង្គភាពណា?

**ផ៖** មករៀននៅបុរីកីឡាហ្នឹង? គឺមានអង្គភាពកាត់ដេរ ប្រជុំដោយកន្លែងកាត់ដេរទៅ ដឹកជញ្ជូនជើងគោក គឺទៅដោយកន្លែងគេដឹកជញ្ជូនជើងគោកទៅចាស។ ផ្នែកផ្សេងគ្នា។

**ស៖** នៅក្នុងវគ្គរៀនសូត្រដែល ខៀវ សំផន គាត់បង្រៀនហ្នឹង គាត់មាននិយាយស្អីអំពីខ្មាំងដែរឬទេ?

**ផ៖** ដូចអត់មានឮនិយាយអីផង។ គាត់និយាយអំពីរឿងថា តស៊ូធ្វើការដើម្បីស្តារសេដ្ឋកិច្ចប្រទេសខ្មែរ តែប៉ុណ្ណឹង។ ឲ្យចេះរួបរួមគ្នាតែប៉ុណ្ណឹង ចាស។

[១១:២៦:៥៦]

**ស៖** សំណួររបស់ខ្ញុំបន្ទាប់ គឺពាក់ព័ន្ធទៅនឹងឈ្មោះ ប៉ង់។ តើ ខៀវ សំផន បាននិយាយថា គេចាប់ខ្លួន ប៉ង់ នៅពេលណាដែរទេ?

**ផ៖** គាត់អត់បានលើកថាថ្ងៃនេះៗផង នាងខ្ញុំគ្រាន់តែបានស្តាប់ថា បច្ចុប្បន្ននេះ ត្រូវគេចាប់ខ្លួន

ឈ្មោះ ប៉ង់ ហ្នឹងទៅបាត់ហើយ ចាស។

**ស៖** នៅពេលគាត់និយាយថា ប៉ង់ ត្រូវគេចាប់ខ្លួនយកទៅបាត់ហើយ ដោយសារថាគាត់ជា ប៉ង់ ជាអ្នកក្បត់ សហការជាមួយយួន ចូលដៃជាមួយយួន។ តើគាត់មាននិយាយលម្អិតថា ប៉ង់ ហ្នឹងចូលដៃជាមួយយួនហ្នឹងដោយរបៀបណាដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ពីព្រោះសំណួររបស់គាត់បានធ្វើឡើងដោយនាំមុខ ចំពោះសាក្សី។ ជាក់ស្តែងសំណួរមុន ក៏ដូចគ្នាដែរ គឺអ្នកស្រីសាក្សី គាត់មិនដែលបាន មិនទាន់បានលើកនិយាយអំពីឈ្មោះ ប៉ង់ ទេ។ ហើយតំណាងសហព្រះរាជអាជ្ញាពីឈ្មោះ ប៉ង់។ ហើយឥឡូវនេះ គាត់លើកអំពីការក្បត់របស់ ប៉ង់ ទៀត ដែលសាក្សីមិនបានឆ្លើយបញ្ជាក់ទាក់ទងទៅនឹងឈ្មោះ ប៉ង់ នេះនៅឡើយ។ ដូច្នេះ ការធ្វើបែបនេះវាជាការនាំមុខឲ្យសាក្សី ជាការផ្តល់ចម្លើយឲ្យសាក្សី ដើម្បីឲ្យសាក្សីឆ្លើយ។ បាទ សូមជំទាស់។ សូមអរគុណ។

[១១:២៨:៥០]

**លោក ឃីត វេយ្យ័ន៌រ៖**

លោកប្រធាន ខ្ញុំបានអានសម្រង់កិច្ចសម្ភាសន៍ស្តាប់ចម្លើយដែលសាក្សី -- បញ្ជាក់ហើយថា គាត់ប្រកាន់យកចម្លើយរបស់គាត់។ គឺឯកសារជាខ្មែរគឺត្រឹមត្រូវហើយ ជាសម្រង់នេះ ខ្ញុំអានចេញពីកំណត់ហេតុស្តាប់ចម្លើយ។ ម្នាក់ៗបានដឹងច្បាស់ហើយ អំពីកំណត់ហេតុនេះ។ ខៀវ សំផន បានលើកនិយាយអំពីបញ្ហាឈ្មោះ ប៉ង់ ដែលគាត់ប្រកាសប្រាប់ថា ប៉ង់ ជាប្រធានមន្ទីរ៨៧០នោះ ត្រូវគេចាប់យកទៅបាត់ហើយ ដោយសារតែគាត់ចូលដៃជើងជាមួយយួន។ ដូច្នេះសំណួររបស់ខ្ញុំងាយទេ គ្រាន់តែសួរបន្ថែមទៅលើកំណត់ហេតុស្តាប់ចម្លើយតែប៉ុណ្ណោះ។ លោកប្រធាន ខ្ញុំអាចបន្តទៅទៀតបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងនៃសេចក្តីជំទាស់មិនត្រឹមត្រូវទេ។ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា ដែលសួរ

លោកស្រីចុងក្រោយអម្បាញ់មិញនេះ!

[១១:២៩:៥៦]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោកស្រី ឯក ហេន ខ្ញុំសូមសួរលោកស្រីម្តងទៀត តើខៀវ សំផន ពិតជាបាននិយាយអ្វីខ្លះនៅពេលដែលគាត់និយាយថា "ប៉ង់ ជាអ្នកក្បត់ចូលដៃជាមួយនឹងយួននោះ"?

**លោកស្រី ឯក ហេន៖**

**ឆ៖** គាត់មិនមាននិយាយអីឲ្យវែងឆ្ងាយផង គាត់ថា "មានឈ្មោះ ប៉ង់ ហ្នឹងក្បត់ តែយើងនៅទាំងអស់គ្នាហ្នឹងយើងកុំក្បត់ យើងត្រូវសាមគ្គីគ្នា ជួយគ្នា"។ គាត់បានលើកឡើងថា "ចង្កឹះមួយអាចកាច់បាក់ តែចង្កឹះមួយបាច់មិនអាចកាច់បាក់ទេ។ យើងត្រូវត្រូវសាមគ្គី មិនអាចបែកបាក់ទេ"។ ចាស បានន័យថាអ៊ីចឹង គាត់លើកឡើងអ៊ីចឹងដែរ។

**ស៖** នៅពេលនោះ តើគេចាត់ទុកថា យួនជាមិត្តរបស់បដិវត្តន៍ ឬក៏គេចាត់ទុកយួនជាខ្មាំងរបស់បដិវត្តន៍នៅពេលនុ៎ង?

**ឆ៖** នៅពេលនុ៎ង គឺយួនអត់មានមិត្តទេ គឺប្រទេសយើងអត់មានយួនទេ គឺមានតែខ្មែរ ចាសមានតែខ្មែរអត់មានយួនទេ។ ព្រោះអីជំនាន់នុ៎ងគឺគាត់បានលើកឡើងអ៊ីចឹងដែរ គាត់ថា "យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន គឺមានតែខ្មែរ ខ្មែរនិងខ្មែរចេះស្រឡាញ់គ្នា" គឺមានអ៊ីចឹង។

[១១:៣១:៥៨]

**ស៖** តើនេះជាពេលទី១ ដែលលោកស្រីបានឮពាក្យថា "ជនក្បត់" ហ្នឹងឬទេ? ថាតើពីរឿង ប៉ង់ ឬអ្នកដទៃទៀត ឬក៏ធ្លាប់បានឮអ្នកណាដទៃទៀតនិយាយពីជនក្បត់ទេ មុនពេលដែលមានវគ្គសិក្សារៀនសូត្រនេះ?

**ឆ៖** ចាស ពីមុនមកគឺមិនដែលឮទេ ទើបនឹងឮពេលនោះហើយ ដែលមានថាក្បត់ចាស។

**ស៖** តើលោក ខៀវ សំផន និយាយថាតើគេយក ប៉ង់ ទៅណាទេ ក្រោយពីគេចាប់ខ្លួនហើយនោះ?

**ឆ៖** គាត់អត់មានលើកឡើងយកទៅណាមកណាផង គាត់អត់មាននិយាយតទៅទៀត ដឹងគ្រាន់ថាយកទៅបាត់ចាស។

**ស៖** លោកស្រីបាននិយាយនៅក្នុងបទសម្ភាសន៍ថា ប៉ង់ បានធ្លាប់មកមើលការងារនៅរោងចក្រ

ខាងដេររបស់លោកស្រី។ តើគាត់ -- តើ ប៉ង់ បានមកមើលការងារនៅរោងចក្ររបស់លោកស្រីហ្នឹងប៉ុន្មានដង?

**ឆ៖** គាត់ចូលមកបានពីរដងដែរ បើតាមខ្ញុំចាំ ខ្ញុំឃើញផ្ទាល់ភ្នែក គាត់មកមើលពីរដងដែរ។

**ស៖** នៅពេលដែល ប៉ង់ មកក្នុងពេលពីរដងនោះ តើថ្នាក់ដឹកនាំខ្ពស់ផ្សេងទៀតមកជាមួយគាត់ទេមកមើលពិនិត្យរោងចក្រកាលនោះ?

[១១:៣៤:០០]

**ឆ៖** ចាស គាត់មកគាត់ជិះឡានគាត់មក។ មកដល់គាត់ចុះ តែកងរយៗនៅតាមកន្លែងកាត់ដេរហ្នឹង គឺចុះទៅទទួលនាំដើរមើលអ្នកដេរអ៊ីចឹងទៅ សម្លៀកបំពាក់ហ្នឹង គាត់ដើរមើលអ៊ីចឹងដែរចាស។

**ស៖** ខ្ញុំនឹងចូលទៅដល់ការមកទស្សនកិច្ចរបស់លោក ខៀវ សំផន នៅរោងចក្រ។ លោកស្រីនិយាយថាគាត់មកបី ឬបួនដង។ នៅពេលដែលគាត់មកនោះ តើអ្នកណាជាអ្នកទទួលលោក ខៀវ សំផន នៅពេលដែលគាត់មកដល់អង្គភាពលោកស្រីនោះ មកមើលនោះ?

**ឆ៖** ពេលគាត់អញ្ជើញមកពួកខ្ញុំកំពុងតែធ្វើការ នាំគ្នាងើប ងើបឡើងទទួលគាត់ហ្នឹង ជួនកាលគាត់មកតែពីរនាក់ក៏មាន ជាមួយតែកុងឡាន គាត់ចុះដើរមើលអ៊ីចឹងទៅ មួយគ្រួសអ៊ីចឹងទៅ គាត់ទៅវិញហើយចាស។

**ស៖** នៅក្នុងរៀបរាប់អំពីហេតុការណ៍មួយដែលថាគាត់មកភ្លក់សម្ល។ តើគាត់បានសុំខ្ចីស្លាបព្រាលោកស្រី ដើម្បីភ្លក់ ឬក៏លោកស្រីហុចជូនទៅគាត់កាលនោះ?

**ឆ៖** ចាស ពេលនោះគាត់មក ពួកនាងខ្ញុំកំពុងតែហូបបាយ។ គាត់មកគាត់ឃើញពួកនាងខ្ញុំហូបបាយអ៊ីចឹង ដូចថាស្និទ្ធស្នាលជាមួយកម្មករ គាត់បាននិយាយលេងអ៊ីចឹង "សម្លឆ្ងាញ់ដែរមើល៍ៗ សុំភ្លក់បន្តិចមើលអ៊ីចឹង"។ គាត់ក៏ភ្លក់ ហើយៗគាត់ក៏សួរថាឆ្ងាញ់ ហើយគាត់សួរយើងថា "ម៉េចឆ្ងាញ់ដែរ?" នាងខ្ញុំក៏ឆ្លើយថា "ឆ្ងាញ់តើអ៊ំ" ថាអ៊ីចេះចាស។

[១១:៣៦:០៥]

**ស៖** តើនៅឆ្ងាយប៉ុន្មាននៅពេលដែលលោកស្រីឃើញគាត់ភ្លក់ស៊ុបនោះ សម្លនោះ។ គាត់នៅជិតឬក៏ចម្ងាយប៉ុនណាពីលោកស្រី?

**ឆ៖** បើនិយាយទៅក្នុងកន្លែងហូបបាយផ្សារអូរឫស្សីហ្នឹងគឺមានតុរៀបដល់ទៅបីជួរ។ មានច្រើនកម្មករចូលទៅហូបបាយ មានច្រើនចាស។ គាត់ចូលទៅកន្លែងហ្នឹងទៅ ជួនកាលតុក្បែរគ្នាហ្នឹងគាត់

ក៏ទៅអើតមើលអ៊ីចឹងទៅ គាត់ទៅភ្លក់ក្បែរនាងខ្ញុំហ្នឹងដែរចាស។

**សៈ** ប៉ុន្តែចង់សួរថា លោកស្រី ហើយនិងគាត់ហ្នឹង ពេលដែលគាត់ភ្លក់ហ្នឹង ភ្លក់សម្លលោកស្រី ហើយនិងគាត់ហ្នឹងជិតគ្នា ឬនៅចម្ងាយប៉ុនណា?

**ឆៈ** បើនិយាយទៅនៅតុក្បែរគ្នា ចាស។

**សៈ** សូមអរគុណ។ ខ្ញុំនឹងចូលទៅដល់ករណីរបស់លោក នួន ជា ហើយខ្ញុំដកស្រង់ពីឯកសារដដែលគឺកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យស៊ើបអង្កេត គឺឯកសារ E3/474, គឺអង់គ្លេស 00205050, បារាំង 00205054, ហើយបារាំង 00172065។ លោកស្រីបាននិយាយអំពី "វគ្គរៀនសូត្រនៅបុរីកីឡា ដែលមានប្រជាជន អ្នកចូលរួមប្រហែលជា ៥០០នាក់ ទាំងកម្មករ ហើយនិងបុគ្គលិកផង។ ខ្លឹមសារនៃវគ្គនោះគឺនិយាយអំពីឲ្យកម្មករប្រឹងប្រែងធ្វើការងារ ប្រសិនបើមានកំហុសអ្វីឲ្យកម្មករកែខ្លួនដោយខ្លួនឯង, ការពារទឹកដីដើម្បីកុំឲ្យយួនឈ្លានពានបាន, អំពីភូមិភាគឧត្តរដែលជាជនក្បត់, អំពីការក្បត់ជាតិរបស់ កុយ ធួន, មិនឲ្យកម្មករចូលរួមក្នុងអំពើក្បត់, ឲ្យស្រឡាញ់ទឹកដីកុំឲ្យសម្លាប់គ្នា, អំពីត្រូវសម្រេចផែនការឲ្យបាន ហើយត្រូវរក្សាការប្រុងប្រយ័ត្ន ហើយគាត់និយាយអំពីការបោសសម្អាតអ្នកដែលជាខ្សែរបស់ កុយ ធួន"។ សូមបញ្ចប់សេចក្តីដកស្រង់។

[១១:៣៨:៥៤]

លោកស្រី ឯក ហេន តើលោកស្រីនៅប្រកាន់អ្វីដែលលោកបានប្រាប់ទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹងដដែលឬទេ?

**ឆៈ** ចាស ខ្ញុំនៅតែចាំពាក្យដដែល ដែលខ្ញុំបាននិយាយ បានឃើញ បានស្តាប់ឮចាស។

**សៈ** នៅក្នុងការសិក្សារៀនសូត្រនេះ ថាតើជាមួយ នួន ជា ហ្នឹងវគ្គសិក្សាហ្នឹងបន្តរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆៈ** រៀនតែមួយថ្ងៃទេចាស។ បើនិយាយទៅថារៀនថា មួយព្រឹកៗហ្នឹងគឺថ្ងៃឡើងគឺបែករៀងខ្លួន ទៅប្រជុំរៀងខ្លួនចាស។

**សៈ** នៅពេលដែល នួន ជា និយាយអំពី កុយ ធួន – អំពីអំពើក្បត់របស់ កុយ ធួន នោះ – តើគាត់បាននិយាយដូចម្តេចខ្លះអំពីអំពើក្បត់របស់ កុយ ធួន នោះ? តើគាត់បាននិយាយអំពីអំពើក្បត់របស់ កុយ ធួន នោះ?

[១១:៤០:១៨]

**ឆ៖** បើនិយាយពីជំនាន់ហ្នឹងនិយាយពីរឿងថាក្បត់អី ដូចអត់មានឮនិយាយថាឈ្មោះនេះ ឈ្មោះនោះអីក្បត់ផង។ ស្រាប់តែថា អើដូចខ្ញុំលើកឡើងពីខាងលើ បាត់ទៅរប៉ុយៗអ៊ីចឹង។ ប៉ុន្តែគាត់លើកឡើងអត់មាននិយាយថាឈ្មោះនេះ ឈ្មោះនោះអីក្បត់ផង។ គាត់គ្រាន់តែលើកឡើងពីការសាមគ្គីគ្នា ចាស។

**ស៖** ពាក្យថាក្បត់ជាតិហ្នឹង មានដល់ទៅបីក្នុងខ្លឹមសារដែលខ្ញុំបានអាន។ លោកស្រីបានប្រាប់ទៅអ្នកស៊ើបអង្កេតថាមានការនិយាយអំពីអំពើក្បត់របស់ភូមិភាគឧត្តរ អំពីអំពើក្បត់របស់ កុយ ធួន ហើយមិនត្រូវឲ្យកម្មករចូលរួមក្នុងអំពើក្បត់នោះទេ។ តើត្រឹមត្រូវដែរឬទេ ឬក៏ការដែលបញ្ជាក់នោះខុស? សូមលោកស្រីបញ្ជាក់។

**ឆ៖** ចាស សំណួរនេះពិតជាត្រឹមត្រូវចាស។ នាងខ្ញុំបាននិយាយដូច្នេះមែនចាស។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីអំពើក្បត់របស់អ្នកដែលនៅភូមិភាគឧត្តរ។ តើលោក នួន ជា បាននិយាយអ្វីខ្លះអំពីរឿងហ្នឹង?

**ឆ៖** បើនិយាយពីភូមិភាគឧត្តរក្បត់ នាងខ្ញុំអត់សូវបានដឹងជាសាវតារស្អីពីខាងភូមិភាគឧត្តរហ្នឹងទេ។ ដូច្នេះនាងខ្ញុំទៅរៀនសូត្រហ្នឹង ក៏គាត់លើកឡើងថា គ្រាន់តែថាភូមិភាគឧត្តរក្បត់ តែមិនដឹងថាអ្នកណា ជាអ្នកណាជាអ្នកក្បត់ ក៏អត់ដឹងដែរ ចាស។

[១១:៤២:២៩]

**ស៖** ដើម្បីឲ្យយើងយល់ច្បាស់នោះ គឺគាត់បាននិយាយអំពីជនក្បត់។ តើគាត់បាននិយាយ ឬមិនបាននិយាយពីឈ្មោះរបស់ កុយ ធួន កាលណោះ?

**ឆ៖** កាលហ្នឹងគាត់ក៏បានលើកឡើងអំពីថា កុយ ឃួន ហ្នឹងក្បត់ តែក្បត់ហ្នឹងមិនដឹងថាជាក្បត់របៀបម៉េចដែរ នាងខ្ញុំក៏អត់ដឹងដែរ គាត់ក៏អត់បានបញ្ជាក់វែកញែកឲ្យពួកខ្ញុំបានដឹងដែរ គ្រាន់តែលើកឡើងថាភូមិភាគឧត្តរក្បត់, កុយ ឃួន ហ្នឹងក្បត់។ ដូច្នេះយើងត្រូវតស៊ូ យើងត្រូវសាមគ្គីគ្នាកុំឲ្យមាន។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចបាទ! លោកតំណាងសហព្រះរាជអាជ្ញាផ្អាកតិចសិន។

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមឲ្យមានការបំភ្លឺ។ ខ្ញុំឮសាក្សីថា កុយ ឃួន មិនមែនកុយ ធួន ទេ។ ដូច្នោះតើសហព្រះរាជអាជ្ញា លោកយល់ដូចម្តេច ឬក៏?

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** តើលោកស្រីដឹងទេនៅពេលនេះ គឺថា កុយ ធួន ក៏មានឈ្មោះថា កុយ ឃួន។ តើលោកស្រីដឹងទេនៅកាលនោះ ឬក៏ដល់ពេលនេះនោះ?

**ឆ៖** កុយ ឃួន។ នាងខ្ញុំក៏ដូចថាស្គាល់ក៏មិនច្បាស់។ ឈ្មោះហ្នឹងក៏មិនច្បាស់ មុខហ្នឹងក៏មិនដែលស្គាល់។ ដូច្នេះឮតែតាមពាក្យសម្ដីដែលគាត់លើកឡើងដែរទេចាស។

[១១:៤៤:២៩]

**ស៖** តើ នួន ជា និយាយដូចម្ដេចថាកុំឲ្យកម្មករហ្នឹងចូលរួមក្នុងអំពើក្បត់នេះ តើលោកស្រីអាចពន្យល់ឲ្យច្បាស់ជាងនោះបន្តិចបានទេបាទ?

**ឆ៖** គាត់ពន្យល់ណែនាំពួកខ្ញុំទាំងអស់គ្នាហ្នឹងថា បើមានខ្សែរយៈតូចតាច យើងដឹងខ្លួន យើងត្រូវកែខ្លួន ហើយបែរមកសាមគ្គីគ្នា កុំទៅតាមគេអ៊ីចឹងទៅ។ គាត់ណែនាំឲ្យហើយក្រែងលោមានខ្សែរយៈអីជាប់ពាក់ព័ន្ធអ៊ីចឹងណ៎ា គឺគាត់បានលើកឡើងអ៊ីចឹង។ យើងកុំពាក់ព័ន្ធជាមួយ យើងត្រូវសាមគ្គីគ្នាស្រលាញ់គ្នាមានតែប៉ុណ្ណឹងចាស។

**ស៖** តើលោក នួន ជា បាននិយាយអ្វីខ្លះអំពីការការពារទឹកដីដើម្បីកុំឲ្យយួនឈ្លានពានបាន។ តើគាត់និយាយអ្វីខ្លះពីរឿងហ្នឹង?

**ឆ៖** គាត់អត់មាននិយាយអីវែងឆ្ងាយផង។ គាត់គ្រាន់តែលើកឡើងថា ត្រូវចេះស្រលាញ់គ្នា ពួតដៃគ្នាសាមគ្គីគ្នាការពារទឹកដី ខ្មែរចេះស្រលាញ់ខ្មែរចាស។ គឺគាត់លើកឡើងអ៊ីចឹង អត់មានថា អូ! ក្បត់ទៅចូលឯណោះទៅចូលឯណោះ អត់មានលើកឡើងទេ អត់ទេ។

**ស៖** តើលោក នួន ជា បាននិយាយអ្វីខ្លះអំពីការបោសសម្អាត អ្នកដែលជាប់ខ្សែជាមួយ កុយ ឃួន ឬ កុយ ធួន ហ្នឹង? ខ្ញុំចង់សួរលោកស្រីថាតើគាត់បាននិយាយអ្វីខ្លះអំពីការបោសសម្អាតហ្នឹង? តើគាត់បានរៀបរាប់ដូចម្ដេចកាលនោះ តើលោកស្រីនៅចាំទេ?

[១១:៤៦:៥៧]

**ឆ៖** បើនិយាយរឿងបោសសម្អាត យើងតូចតាចកម្មករធម្មតា គឺធម្មតាៗ តែអ្នកធំៗដូចជាមានខ្សែរយៈហ្នឹងដូចជាខ្ញុំអត់ដឹងដែរ រឿងខ្សែរយៈអ្នកធំៗ ព្រោះខ្ញុំជាកម្មករតូចតាចមិនអាចដឹងទេ ហើយគាត់ក៏អត់មានបញ្ជាក់ប្រាប់ពួកកម្មករអីដែរចាស។

**ស៖** លោកស្រីនិយាយថា នួន ជា បាននិយាយអំពីការប្រព្រឹត្តកំហុស។ តើនិយាយពីកំហុស

ហ្នឹង គាត់បានពន្យល់ពីអ្វីខ្លះថា ដែលអ្នកណាធ្វើខុសហ្នឹងគេធ្វើអ្វី? គាត់បានពន្យល់ទេ?

[១១:៤៧:៥០]

**ឆ៖** ពេលរៀនសូត្រហើយគឺប្រជុំ។ ប្រជុំជាក្រុម មួយក្រុម១០នាក់ អ៊ីចឹងគេឲ្យយើងហៅថា ឆ្លងជីវទស្សន៍ណ៎ះ ពាក់ព័ន្ធនិយាយលើកឡើងពីខ្លួនឯងពីកំហុសខ្លួនឯង ពីគុណសម្បត្តិ និងគុណវិបត្តិ។ ជំនាន់នោះគឺគេលើកឡើងពីអ៊ីចឹង។ យើងពាក់ព័ន្ធខ្លួនឯងតែម្តង លើកឡើងរាយការណ៍ប្រាប់សមូហភាពឲ្យដឹងថា ខ្លួនខ្ញុំនេះគុណសម្បត្តិវាមានប៉ុនណា គុណវិបត្តិវាមានប៉ុនណា ដូច្នេះយើងដោះស្រាយ។ យើងថាយើងមានវិបត្តិយើងត្រូវដោះស្រាយខ្លួនឯងដើម្បីលុបលាងខ្លួនឯងឲ្យបានស្អាតទាំងអស់គ្នាចាស។

**ស៖** បន្ទាប់ពីវគ្គសិក្សារៀនសូត្រនេះ ដែល នួន ជា -- ជាមួយ នួន ជា នោះថាតើបន្ទាប់មកមានបញ្ហាអីចំពោះកម្មករនៅរោងចក្រទេបើសិនជាអ្នកនោះប្រព្រឹត្តកំហុស ឬក៏អង្គការចាត់ទុកថាគេមនុស្សអាក្រក់នោះ តើលោកស្រីធ្លាប់ជួបឃើញអ៊ីចឹងទេ?

**ឆ៖** ក្រោយពីការរៀនសូត្រប្រជុំឆ្លងជីវទស្សន៍លើកពាក់ព័ន្ធខ្លួនឯងរួច ពួកខ្ញុំបានត្រឡប់មក ដល់ផ្ទះវិញធ្វើការជាធម្មតាចាស។ តែដូចជាមិនឃើញមានជាបញ្ហាអ្វីតទៅទៀតផង។

**ស៖** លោកស្រី ឯក ហេន សូមអរគុណដែលលោកស្រីបានឆ្លើយនូវសំណួររបស់ខ្ញុំ។ ឥឡូវនេះខ្ញុំនឹងផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរលោកស្រីបន្ត។

សូមអរគុណ លោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេនី។ សូមអញ្ជើញ។

[១១:៤៩:៥៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខាងដើមបណ្តឹងរដ្ឋប្បវេណីគឺលោកស្រីមេធាវី ស៊ីន សុវ៉ន និង គ្រីស្ទីន ម៉ាទីណូ នឹងសួរសំណួរមួយចំនួនទៅកាន់សាក្សីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ចាស សូមគោរពលោកប្រធាន។ សូមគោរពលោក លោក

ស្រីចៅក្រម។ សូមគោរពសហភាគា និងជម្រាបសួរផងដែរ លោកស្រី ឯក ហែន។ ខ្ញុំឈ្មោះ ស៊ីន សុវ៉ាន ជាមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ពេលនេះ ខ្ញុំនឹងជម្រាបសួរសំណួរអ្នកស្រីមួយចំនួន ដែលអ្នកស្រីបានដឹង បានឮ និងអ្នកស្រីបានឃើញ ហើយបានជួបប្រទះ និងបានចងចាំនៅក្នុងអំឡុងពេលនោះ។

[១១:៥០:៤២]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ាន៖**

**ស៖** សំណួរដែលខ្ញុំចង់សួរអ្នកស្រី ខ្ញុំចង់ជម្រាបសួរបន្តពីខាងសហព្រះរាជអាជ្ញា។ ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា អ្នកស្រីបានជម្រាបអង្គសវនាការរួចហើយថាពីមុនគឺអ្នកស្រីបានធ្វើការអង្គការគេបានឱ្យអ្នកស្រីទៅកន្លែងចល័ត ហើយគេឱ្យអ្នកស្រីលើកទំនប់ ហើយក្រោយមកទៀតអ្នកស្រីស្ម័គ្រចិត្តចូលទៅកងយុវនារីនៅក្នុងភូមិបូព៌ា។ មែនទេអ្នកស្រី?

**លោកស្រី ឯក ហែន៖**

**ឆ៖** ចាស ពិតមែន។

**ស៖** ចាស អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា ហេតុអីបានអ្នកស្រីស្ម័គ្រចិត្តចូលទៅកងយុវនារី? តើអ្នកចូលហ្នឹង តាមរយៈអ្នកណាដែរ?

**ឆ៖** កាលពីជំនាន់ហ្នឹង នាងខ្ញុំទៅលើកទំនប់។ បើនិយាយទៅមិនមែនថា យើងមានចិត្តតស៊ូអីទេ ប៉ុនថាខ្លួននៅក្មេង នៅក្មេងដល់ពេលហត់នឿយខ្លាំងពេក នឹកឃើញថា អញឈប់លើកទំនប់ហើយ។ អញទៅធ្វើយុវនារី ងាប់ចោលទៅ។ មានគំនិតមួយផ្សេង។ ដល់ហើយ ខ្ញុំទៅមានតែពិបាកអីណា ចូលធ្វើការបម្រើប្រទេសជាតិ ដូចថាមុនដំបូងដឹកជញ្ជូន ដឹកអីអ៊ីចឹងទៅ យូរៗទៅជាយុវនារី ជាទ័ព កងទ័ពយុវនារី។ ខ្ញុំទៅរស់នៅខាងភូមិភាគបូព៌ា ចាស។

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់សួរអ្នកស្រីផ្ដោតទៅលើការដែលអ្នកស្រី មុនដំបូងពេលដែលអ្នកស្រីស្ម័គ្រចិត្តចូលទៅកងយុវនារីនោះ អ្នកណាជាអ្នកប្រាប់អ្នកស្រីថាឱ្យចូលទៅកងយុវនារី? ហើយថាតើនៅក្នុងកងយុវនារីហ្នឹង ដែលអ្នកស្រីថាចូលធ្វើទ័ព អ្នកស្រីដែលទៅសមរភូមិទេ សមរភូមិប្រយុទ្ធទេ?

[១១:៥២:៥២]

**ផ៖** ចាស ជំនាន់នោះ គឺមានគណៈយុវជនភូមិ គេចុះទៅកត់ឈ្មោះតែម្តងនៅតាមទំនប់។ គេសួរអ្នកណាស្ម័គ្រចិត្តទៅយុវនារី គឺគេកត់ឈ្មោះទៅតែម្តង ចាស។

**ស៖** ចាស យុវជនភូមិឈ្មោះអីដែរ អ្នកស្រីអាចប្រាប់ឈ្មោះដល់អង្គសវនាការបានទេអ្នកស្រី?

**ផ៖** យុវជនឃុំ ជំនាន់ហ្នឹង គឺឈ្មោះ អេន ដែលកត់ឈ្មោះនាងខ្ញុំទៅលើទំនប់ហ្នឹង ដល់ក្រោយមក ក៏គាត់ទៅកត់ឈ្មោះ គាត់ដើរតាមទំនប់ហ្នឹង ក៏គាត់ជ្រើសរើសអ្នកស្ម័គ្រចិត្ត។ នាងខ្ញុំក៏ស្ម័គ្រចិត្ត។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំសូមជម្រាបសួរសំណួរអ្នកស្រីបន្ត។ អ្នកស្រីបានចូលទៅកងយុវនារីហ្នឹង បានរយៈពេល៦ខែ។ អ៊ីចឹងមែនទេអ្នកស្រី?

**ផ៖** ចាស អស់រយៈពេល៦ខែ។

**ស៖** ចាស ក្នុងអំឡុងពេល៦ខែហ្នឹង តើអ្នកស្រីបានរៀនវគ្គគោលនយោបាយ ឬក៏វគ្គគោលនយោបាយ ឬក៏វគ្គខ្លីៗអីខ្លះដែរ នៅក្នុងកងយុវនារីហ្នឹង?

[១១:៥៤:២៥]

**ផ៖** ចូលដំបូង នាងខ្ញុំទៅនៅខាងស្រុកកញ្ជៀច។ ស្រុកកញ្ជៀចនៅភូមិស្វាយចេក។ ទៅដំបូងគឺគ្មានបានរៀនសូត្រអីទេ គឺហាត់រៀនតែម្តង ហាត់បាញ់ ដោះកាំភ្លើង ហាត់បាញ់ ហាត់វៃ ហាត់បោកគ្រាប់បែក រៀនសូត្ររយៈពេល៦ខែ ចេះចប់។

**ស៖** អ៊ីចឹងនៅក្នុងយុវនារី អ្នកស្រីរៀនតែវិជ្ជាផ្នែកទ័ពទេ។ អ្នកស្រីអត់បានរៀនផ្នែកបំពាក់បំប៉នគោលនយោបាយបដិវត្តន៍អីៗទេ អ្នកស្រី?

**ផ៖** ចាស អត់ដែលបានរៀនទេ។

**ស៖** ចាស សូមអរគុណ។ អ្នកស្រីបានជម្រាបរួចមកហើយថា អ្នកស្រីធ្វើយុវនារីបាន ៦ខែ ហើយបន្ទាប់មកទៀតអ្នកស្រីត្រូវបានគេបញ្ជូនមកភ្នំពេញ។ ហើយខ្ញុំចង់ជម្រាបសួរថា ហេតុអីបានអ្នកស្រីដឹងថា គេត្រូវបានបញ្ជូនអ្នកស្រីមកភ្នំពេញហ្នឹង? ដោយអ្នកស្រីធ្វើនៅអង្គភាពយុវនារីសុខៗ ហេតុអីបានជាគេបញ្ជូនអ្នកស្រីមកភ្នំពេញហ្នឹង អ្នកស្រីមានដឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ ទំនងជាឆ្ងាយពីអង្គហេតុដែលអង្គជំនុំជម្រះមានបំណងស្តាប់សក្ខីកម្មសាក្សីរូបនេះ។ អង្គជំនុំជម្រះបានជម្រាបព្រឹកមិញហើយ សូមភាគីផ្អែកទៅលើមូលដ្ឋាននៃឯកសារជាសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា សុំបន្ថែមការស្តាប់សក្ខីកម្មសាក្សីចុងបញ្ចប់នៃសំណុំរឿង

០០២/០១។ គោលបំណងនៃការស្តាប់នេះគឺ បញ្ជាក់អំពីតួនាទីរបស់ជនជាប់ចោទ នួន ជា, ខៀវ សំផន ហើយនិងអាច/ឬពាក់ព័ន្ធជាមួយនឹងអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម ដែលគេមានចង្អុលបង្ហាញនៅក្នុងផ្នែកខ្លះនៃកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីរូបនេះនៅចំពោះមុខការិយាល័យ -- ចំពោះអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដូចជាទំនងពាក់ព័ន្ធនឹងទំព័រចុងក្រោយ។

[១១:៥៦:៣៧]

ហើយសំណួរប៉ុន្មានសំណួរនេះគឺជាសំណួរច្រំដែល ដែលអង្គជំនុំជម្រះទំនងជាមិនត្រូវការស្តាប់ទេ មិនមានផលប្រយោជន៍អ្វីដែលអង្គជំនុំជម្រះយកទៅវិភាគ ជជែក ពិចារណា ពិនិត្យភស្តុតាងសម្រេចលើបញ្ហាហ្នឹងទេ។ សូមលោកស្រីប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាពនៅសល់ពេលវេលាតិចណាស់។ ពេលវេលាតិចហើយ ប្រើប្រាស់ពេលវេលាទំនងជាមិនចំគោលដៅ ឬក៏វត្ថុបំណងនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះនៅក្នុងដំណាក់កាលនេះឡើយ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន ខ្ញុំនឹងដូរសំណួរ។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស ខ្ញុំជម្រាបសួរអ្នកស្រីបន្តទៀត។ អ្នកស្រីបានជម្រាបអង្គសវនាការរួចហើយថាអ្នកស្រីបានឃើញគេចាប់ឈ្មោះ កែវ ហើយឈ្មោះ គុន។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរថា ក្រៅពីដែលអ្នកស្រីបានឃើញដែលគេចាប់ឈ្មោះ កែវ និងឈ្មោះ គុន តើមានអ្នកណាខ្លះដែលអ្នកស្រីបានៗស្គាល់ហ្នឹងក្រៅពីឈ្មោះ កែវ ហើយឈ្មោះ គុន ហ្នឹង?

**លោកស្រី ឯក ហេន៖**

**ឆ៖** ក្រៅពីឈ្មោះ កែវ និង គុន ហ្នឹង គឺ មានពីរនាក់ទៀតដែលត្រូវគេយកទៅហ្នឹងគឺមានឈ្មោះ មួយឈ្មោះ ថន។ មួយទៀតឈ្មោះ -- ភ្លេចឈ្មោះបាត់ទៅហើយ។ ការចងចាំវាយូរដែរទៅហើយណ៎ា បើនិយាយទៅថាបួននាក់ទៅចុះបានឃើញបាត់ខ្លួនចាស។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹងការដែលគេចាប់ខ្លួនឈ្មោះ កែវ, ឈ្មោះ គុន, ឈ្មោះ ថន ហើយនិងម្នាក់ទៀតដែលអ្នកស្រីមិនស្គាល់ហ្នឹង ខ្ញុំចង់ជម្រាបសួរថា ភាគច្រើនគេចាប់ខ្លួន គេចាប់នៅពេលណាដែរ? នៅពេលយប់ ឬក៏ពេលថ្ងៃ ឬក៏ពេលជិតភ្លឺ? អ្នកស្រីអាចចងចាំបានទេចាស?

[១១:៥៨:៤៤]

**ផ៖** នាងខ្ញុំពិតជាចងចាំបាន។ នាងខ្ញុំកំពុងតែធ្វើការកន្លែងដេរគឺប្រហែលជាម៉ោងប្រាំបួន ឡានមកដល់ឈប់ ឃើញ មើលឃើញអ៊ីចឹងដែរ តែមិនដឹងថាមកពីខាងណា ហើយក៏មិនស្គាល់ ហើយក៏មិនដឹងយកទៅខាងណាដែរចាស គ្រាន់តែថាបានឃើញ។

**ស៖** ចាស សូមអរគុណ។ ឯកសារដែលអ្នកស្រីបានចូលរួមសួរដោយសហចៅក្រមស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ D3/474, ERN ជាភាសាខ្មែរ 00172064, ERN ជាភាសាអង់គ្លេស 00205049 និង ERN ជាភាសាបារាំង 00205053។ ត្រង់ចម្លើយ -- ត្រង់សំណួរដែលៗសហចៅក្រមស៊ើបអង្កេតសួរអ្នកស្រីថា "តើនៅក្នុងអង្គភាពរបស់អ៊ំមានការបាត់ខ្លួនដែរឬទេ?" ហើយអ្នកស្រីបានឆ្លើយថា "ខ្ញុំឃើញមានការបាត់ខ្លួនមនុស្សឡើងឡានឃ្លុបបិទជិត ដោយកងទ័ពមានអាវុធ។ ដំបូងគេចាប់មេៗ បន្ទាប់មកគេចាប់អនុ និងសមាជិកដែលមានការពាក់ព័ន្ធនឹងខ្សែឧត្តរ និងបូព៌ា ដោយគេចោទថាខ្មាំង។ ឈ្មោះ កែវ ដែលជាអនុរោងចក្រត្រូវគេចាប់យកទៅបាត់ក្នុងឆ្នាំ១៩៧៧ ដែលជាប់ខ្សែបូព៌ា ហើយខ្ញុំមិនដែលបានជួបគាត់ទេ ហើយក៏មិនដឹងថាមូលហេតុអ្វីដែរ"។

អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកស្រីថា ហេតុអីលោកស្រីដឹងថាគេចាប់ខ្លួនខ្សែពួកឧត្តរ និងខ្សែបូព៌ា? អ្នកស្រីដឹងដោយវិធីណាដែរចាស?

[១២:០១:០៤]

**ផ៖** ចាស កាលសម័យនុ៎ងគឺមានគេនិយាយតៗគ្នា គឺរឿងជាដូចយើងថាពិត ឬមិនពិតទេណា៎។ និយាយតាមៗគ្នា ដូចថាល្បីថា "ហ្នំ! ភូមិភាគឧត្តរក្បត់គ្នា" អាហ្នឹងគឺអ៊ីចឹង។ ក្រោយមកគឺមានបាត់បន្តបន្ទាប់អ៊ីចឹងដូចខ្ញុំបានលើកឡើងអ៊ីចឹង តែខ្ញុំមិនដឹងថាមកពីខាងណា ឬយកទៅខាងណា ហើយឲ្យស្គាល់គេក៏អត់ស្គាល់ដែរ គ្រាន់តែបានឃើញ។ ចាស គ្រាន់តែប៉ុណ្ណឹង។

**ស៖** ចាស សូមអរគុណ។ តើលោកស្រីដែលធ្លាប់ឮថា ឮពាក្យថា "ខ្មាំង" ទេក្នុងសម័យហ្នឹង?

**ផ៖** ក្នុងសម័យហ្នឹងដូចជាមិនមានខ្មាំងឯណាផង មិនដែលឮផងចាស។

**ស៖** ចាស សូមអរគុណ។ កំណត់ហេតុយកចម្លើយដោយសហចៅក្រមស៊ើបអង្កេត គឺឯកសារដដែលគឺ E3/474 ហើយ ERN ជាភាសាខ្មែរ 00172065, ERN ជាភាសាអង់គ្លេស 00205050 និង ERN ជាភាសាបារាំង 00205054។ ត្រង់ចំណុចមួយដែលលោកស្រីបាននិយាយថា "លោក នួន ជា ធ្លាប់ដឹកនាំប្រជុំរៀនសូត្រនៅបុរីកីឡាដែរនៅឆ្នាំ១៩៧៨ ដែលមានអ្នកចូលរួមប្រហែល៥០០នាក់។ មានបុគ្គលិក កម្មករ។ ឯខ្លឹមសារប្រជុំរៀនសូត្រនិយាយពីបញ្ហាឲ្យកម្មករខំធ្វើការ បើមានកំហុសកម្មករ

កែខ្លួន កែប្រែខ្លួន ការពារទឹកដីកុំឲ្យឃ្លួនឈ្លានពាន លើកពីបញ្ហាភូមិភាគឧត្តរក្បត់ កុំឲ្យកម្មករចូលរួមក្បត់។ លើសពីនេះ -- លើកពីឈ្មោះ កុយ ធួន ដែលក្បត់ ឲ្យកម្មករចេះស្រឡាញ់ទឹកដី កុំកាប់ចាក់គ្នា។ ខំធ្វើការឲ្យទាន់ផែនការ ចេះសន្សំសំចៃ ហើយគាត់ប្រាប់ពីការបោសសម្អាតអ្នកជាប់ខ្សែ កុយ ធួន"។ ខ្ញុំចង់សម្រាបសួរអ្នកស្រីនៅក្នុងវគ្គនេះ ពាក្យដែលអ្នកស្រីថា "ធ្វើការឲ្យទាន់ផែនការ" ហ្នឹង តើអ្នកស្រីដឹងទេថា បើកម្មករនៅក្នុងអង្គភាពហ្នឹងធ្វើការមិនទាន់ផែនការ តើមានបញ្ហាអ្វីកើតឡើងចំពោះគាត់ទេ?

[១២:០៤:១៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ពីព្រោះវាជាសំណួរឧបមានវិធីដែលសួរឲ្យសាក្សីវែស្មាន។ ថាបើសិនជាអំពើណាមួយយ៉ាងម៉េចៗអីចេះ។ ខ្ញុំសូមជំទាស់។ សូមអរគុណ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណ។ សូមគោរពលោកប្រធាន ចំពោះសំណួរនេះដោយសារនាងខ្ញុំសួរពាក់ព័ន្ធនឹងសំណួរនេះ ដោយសារចម្លើយរបស់អ្នកស្រី គាត់បាននិយាយច្បាស់ហើយថា លោក នួន ជា គាត់បានបញ្ជាក់ឲ្យកម្មករហ្នឹងធ្វើការឲ្យទាន់តាមផែនការ។ ហើយខ្ញុំចង់ជម្រាបសួរថាចុះបើក្នុងអង្គភាពរបស់អ្នកស្រី បើក្នុងនោះមានកម្មករណាមួយធ្វើការមិនទាន់ផែនការ តើអ្នកស្រីដែលឃើញកម្មករហ្នឹងទទួលហេតុការណ៍អីទេ?

[១២:០៥:១៦]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ត្រឹមត្រូវ។ ជាសំណួរឧបមានវិធី មិនត្រឹមត្រូវទេ។ អ៊ីចឹងសាក្សីមិនបាច់ឆ្លើយតបសំណួរបែបនេះទេ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ចាស ខ្ញុំមានសំណួរចុងក្រោយ។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា ចាប់តាំងពីអ្នកស្រីមកធ្វើការនៅភ្នំពេញក្នុងឆ្នាំ៧៦ រហូតដល់ឆ្នាំ១៩៧៩ ពេលដែលយួនវាយបែក ខ្ញុំចង់ជម្រាបសួរថាក្នុងអំឡុងពេលហ្នឹងអ្នកស្រីដែលបានទៅលេងស្រុកកំណើតអ្នកស្រីទេ?

**លោកស្រី ឯក ហេន៖**

**ឆ៖** តាំងពី -- និយាយរួមតាំងពីចេញពីផ្ទះមក តាំងពី៧៤ នាងខ្ញុំមិនដែលបានវិលទៅផ្ទះទេ។ នាងខ្ញុំមក មករហូត។ រហូតដល់ឆ្នាំ៧៩ ថ្ងៃ០៧ មករា នាងខ្ញុំបានត្រូវគេជម្លៀសចេញទៅនៅជាយដែនខាងលិច។ ខ្ញុំទៅនៅជំរំ រហូតទៅដល់ជំរំស្រះកែវ ចាស។

[១២:០៦:២៩]

**ស៖** ចាស សូមអរគុណ។ អ្នកស្រីមានដឹងថាមូលហេតុអីបានគេមិនឲ្យអ្នកស្រីទៅលេងផ្ទះសម្បែងហ្នឹង ដោយអ្នកអ្នកស្រីមកធ្វើការយូរហើយ អ្នកស្រីមិនដែលបានទៅលេងផ្ទះសម្បែងសោះ។ អ្នកស្រីមានដឹងពីមូលហេតុហ្នឹងទេ?

**ឆ៖** មូលហេតុនេះគឺខ្ញុំអត់បានដឹងដែរ គ្រាន់តែថាតាំងពីមក គឺមិនដែលមកលេងផ្ទះ។ ដឹងតែប៉ុណ្ណឹង។ បើគេអត់ឲ្យទៅ យើងក៏អត់ទៅដែរ ទៅនៅទៅ ចាស។

**ស៖** ចុះបើយើងទៅម៉េចដែរអ្នកស្រី? អ្នកស្រីថា--

**ប្រធានអង្គជំនុំ៖**

មិនបាច់ៗឆ្លើយទេ។ គោលបំណងនៃការសួរហ្នឹង គោលបំណងចង់បានអី? ឲ្យអង្គជំនុំជម្រះស្តាប់ដើម្បីប្រយោជន៍យកចម្លើយពីសក្ខីកម្មសាក្សីនេះយកទៅពិចារណាលើអង្គហេតុណាមួយ លោកស្រីមេធាវីអាចពន្យល់បានទេ ដែលពាក់ព័ន្ធនឹងអង្គហេតុកំណត់ឲ្យធ្វើ -- អង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការនេះ?

[១២:០៧:២៨]

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស អរគុណលោកប្រធាន ខ្ញុំនឹងដូរសំណួរ។

**ប្រធានអង្គជំនុំ៖**

តើចំណាយពេលវេលាប៉ុន្មានទៀត?

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** លោកស្រីរៀបការក្នុងឆ្នាំណាដែរលោកស្រី?

**ឆ៖** ប្រាំបួនរយ-- អ៎! នៅឆ្នាំ១៩៧៩ ជិតចូលឆ្នាំ៨០ទៅហើយចាស។

**ស៖** ចាសសូមអរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរអ្នកស្រីក្នុងអំឡុងពេលដែលអ្នកស្រីធ្វើការនៅអង្គភាពកាត់ដេរមជ្ឈិមពីឆ្នាំ៧៦ រហូតមកដល់ឆ្នាំ៧៩ហ្នឹង។ ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា តើនៅក្នុងអង្គភាពអ្នកស្រីហ្នឹងមានដែលមានយុវនារីណាដែលត្រូវបានអង្គការគេឲ្យរៀបការដែរ អ្នកស្រី?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្ដី!

[១២:០៨:៣៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា សំណួរនេះវាអត់មានអីពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង០០២/០១ របស់យើងនេះទេ។ ហើយម្យ៉ាងទៀត ខ្ញុំក្រលេកឃើញថាពេលវេលាគឺអស់ទៅហើយ។ ហើយលោកប្រធានក៏បានបញ្ជាក់ដែរថា មិនអាចបន្ថែមពេលវេលាទៀតទេ។ ដូច្នេះសូមលោកប្រធានអធ្យាស្រ័យ ហើយពិនិត្យ។ បាទ សូមអរគុណ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាសសូមអរគុណ។ សំណួរដែលខ្ញុំសួរពាក់ព័ន្ធនឹងការរៀបការនេះ ពីព្រោះការរៀបការក៏វាស្ថិតនៅក្នុងគោលនយោបាយរបស់អង្គការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរចាស។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ!

[១២:០៩:២៦]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ លោកប្រធាន ខ្ញុំមិនដឹងថាលោកប្រធានអនុញ្ញាតឲ្យខ្ញុំចោទសំណួរទៅកាន់សាក្សីនេះមួយចំនួនតូចតែប៉ុណ្ណោះមុនពេលសម្រាក ឬក៏

ចង់ឲ្យខ្ញុំសួរពេលចូល ក្រោយពេលសម្រាកនេះវិញ ពិសាបាយហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ផ្តល់ឱកាសឥឡូវនេះ ប៉ុន្តែសូមសួរឲ្យខ្លីបានហើយ។ ហើយសូមប្រើប្រាស់ពេលវេលាផ្សេងដេញដោលដែលចែកឲ្យ ឲ្យមានប្រសិទ្ធភាព។ សំខាន់គឺចំអង្គហេតុ ដើម្បីជាប្រយោជន៍សម្រាប់អង្គជំនុំជម្រះយកទៅពិចារណាក្នុងការសម្រេចសេចក្តី។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធានខ្ញុំនឹងព្យាយាមសួរដោយខ្លីៗដោយសារសំណួរបានចោទច្រើនមកហើយ។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** លោកស្រីសាក្សីខ្ញុំសូមធ្វើការសួរឲ្យលោកស្រីជួយសង្ខេបបន្តិចទាក់ទងនឹងការរៀនសូត្ររបស់លោកស្រី។ លោកស្រីនិយាយថា លោកស្រីបានទទួលការអប់រំរៀនសូត្រពីលោក ខៀវ សំផន ហើយនិងពីលោក នួន ជា ផងដែរ ហើយលោកស្រីបានឆ្លើយទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា -- ខ្ញុំអាចផ្តល់លេខ ERNបាន គឺ00795296 ជាភាសាបារាំង, អង់គ្លេសគឺ 00662015, ជាភាសាខ្មែរគឺ 00019582។ លោកស្រីបានជម្រាបថា ប៉ង់ ពីមន្ទីរ ម-៨៧០ ជាគ្រូបង្រៀនដែរហើយគាត់ក៏បានផ្តល់ការបណ្តុះបណ្តាលដល់លោកស្រីផងដែរ អម្បាញ់មិញនេះខ្ញុំមិនបានឮលោកស្រីនិយាយអំពីមុខងាររបស់ ប៉ង់ នេះទេ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើ ប៉ង់ នេះគាត់ផ្តល់ការអប់រំរៀនសូត្រដល់កម្មករគេគ្រប់គ្នាហ្នឹងនៅពេលណាដែរក្នុងកាលៈទេសៈណាដែរ?

[១២:១១:៥៥]

**លោកស្រី ឯក ហេន៖**

**ឆ៖** ខ្ញុំបានលើកឡើងហើយឈ្មោះ ប៉ង់ នេះអត់ដែលបានទៅរៀនទេ។ ខ្ញុំបានទៅរៀនជាមួយលោកអ៊ំ នួន ជា, លោកអ៊ំ ខៀវ សំផន ចាស។ ឯឈ្មោះ ប៉ង់ នេះ លោកអ៊ំបានលើកវ៉ាយរាប់ប្រាប់នាងខ្ញុំទេ បាននាងខ្ញុំដឹងចាស។

**ស៖** ខ្ញុំប្រហែលជាមានការបកប្រែខុសជាភាសាបារាំងហើយមើលទៅ។ ប៉ុន្តែលោកស្រីខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វីដែលកើតឡើងនៅពេលដែលលោក ខៀវ សំផន មកក្នុងរោងចក្ររបស់លោកស្រីដើម្បីធ្វើការត្រួតពិនិត្យក្រៅពីភ្លក់ម្ហូបនោះ តើលោក ខៀវ សំផន មានបានទៅត្រួតពិនិត្យមើលលក្ខខណ្ឌការងារដែរឬទេ ? ឧទាហរណ៍ដូចជាម៉ោងចូល ម៉ោងចេញធ្វើការងារ ហើយនិងរបៀបធ្វើការ

នៅកន្លែងលោកស្រីនុ៎ង តើគាត់មានបានចូលទៅមើលក្នុងកន្លែងរោងជាងអីទេ ត្រួតពិនិត្យពីលក្ខខណ្ឌការងារជាដើម?

**ឆ៖** បើនិយាយទៅមុខទិសដៅរបស់គាត់មកចំត្រង់ហ្នឹងគាត់ឆៀងចូលមួយភ្លែតទៅ។ ទៅមើលទៅកម្មករហ្នឹង ទៅវិលត្រឡប់ទៅវិញទៅគាត់គ្មាននៅយូរទេចាស។

**សៈ** តើកម្មករ កម្មការិនី ដូចជាលោកស្រី និងអ្នកដទៃទៀតហ្នឹងមានអ្នកតំណាងទេ ក្រៅពីមេកងមេក្រុមរបស់លោកស្រី មានអ្នកតំណាងទេ? សូមឆ្លើយនូវសំណួរទី១ ខ្ញុំនេះសិន។

[១២:១៤:០០]

**ឆ៖** ចាសក្នុងអង្គភាពកាត់ដេរមាន១៧កង។ កងទី១ រហូតដល់កងទី១៧ សុទ្ធតែយុទ្ធនារី។ នារីចម្រុះមានមកពីបូព៌ា ឧត្តរ មានតែពីរភូមិភាគទេ អត់តែនិរតីទេចាស។ ភូមិភាគបូព៌ា និងឧត្តរចម្រុះចូលគ្នាភាគច្រើន ភូមិភាគឧត្តរ។ បូព៌ាមានចំនួនប្រហែលជា ១០០នាក់ប៉ុណ្ណោះទេ។ ពួកខ្ញុំជាយុទ្ធនារីមកច្រឡូកជាមួយគេតែ១០០នាក់ប៉ុណ្ណោះទេ បើនិយាយទៅ១៧កងហ្នឹងសុទ្ធសាច់តែនៅភូមិភាគឧត្តរទាំងអស់។ នៅរស់តាមកង ក្នុងមួយកងវាមានបីក្រុមចាស។ នៅតាមក្រុម តាមកងរហូតដល់កងទី១៧ អ៊ីចឹងទៅតាមផ្ទះរៀងៗខ្លួន។ ការងារមានកន្លែងធ្វើរៀងខ្លួនចាស។ មាន មិនមែនថានៅជាសេរីចូលគ្នាបាន អត់ទេ នៅតាមកង តាមក្រុម ចាស។

**សៈ** លោកស្រីមិនបានឆ្លើយតបនឹងសំណួរខ្ញុំឱ្យបានត្រឹមត្រូវទេ។ ខ្ញុំចង់ដឹងថាតើមានអ្នកតំណាងកម្មករ កម្មនារីដែរឬទេ? ឥឡូវសំណួរមួយទៀត នៅពេលដែលលោក ខៀវ សំផន ហើយមេដឹកនាំផ្សេងទៀតមកត្រួតពិនិត្យរោងចក្រហ្នឹង តើកម្មករ កម្មការី មានលទ្ធភាពក្នុងការជូនពរដល់ពួកគាត់ ឬក៏ -- មិនមែនទេធ្វើសំណើ -- គាត់ធ្វើជាសំណើ ឬក៏រិះគន់ដល់លក្ខខណ្ឌការងារនៅកន្លែងរោងចក្រហ្នឹងទេដែលធ្លាប់មានទេរឿងហ្នឹង?

[១២:១៦:០០]

**ឆ៖** ចាស គាត់ចូលមក ដូចមិនមានជាសំណើអីផង។ គាត់គ្រាន់ថា ខំធ្វើការទាំងអស់គ្នា មានកម្លាំងចិត្តធ្វើការឱ្យរីកចម្រើន។ គាត់មានតែលើកដៃប្រាប់កូនចៅ អ្នកកម្មករហ្នឹងថា "ខំស្រឡាញ់គ្នាជួយការងារគ្នាឱ្យរីកចម្រើន ជួយប្រជាជន កាត់ដេរជូនប្រជាជនខាងណោះ ជូនទៅខាងណោះគ្រប់ទីកន្លែង"។ គឺកាត់ដេរកន្លែងហ្នឹងគឺមានតែមួយកន្លែងមួយទេ គឺបញ្ជូនជនបទ។ គាត់អត់មានសំណើរិះគន់អី អត់មានទេ។ គាត់មានតែជួយកម្លាំងចិត្ត បើនិយាយទៅ។

**ស៖** បើក្រោយពីពួកគាត់មកមើលនោះ តើការលក្ខខណ្ឌការងារ ហើយនិងរបបអាហារហ្នឹង ប្រសើរឡើងទេ ក្រោយពីគាត់មកត្រួតពិនិត្យហើយហ្នឹង? ព្រោះថាគាត់មកហ្នឹង ដើម្បីលើកទឹកចិត្ត លោកស្រី និងអ្នកផ្សេងទៀតនោះ ព្រោះថាលោកស្រីនិយាយថា ការងារហ្នឹងធ្ងន់ធ្ងរអស់កម្លាំងខ្លាំង ណាស់។ អ៊ីចឹងមានការធ្វើឲ្យលក្ខខណ្ឌការងារហ្នឹងប្រសើរឡើងទេ ក្រោយពីពេលគាត់មកពិនិត្យហើយ?

**ឆ៖** ចាស ពេលគាត់ចូលមកពិនិត្យអ៊ីចឹង ក្រោយមកអាហារហូបចុកក៏គ្រប់គ្រាន់។ បាយ -- បើនិយាយទៅយើងហូបអត់អស់ទេ បាយ។ សម្លធ្លាញ់ បើនិយាយទៅចាត់ចែងកន្លែងចិញ្ចឹមសត្វ ចិញ្ចឹម ជ្រូក ហើយតាមកងហ្នឹងដាំបន្លែ ឧបត្ថម្ភក្នុងអង្គភាពហ្នឹង ក្នុង១ថ្ងៃកាត់បន្លែបានពីរកងអ៊ីចឹងទៅ រួចមួយ ថ្ងៃ។ ដាំបន្លែបានកើត ឧបត្ថម្ភក្នុងអង្គភាពហ្នឹង។ ចុះជំនាន់ហ្នឹង យើងមិនអាចមានផ្សារផ្សោអីណា យើងទៅទេ អត់មានទេ។ ដូច្នេះ យើងឧបត្ថម្ភខ្លួនឯង។ ដាំខ្លួនឯង បេះមកយកទៅឲ្យចង្រ្កានចុងភៅទៅ ស្លមកឲ្យយើងហូបវិញ។ ដូច្នេះ វាជាការឧបត្ថម្ភខ្លួនឯងទេ។

[១២:១៨:២៦]

**ប្រធានអង្គជំនុំ៖**

អស់សំណួរទៅលោកស្រីមេធាវី អស់ពេលហើយ។ ២០នាទីឲ្យអស់។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូនិយាយ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធាន ខ្ញុំនៅសល់សំណួរមួយ ឬពីរទៀត ដើម្បីបញ្ចប់។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** ខ្ញុំសូមអានសម្រង់ទៅលោកស្រីសាក្សី--

**ប្រធានអង្គជំនុំ៖**

បញ្ហាមិនមែនត្រង់តែពីរសំណួរខាតពេលនោះទេ។ បញ្ហាឥឡូវហ្នឹង វាអស់ វីស៊ីឌី ហើយ។ មន្ត្រីរដ្ឋបាលតុលាការ ផ្លាស់ប្តូរវីស៊ីឌី។

[១២:១៩:២៦]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធាន បើសិនជាអស់ស៊ីឌីហើយ ខ្ញុំឈប់ត្រឹមហ្នឹងតែម្តងទៅ ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ បើយល់បញ្ហា យល់ស្ថានការណ៍ដូច្នេះ។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬកន្លែងណាមួយសមស្របនៅក្នុងបរិវេណនៃ អ.វ.ត.ក យើងនេះដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅរសៀលនេះ ឲ្យបាន -- អ៊ំ នៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យខាងបុគ្គលិកខាងផ្នែកសោតទស្សន៍ -- អ៊ំ! បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ។ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:២០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវី សហព្រះរាជអាជ្ញា និងភាគីទាំងអស់។

[១៣:៣៣:៤២]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំមានសំណួរមួយចំនួនតូចទេ លោកស្រីសាក្សី។ ខ្ញុំជាមេធាវីការពារក្តីអន្តរជាតិឲ្យលោក នួន ជា។ ខ្ញុំសូមចាប់ផ្តើមសួរលោកស្រីអំពីមរណភាពរបស់ឪពុកលោកស្រីនៅក្នុងឆ្នាំ១៩៧១។ នៅក្នុងចម្លើយរបស់លោកស្រីជូនទៅអ្នកអង្កេតការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ លោកស្រីនិយាយថា -- នៅទំព័រទី២ ឯកសារ E3/474 -- "គាត់ស្លាប់ដោយការទម្លាក់គ្រាប់បែកពីយន្តហោះ លន់ នល់ តើលោកស្រីចង់ជម្រាបតុលាការឲ្យច្បាស់ទេថា ហេតុការណ៍នោះវាយ៉ាងដូចម្តេចដោយប្រាកដនោះ?

**លោកស្រី ឯក ហេន៖**

**ឆ៖** ខ្ញុំសូមគោរពលោកតុលាការ។ រឿងឧក្រិដ្ឋកម្មមកលើឪពុករបស់ខ្ញុំ នៅស្វាយទាបចាស នៅភូមិស្វាយទាប ពេលនោះនាងខ្ញុំអត់បានឃើញផ្ទាល់ភ្នែកទេ មានបងប្រុសនាងខ្ញុំបានមកប្រាប់ដល់ផ្ទះ គាត់ថា លោកឪពុករបស់ខ្ញុំបានស្លាប់ដោយសារឧប្បត្តិហេតុ គ្រាប់បែកទម្លាក់នៅស្វាយទាប ចំគាត់ស្លាប់តែម្តង។

**ស៖** តើលោកស្រីដឹងដូចម្តេចថា ការទម្លាក់គ្រាប់បែកនោះធ្វើឡើងដោយយន្តហោះរបស់ លន់ នល់ នោះ?

[១៣:៣៥:៣៨]

**ឆ៖** កាលនោះសម័យនោះសង្គ្រាមមានតែខាងរំដោះ និងខាង លន់ នល់។ ខាងរំដោះអត់មានយន្តហោះទេ, ខាង លន់ នល់គឺមានយន្តហោះ។ ដូច្នេះគឺមានពួករំដោះ ឬក៏ទ័ពរំដោះទាហានអីស្នាក់នៅកន្លែងណាហ្នឹងគឺមានខ្សែរយៈ។ ដូច្នេះ គាត់គ្រោះថ្នាក់ដោយសារយន្តហោះ គឺយន្តហោះគឺមកទៅចេញទៅពីភ្នំពេញតែម្តងចាស។

**ស៖** តើលោកស្រីដឹងទេថា មានតែឪពុករបស់លោកស្រីទេដែលគាត់បានស្លាប់ពីការទម្លាក់គ្រាប់បែក? ឬក៏មានអ្នកផ្សេងទៀតស្លាប់ ឬក៏រងរបួសដែរឬទេ?

**ឆ៖** ចាស ពេលនោះខ្ញុំក៏មិនបានសួរគាត់ឲ្យបានវែងឆ្ងាយដែរ។ ដឹងថាមានតែឪពុករបស់ខ្ញុំមួយ តែមានទៀតតែមិនដឹងជាប៉ុន្មាននាក់ក៏មិនដឹងដែរចាស។

**ស៖** តើលោកស្រីបានដឹងទេថា ការទម្លាក់គ្រាប់បែកនោះ ហើយនិងមរណភាពឪពុករបស់លោកស្រីហ្នឹងអាចជាមូលហេតុឲ្យបងប្រុសរបស់ទៅជាចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៧០ ឬក៏៧១ នោះដែរនោះ?

**ឆ៖** ចាស ដើមដំបូងគាត់ចូលតែបងប្រុសខ្ញុំម្នាក់ទេ។ ចាស បងប្រុសទី២គឺនៅជាមួយឪពុក។ ក្រោយមកឪពុកខ្ញុំស្លាប់ ទើបបងប្រុសទី២ ចូលមួយទៀតចាស។

[១៣:៣៧:៤៦]

**ស៖** លោកស្រីបានបញ្ជាក់នៅក្នុងចម្លើយទៅអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង គឺថាបងរបស់លោកស្រីហ្នឹងចូលកងទ័ពបដិវត្តន៍ហ្នឹងក្នុងឆ្នាំ១៩៧០។ លោកស្រីក៏បាននិយាយផងដែរថា គាត់បានមកលេងផ្ទះប្អូនដងមុននឹងចូលកងទ័ពរំដោះ។ តើលោកស្រីនៅចាំទេថាហេតុអីបានជាគាត់មកលេងផ្ទះបងប្អូនប្រុសស្រីហើយ ទើបបានគាត់ទៅចូលរួមកងទ័ពបដិវត្តន៍វិញនោះ?

**ឆ៖** មិនមែនទេចាស សំណួរហ្នឹងគឺខុស។ គាត់ចូលហើយគឺគាត់ទៅលេង។ គាត់ចូលរួចហើយបានគាត់ទៅលេង។ មិនមែនទៅលេងហើយបានមកវិញចូលទេចាស។

**ស៖** បាទ ប្រហែលជាបកប្រែខុសទេ ប៉ុន្តែខ្ញុំចង់និយាយដូចលោកស្រីបញ្ជាក់នោះឯង គឺថាលោកស្រីបាននិយាយថា ថាគាត់បានមកលេងផ្ទះប្អូនដងក្រោយពីគាត់ចូលទ័ព។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំឆ្លើយអ៊ីចឹង គាត់ថាគាត់ចូលហើយបានគាត់មកលេង។ គាត់ចូលបានយូរឆ្នាំដែរហើយគាត់មកលេងហ្នឹងនោះ មិនមែនថាមកលេងហើយទៅវិញបានចូលនោះទេ។

[១៣:៣៩:២៥]

**ស៖** ខ្ញុំដឹងហើយថាយូរមកហើយ។ តើគាត់ -- លោកស្រីនៅចាំទេគាត់បាននិយាយពីរឿងសមរភូមិអី ដែលគាត់បានវាយប្រយុទ្ធជាមួយពួកទាហាន លន់ នល់ ទេកាលនោះ ពេលដែលគាត់មកលេង?

**ឆ៖** ចាសគាត់បានលើកឡើងដែរ។ គាត់បានចូលសមរភូមិ ចូលសមរភូមិព្រែកក្តាម ព្រែកឆ្នៅ។ ក្រោយមកបងប្រុសខ្ញុំទី២ គាត់បានស្លាប់នៅសមរភូមិព្រែកឆ្នៅហ្នឹងតែម្តងចាស។

**ស៖** តើលោកស្រីនៅចាំទេ គាត់ប្រាប់លោកស្រីថា តើសមរភូមិណាមួយដែលគេច្បាំងជាមួយ

ទាហាន លន់ នល់ ហ្នឹងច្បាស់លាស់ទេ?

**ឆ៖** គឺច្បាស់ គាត់ច្បាំងនៅសមរភូមិព្រែកព្នៅហ្នឹងតែម្តង។

**ស៖** តើលោកស្រីនៅចាំទេ គាត់ធ្លាប់ប្រាប់លោកស្រីអំពីរឿងរ៉ាវថា ទាហាន លន់ នល់ ឬក៏ យោធា លន់ នល់ ត្រូវបានគេចាប់ខ្លួន បានន័យថាកងទ័ពគាត់ ឬក៏កងទ័ពបដិវត្តន៍ធ្លាប់បានចាប់ទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** គាត់ដូចជាមិនដែលនិយាយរឿងអីផង ចាស។ គាត់មកអ៊ីចឹងគាត់ថាទៅលេង ទឹកបងប្អូន អ៊ីចឹងទៅ ទៅលេងទៅ១ថ្ងៃអ៊ីចឹងទៅ គាត់មកវិញហើយ។ ចាស មិនដែលបាននៅយូរសំណេះសំណាល អីបានយូរទេចាស។

[១៣:៤១:២១]

**ស៖** រឿងហេតុដែលថា លោកស្រី ហើយនិងបងប្រុសលោកស្រីដែលបានស្លាប់នោះ -- ខ្ញុំសួរ ឡើងវិញ។ ដែលថាមូលហេតុដែលបងស្រី -- បងប្រុសរបស់លោកស្រីហ្នឹងចូលទៅខាងកងទ័ពបដិវត្តន៍ ហ្នឹង តើដឹងពីមូលហេតុច្បាស់លាស់ថា ហេតុអីបានគាត់ចូលទេ?

**ឆ៖** បើនិយាយទៅ ខ្ញុំអត់មានបានដឹងទាំងអស់។ ចាស ទាល់តែគាត់ចូលហើយ បានគាត់ទៅ លេង ថាគាត់ចូលបម្រើកងទ័ព។ គាត់នៅក្នុងជួរកងទ័ពរួចទៅហើយចាស។

**ស៖** តើគាត់ធ្លាប់លោកស្រីអំពីការកាប់សម្លាប់ ការសម្លាប់ទាហាន លន់ នល់ ដែលគេចាប់បាន ទេក្នុងពេលនោះ?

**ឆ៖** ខ្ញុំដូចអត់ដែលបានឮគាត់និយាយផង។

**ស៖** ខ្ញុំយល់ពីចម្លើយរបស់លោកស្រីថាគាត់ជាផ្នែកមួយនៃកងទ័ពរំដោះនៅភូមិភាគឧត្តរ។ នៅ ពេលមួយនោះលោកស្រីក៏បានចូលកងកម្លាំងបដិវត្តន៍នោះដែរ ប៉ុន្តែនៅភូមិភាគបូព៌ា។ តើលោកស្រីបាន ដឹងថា ហេតុអ្វីបានជាគាត់ទៅចូលនៅខាងភូមិឧត្តរ ហើយលោកស្រីចូលខាងភូមិភាគបូព៌ានោះ?

**ឆ៖** ដើមកំណើតនាងខ្ញុំនៅភូមិភាគបូព៌ា។ ខ្ញុំនៅបូព៌ា ខ្ញុំនៅបូព៌ា ខ្ញុំចូលនៅខាងបូព៌ា ដូចថាគាត់ ឧត្តរអ៊ីចឹង កាលដើមឡើយគាត់ទៅរកស៊ីនៅភូមិ -- នៅស្វាយទាប បុសខ្នុរ មុនយើងរដ្ឋប្រហារ គាត់ នៅរកស៊ីខាងធ្វើដំឡូង ដល់ពេលសង្គ្រាមក៏គាត់អត់វិលមកវិញ ស្រុកទេសយើងកើតសង្គ្រាមគាត់អត់ វិលមកវិញទេ គាត់នៅ គាត់ចូលនៅទីកន្លែងនោះតែម្តងចាស។

[១៣:៤៣:៣៧]

**ស៖** លោកស្រី ព្រឹកមិញនេះលោកស្រីបានឆ្លើយថា លោកស្រីបានចូលកងកម្លាំងបដិវត្តន៍នោះ ហើយខ្ញុំកត់ត្រាបើមិនខុសទេ លោកស្រីនិយាយថា ជាសមាជិកទី៣នៃកងវរសេនាតូចនៅភូមិភាគបូព៌ា។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំជាយុទ្ធជនធម្មតាទេ តែទៅនៅកងទ័ពក្នុងមួយកងមាន ១០០នាក់។ ខ្ញុំនៅក្រុមទី៣ កងតូចទី២ កងធំទី១០ -- ទី១៣។

**ស៖** តួនាទីរបស់លោកស្រីនោះគឺថា ខ្ពស់ជាងទាហានធម្មតា ឬក៏មានឋានៈជាអ្វីនៅពេលជាយោធានោះ?

**ឆ៖** ខ្ញុំជាយុទ្ធជនធម្មតាទេ យុទ្ធនារីធម្មតា។ ដូចខ្ញុំថាអ៊ីចឹងក្នុងក្រុមរបស់ខ្ញុំហ្នឹង ខ្ញុំនៅក្រុមទី៣ សមាជិកក្រុមទៀតផងចាស មិនមែនធ្វើអីអត់មានទទួលតំណែងអ្វីអត់មានទាំងអស់។ ចាស នៅក្នុងក្រុមទី៣ហ្នឹង កងតូចទី២ ហ្នឹងក៏ខ្ញុំនៅក្នុងកងតូចទី២។ កងធំហ្នឹងក៏ ហ្នឹងហើយកងធំទី១៣ហ្នឹងតែម្តងចាស។ អត់មានតំណែងអ្វីទាំងអស់។ ជាយុទ្ធនារីសុទ្ធសាធ។

[១៣:៤៥:២១]

**ស៖** នៅកងអនុសេនាតូច១៣នោះ គឺស្ថិតនៅក្រោមកងពល២០៣ ឬក៏កងពលណា?

**ឆ៖** កងពល២០៣ហ្នឹង មិនមែនកងពលទេ ជាឈ្មោះភូមិភាគ អ៎! តំបន់២០៣ ភូមិភាគបូព៌ាអាហ្នឹងមួយចំនៀរ ខាងស្តាំទន្លេមេគង្គ គឺជាតំបន់ភូមិភាគ២០៣ ចាស។ មិនមែនតំណែង២០៣ទេចាស គឺភូមិភាគ២០៣។

**ស៖** បាទខ្ញុំយល់ច្រឡំទេ។ ត្រូវហើយ។ តើលោកស្រីអាចជម្រាបតុលាការបានទេថាកងវរសេនាតូចរបស់លោកស្រីហ្នឹងជាផ្នែកនៃកងពលណាមួយ តើកងពលទីប៉ុន្មាន? កងពលទី១ ទី២ ឬក៏ទី៣របស់កម្ពុជាប្រជាធិបតេយ្យនោះ។ អាចជម្រាបបានទេ?

**ឆ៖** បើនិយាយទៅកងទ័ពនារីមិនមានច្រើនទេ។ មានតែប៉ុន្មានកង អត់មានដល់កងពលផង។ កងទ័ពយុទ្ធនារីហ្នឹងក៏ទើបតែកកើតឡើងក្នុងឆ្នាំ១៩៧៤ ដើមឆ្នាំ៧៥ហ្នឹងដែរទេ។ មិនមានដល់កងពលទេចាស។

**ស៖** ហេតុអ្វីបានជាចុងក្រោយហ្នឹង លោកស្រីក្លាយទៅជាក្រុមមួយ ក្នុងក្រុមមួយដ៏ធំ ដែលគេហៅថាជាកងពលនោះ?

[១៣:៤៧:២៥]

**ឆ៖** នាងខ្ញុំដូចជាមិនយល់ដែរ ហៅថាកងពល ព្រោះកងនាងខ្ញុំអត់មានដល់កងពលផង មានត្រឹមតែកងរយ។ កងពលហ្នឹងបានន័យថាច្រើនណាស់បានកងពល។ ហើយត្រឹមកងរយហ្នឹង គឺតិចតួចណាស់ យុទ្ធនារីគឺមានតិចតួច អត់មានដល់កងពលទេចាស។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែថាក្រុមរបស់លោកស្រីទោះបីជាក្រុមហ្នឹងតូច តើធ្លាប់បានជាស្ថិតនៅក្នុងក្រុមណាមួយធំទេ ក្រុមតូចនេះ។ តើកងអនុសេនាតូច ជាផ្នែកមួយនៃកងពល ឬក៏កងទាហានយោធាណាធំនៅពីលើហ្នឹងដែរឬទេ?

**ឆ៖** ចាស អត់មានទេចាស។

**ស៖** តើលោកស្រីធ្លាប់ចូលរួមប្រយុទ្ធនៅក្នុងសមរភូមិជាមួយទាហាន អតីតទាហាន លន់ នល់ នោះដែរឬទេ?

**ឆ៖** ចាស សម័យនោះវាមិនទាន់ដល់ បើនិយាយថាវាមិនទាន់ដល់ ហាត់រៀនចេះចប់ សង្គ្រាមក៏ចប់ដែរ។ ទទួលជ័យជម្នះ១៧មេសាហ្នឹង ក៏រំសាយយុទ្ធនារីហ្នឹងវិញ។ យុទ្ធនារីហ្នឹងក្លាយទៅជាកងចល័តវិញចាស។

[១៣:៤៩:០៨]

**ស៖** ដូច្នេះលោកស្រីមិនធ្លាប់បានចូលសមរភូមិប្រយុទ្ធទេ។ តើ-- ហើយលោកស្រីបានចូលរួមក្នុងការរំដោះទីក្រុងភ្នំពេញ ឬក៏មិនធ្លាប់បានចូលរួមទេ?

**ឆ៖** នាងខ្ញុំមិនធ្លាប់បានចូលរួមរំដោះទេ។ តែក្រោយរំដោះក៏បានចូលមកបោសសម្អាត ចាស។

**ស៖** ប៉ុន្តែនៅពេលក្រោយពីថ្ងៃ១៧ មេសា ឆ្នាំ៧៥ហ្នឹង មកឆ្ងាយបានមកធ្វើការងារនេះ ប៉ុន្តែចង់សួរភ្លាមៗបន្ទាប់ពីនោះ?

**ឆ៖** ភ្លាមៗពីឆ្នាំ៧៥ហើយ? នាងខ្ញុំចូលមកដល់ទីក្រុងភ្នំពេញ។ ដូចខ្ញុំបានរ៉ាយរាប់ពីខាងដើម ហើយដើរបោសសម្អាតគ្រប់ទីកន្លែងវិលមកនៅទីក្រុងភ្នំពេញវិញចូលកន្លែងកាត់ដេរហ្នឹងតែម្តង។

**ស៖** ខ្ញុំព្យាយាមចង់សួរលោកស្រីម្យ៉ាងទៀត តើលោកស្រីនៅកន្លែងណាក្នុងមួយ,ពីរ,បីសប្តាហ៍ ឬមួយខែក្រោយពីថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥នោះ?

**ឆ៖** ពេលរំដោះទីក្រុងភ្នំពេញឆ្នាំ១៩៧៥ នាងខ្ញុំនៅខាងស្រុក កញ្ជៀចចាស។ រយៈពេលយូរខែ រវាងពីរឬបីខែដែរបានបញ្ជូនមកទីក្រុងភ្នំពេញ។

[១៣:៥១:១៧]

**ស៖** ខ្ញុំចង់សួរសំណួរមួយចំនួនទៀតទាក់ទងទៅនឹងការហ្វឹកហ្វឺនដែលលោកស្រីបានឆ្លើយជូនតុលាការគឺថា តាំងពីរំដោះភ្នំពេញរួចមក គឺលែងមានការហ្វឹកហាត់តទៅទៀតហើយខាងយោធា។ តើការហ្វឹកហាត់របស់លោកស្រីនោះទាក់ទងទៅនឹងការប្រព្រឹត្តទៅលើទាហាន លន់ នល់ នៅពេលដែលគេចាប់បានពួកទាំងនោះទេ អ្នកទាំងនោះទេបន្ទាប់ពីសមរភូមិក្រោយពីមានសមរភូមិហើយនោះ?

**ឆ៖** កាលហ្នឹងហាត់ហ្វឹកហ្វឺនដើម្បីចូលសមរភូមិ។ តែមិនបានចូលទេដូចខ្ញុំលើកឡើងវាទទួលយើងជ័យជំនះ ១៧ មេសា។

**ស៖** ខ្ញុំយល់ហើយ។ តើលោកស្រីនៅចាំទេ តើមានការណែនាំការបង្រៀននៅក្នុងវគ្គហ្វឹកហ្វឺនហ្នឹងទេ ថាតើទាហាន លន់ នល់ ដែលគេចាប់បានឬក៏ជាឈ្លើយសឹកជាដើមនោះតើទ័ពខាងរំដោះនោះត្រូវធ្វើម៉េច គេមានណែនាំពីរបៀបធ្វើម៉េចទេ?

**ឆ៖** បើនិយាយទៅពួកខ្ញុំជាយុទ្ធជនសុទ្ធសាធអត់មានបានដឹងអ្វីទាំងអស់ អារឿងការងារសមរ-ភូមិខាងមុខគឺអត់មានបានដឹង អត់ដឹង មិនដឹងថាចាប់បានធ្វើទារុណកម្មអីយ៉ាងណាគឺអត់បានដឹងទាំងអស់។

[១៣:៥២:១៨]

**ស៖** តើលោកស្រីនៅចាំទេ ក្នុងរយៈពេល១ខែ ឬ២ខែក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថាតើពួកទាហាន លន់ នល់ ដែលគេចាប់បាននោះតើគេធ្វើអ្វី? តើធ្លាប់បានឃើញដោយផ្ទាល់ភ្នែកទេថាគេយកទាហានដែលគេចាប់បានដែលចុះចាញ់ហ្នឹងទៅធ្វើអ្វី? ធ្លាប់បានឃើញទេបាទ?

**ឆ៖** ចាស នាងខ្ញុំអត់ដែលបានឃើញផង មិនដែលបានជួប អត់ដែលបានឃើញ ដូចថា ពួកភ្នំពេញគេជម្លៀសចេញអីចឹង ក្រោយមកពួកខ្ញុំចូលមកបានន័យថាដល់អីចឹងអត់ដឹងអីទាំងអស់ចាស។ អត់មានបានដឹង អត់បានឃើញ។

**ស៖** តើលោកស្រីនៅចាំដែរឬទេថាតើធ្លាប់ឮថាគេមាននយោបាយដើម្បីសំដៅទៅរកអតីតទាហាន លន់ នល់ នៅក្នុងភ្នំពេញ ឬក៏នៅកន្លែងផ្សេងៗទៀតនៅក្នុងតំបន់ដែលលោកស្រីរស់នៅគឺថា ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ធ្លាប់ឮដែរឬទេ?

[១៣:៥៤:៣៤]

**ឆ៖** បើនិយាយទៅសម័យនោះវាគ្មានព័ត៌មានអីនឹងបានដឹង ដូចថា នៅកន្លែងណាគឺនៅកន្លែងហ្នឹងអត់បានដឹងអត់បានអីទាំងអស់។ សម័យនោះគឺសម័យដែលនៅកន្លែងណាគឺកន្លែងហ្នឹងធ្វើការកន្លែង

នុំងមិនអាចរហេតរហូតបានទេ។ ចាស គឺអត់បានដឹងទាំងអស់។

**ស៖** លោកស្រីសាក្សី លោកស្រីបានឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងទំព័រ ឯកសារ E3/474។ លោកស្រីបាននិយាយថា "ខ្ញុំសុំសុំឈប់ ហើយសុំស្ម័គ្រចិត្តចូលបម្រើកងទ័ពនារី នៅភូមិភាគបូព៌ាដឹកនាំដោយលោក សោ ភឹម"។ តើលោកស្រីចង់និយាយដូចម្តេច ថាអង្គភាពរបស់ លោកស្រីដឹកនាំដោយលោក សោ ភឹម នោះ?

**ឆ៖** ខ្ញុំចង់និយាយថា ពេលនោះខ្ញុំចូលទៅគេបង្កើតកងទ័ពនារី។ គណៈភូមិបូព៌ាហ្នឹងបានបង្កើត គេឱ្យរើសជាយុវនារីដើម្បីដឹកជញ្ជូន ហើយត្រៀមហាត់ដើម្បីចូលសមរភូមិដែរ ចាស។ គ្រាន់តែឈ្មោះ ថាភូមិភាគកាន់កាប់ដោយ សោ ភឹម ទេ តែមិនដឹងថាមិនមានគាត់ អវត្តមានគាត់មកជួបពួកនាងខ្ញុំ គឺ អត់ទេ។ គ្រាន់តែមានឈ្មោះថា ទ័ពភូមិភាគបូព៌ាតែប៉ុណ្ណោះទេ ចាស។

[១៣:៥៦:២៦]

**ស៖** ដូច្នេះ អង្គភាពរបស់លោកស្រីមិនមែនជាផ្នែកមួយនៅក្នុងកងទ័ពផ្នែកធំ ដែលដឹកនាំដោយ សោ ភឹម ទេ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ពិតជាត្រឹមត្រូវ។

**ស៖** នៅពេលដែលលោកស្រីនិយាយថា ដែលដឹកនាំដោយ សោ ភឹម ហ្នឹងគឺថាតាមពាក្យសម្តី ហ្នឹង គឺថាត្រូវដឹកនាំដោយមេបញ្ជាការ ប៉ុន្តែ សោ ភឹម ជាមេបញ្ជាកំពូលខាងនៃកងកម្លាំងដែលនៅក្នុង នោះមានលោកស្រី -- កងលោកស្រីនៅក្នុងនោះដែរ។ តើអ៊ីចឹងត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ?

**ឆ៖** នេះវាជាត្រឹមត្រូវហើយ គ្រាន់តែថាគាត់បង្កើតមានកងយុវនារីដឹកជញ្ជូនអ៊ីចឹងទៅ សម្រាប់ ជួយផ្តល់ស្បៀងទៅសមរភូមិអ៊ីចឹង។ តែចំណែកឱ្យគាត់ក្តោបក្តាប់យើង គឺអត់មានទេ។ គ្រាន់តែថាគាត់ បង្កើត។ ចាស បង្កើតជាកងទ័ពនារីហ្នឹងទៅ ឱ្យជួយដឹកជញ្ជូន ចាស គ្រាន់តែប៉ុណ្ណឹង។

**ស៖** តើលោកស្រីស្គាល់បុរសម្នាក់ មនុស្សម្នាក់ឈ្មោះ សេង ហ៊ុន នោះទេ?

[១៣:៥៧:៥៧]

**ឆ៖** នាងខ្ញុំដូចជាមិនដែលស្គាល់ផង។ មិនស្គាល់ហើយ មិនដែលឮ មិនដែលឃើញទៀត។

**ស៖** តើលោកស្រីស្គាល់ថា តើអ្នកណាជាអនុលេខាភូមិភាគបូព៌ា នៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩?

**ឆ៖** បើនិយាយទៅ ខ្ញុំយុទ្ធជនតូចតាចមិនអាចស្គាល់អ្នកធំបានទេ។ អត់ដែលបានស្គាល់។

**ស៖** តើលោកស្រីធ្លាប់ស្គាល់មនុស្សម្នាក់ឈ្មោះ កែវ សំណាង ទេ?

**ឆ៖** នាងខ្ញុំក៏មិនដែលស្គាល់ដែរ ចាស។

**ស៖** ខ្ញុំនិយាយខាងដើម គាត់គឺជាអនុប្រធានយោធា បាទ ប្រធានសេនាធការនៅភូមិភាគបូព៌ា។

**ឆ៖** នាងខ្ញុំអត់ស្គាល់ទាំងអស់ ចាស។ អត់ដែលបានស្គាល់។

**ស៖** តើលោកស្រីស្គាល់ឈ្មោះម្នាក់ឈ្មោះ លី ផែន ទេ?

**ឆ៖** ឈ្មោះហ្នឹង ក៏អត់ស្គាល់។

**ស៖** តើម្នាក់ទៀតស្គាល់ឈ្មោះ ពូហាក់ នោះទេ?

**ឆ៖** អត់ស្គាល់ទេ ចាស ព្រោះអីនាងខ្ញុំជំនាន់ហ្នឹង នៅស្ទើរណាស់ អត់ស្គាល់។ អត់ដឹង។

**ស៖** ខ្ញុំប្រាប់ថា គាត់ជាមេបញ្ជាការកងពលនៅ កងពលទី៣ នៅភូមិភាគបូព៌ា តើធ្វើឲ្យលោកស្រីនឹកឃើញទេ?

**ឆ៖** អត់ទេលោក ព្រោះខ្ញុំអត់ដែលបានស្គាល់ផង។

**ស៖** តើស្គាល់ឈ្មោះពូ សារុន អាចនឹងលោកស្រីដឹងចាំថា គាត់ជាអ្នកណាទេ?

**ឆ៖** នាងខ្ញុំក៏មិនបានស្គាល់ដែរហ្នឹង អត់ស្គាល់។

**ស៖** តើឈ្មោះ គ្រី លោកស្រីបានដឹងថា គាត់ជាអ្នកណាធ្វើអ្វីទេ?

**ឆ៖** ចាស នាងខ្ញុំក៏អត់ស្គាល់ដែរ។

[១៤:០១:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន គឺថាខ្ញុំមានសំណួរមួយទៀត ដែលខ្ញុំចង់សាកសួរសាក្សីហ្នឹងទាក់ទងទៅនឹងឈ្មោះភូមិភាគបូព៌ា។ គឺសាក្សីដែលមានរហស្សនាម TCW-223 ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញដល់សាក្សីរូបនេះនៅឈ្មោះរបស់សាក្សី TCW-223 ដែលខ្ញុំសរសេរនៅលើក្រដាស ហើយបន្ទាប់មកខ្ញុំគ្រាន់តែសួរសាក្សី ថាតើសាក្សីគាត់ស្គាល់ឈ្មោះ នុ៎ង ឬក៏អត់ ហើយដោយមិនឲ្យសាក្សីនិយាយ ឬក៏អានពីឈ្មោះនោះទេ។ ហើយប្រសិនបើសាក្សីគាត់ស្គាល់គាត់អាចនឹងបង្ហាញពីតួនាទី ឬក៏ការងាររបស់សាក្សី TCW-223 នៅក្នុងភូមិភាគបូព៌ានេះ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ប៉ុន្តែសូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់ថា ស្គាល់នៅកាលៈទេសៈ

ណាឲ្យបានច្បាស់លាស់។ ជៀសវាងសួរសំណួរទូទៅដែលមិនបែកចែកអំពីកាលវេលាច្បាស់លាស់នៃការស្គាល់។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីយកជូនសាក្សីពិនិត្យ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកស្រីស្គាល់ឈ្មោះនោះដែរឬទេ? គឺខ្ញុំចង់សួរពីចន្លោះខែមេសា ឆ្នាំ៧៥ តើលោកស្រីស្គាល់ឈ្មោះដែលខ្ញុំបង្ហាញហ្នឹងទេ?

**លោកស្រី ឯក ហេន៖**

**ឆ៖** នាងខ្ញុំមិនដែលស្គាល់សោះ។ ឈ្មោះនេះអត់ដែលស្គាល់។ អត់ដែលស្គាល់ ហើយទើបតែស្គាល់គាត់ថ្មីៗ ដោយសារតាមរយៈទូរទស្សន៍អ៊ីអ៊ឹចឹងទៅ ឃើញ។ បើពីមុនមកអត់ដែលបានស្គាល់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១៤:០៣:៥៩]

**លោក អាកទួរ វ៉ែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វ៉ែកគែន៖**

**ស៖** ជម្រាបសួរលោកស្រី។ ខ្ញុំឈ្មោះ អាកទួរ វ៉ែកគែន ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកស្រី។ សំណួរទី១ ពាក់ព័ន្ធនឹងវគ្គរៀនសូត្រដែលលោកស្រីបានឆ្លើយថាបានចូលរួម ហើយក្នុងនោះលោក ខៀវ សំផន ជាអ្នកបង្រៀន។ ដូច្នេះខ្ញុំចង់និយាយជាមួយលោកស្រីអំពីកាលបរិច្ឆេទនៃវគ្គរៀនសូត្រនេះ។ កាលពីព្រឹកមិញ តំណាងសហព្រះរាជអាជ្ញាបានអានឃ្លាមួយចេញពីកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោកស្រីដែលបានធ្វើទៅនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ នៅក្នុងឃ្លាដែលតំណាងសហព្រះរាជអាជ្ញាបានអាននោះ គឺថាលោកស្រីបានបញ្ជាក់ថាពិតជាអ៊ីចឹងមែន។ លោកស្រីបានឆ្លើយថា ខ្ញុំសូមដកស្រង់ "ការរៀនសូត្រដំបូងដែលធ្វើឡើងនៅ

បុរីកីឡា នៅឆ្នាំ១៩៧៦នោះ គឺបង្រៀនដោយលោក ខៀវ សំផន"។ សូមបញ្ចប់ការដកស្រង់។

ដូច្នេះខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់អំពីការបរិច្ឆេទនៃវគ្គរៀនសូត្រ ដែលបង្រៀនដោយលោក ខៀវ សំផន នេះ គឺថាពិតជាឆ្នាំ១៩៧៦ ហ្នឹងមែនទេ?

**ឆ៖** ឆ្នាំ៧៦ គឺចុងឆ្នាំទៅហើយចាស ចុងឆ្នាំ៧៦។ បើនិយាយទៅជិតចូល៧៧ទៅហើយ។

[១៤:០៥:៥៥]

**ស៖** បាទ សូមអរគុណ។ ការពីព្រឹកមិញនេះលោកស្រីបាននិយាយអំពីកាលបរិច្ឆេទផងដែរនៅពេលដែលលោកស្រីនិយាយអំពីកិច្ចប្រជុំនោះ។ លោកស្រីថា ខៀវ សំផន មិនចង់ឲ្យពួកយើងឈ្លោះប្រកែកកាប់ចាក់គ្នាទេគឺថាឲ្យរួបរួមគ្នា ពីព្រោះថាសង្គ្រាមទើបតែបញ្ចប់។ ឃ្លាដែលខ្ញុំចាប់អារម្មណ៍នោះគឺថាឃ្លាដែលថា "សង្គ្រាមទើបតែបញ្ចប់"។ អ៊ីចឹងតើលោកស្រីសំដៅទៅលើសង្គ្រាមអ្វី ពេលដែលលោកស្រីឆ្លើយទៅនឹងតំណាងសហព្រះរាជអាជ្ញាថា "សង្គ្រាមទើបតែបញ្ចប់" នោះ?

**ឆ៖** សំដៅទៅលើប្រទេសខ្មែរយើង។ ចាស សង្គ្រាមម្តងហើយម្តងទៀត ដូច្នេះគាត់ខំឲ្យយើងសាមគ្គីគ្នា កសាងប្រទេសជាតិយើងឲ្យរីកចម្រើន ខំប្រឹងឲ្យទាន់ -- យើងវ័យយើងកំពុងតែខំប្រឹងឲ្យគាត់ឲ្យយើងទាំងអស់គ្នាហ្នឹងខំប្រឹងសាមគ្គីគ្នា ចាប់ដៃគ្នា បង្កើនផល ជួយឲ្យប្រទេសជាតិរុងរឿង។ ចាស ខ្ញុំមានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកស្រី។ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ គឺសង្គ្រាមដែលលោកស្រីនិយាយកាលពីព្រឹកមិញនេះគឺ សង្គ្រាមដែលបញ្ចប់ដោយជ័យជម្នះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ តើអ៊ីចឹងមែនទេ?

[១៤:០៧:៥០]

**ឆ៖** ចាស ពិតជាត្រឹមត្រូវហើយ។

**ស៖** ដើម្បីឲ្យប្រាកដថាយើងនិយាយអំពីពេលវេលា នៃការរៀនសូត្រដែលដឹកនាំដោយលោក ខៀវ សំផន នោះ កាលពីព្រឹកមិញលោកស្រីបានឆ្លើយទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាដែលគាត់បានសួរលោកស្រីថា "នេះជាលើកទី១ ដែលជាវគ្គបង្រៀនដោយលោក ខៀវ សំផន នោះដែលលោកស្រីបានឮអំពីការនិយាយអំពីជនក្បត់មែនទេ? ហើយលោកស្រីក៏បានឆ្លើយថា៖ ពិតហើយគឺលោកស្រីមិនធ្លាប់ឮគេនិយាយអំពីពាក្យថាក្បត់ហ្នឹងពីមុនទេ ទើបតែឮជាលើកដំបូងនៅក្នុងវគ្គរៀនសូត្រដែលដឹកនាំដោយលោក ខៀវ សំផន នេះ"។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** ដូច្នេះតើត្រឹមត្រូវដែរឬទេ? ហើយបើមិនត្រឹមត្រូវសូមលោកស្រីបញ្ជាក់។ គឺមានន័យថា ពាក់ព័ន្ធទៅនឹងវគ្គសូត្រទាំងពីរ ដែលលោកស្រីបានចូលរួម ហើយក្នុងនោះក៏មានវគ្គទី១ បង្រៀនដោយលោក ខៀវ សំផន ហើយវគ្គទី២ គឺ នួន ជា។ អ៊ីចឹងមែនទេចម្លើយរបស់លោកស្រីនុ៎ង? គឺថាវគ្គទី១ គឺបង្រៀនដោយលោក ខៀវ សំផន និងវគ្គទី២ បង្រៀនដោយលោក នួន ជា?

[១៤:០៩:៤០]

**ឆ៖** ពាក់ព័ន្ធនឹងសំណួរទាំងពីរហ្នឹងច្រឡំគ្នាហើយចាស។ សំណួរ -- លោក ខៀវ សំផន រៀនអត់មានពាក់ព័ន្ធរឿងទាន់មានក្បត់ទេចាស។ ដល់ទៅឆ្នាំ៧៨ បានមានពាក់ព័ន្ធ។ វគ្គមុនអត់មានទេ គាត់ឡើងពីការតស៊ូ ធ្វើការងារ ជួយប្រទេសជាតិ អត់មានពាក់ព័ន្ធរឿងមានអ្នកក្បត់ទេ។ ប្រជុំវគ្គទី២ បានមាន។

**ស៖** លោកស្រីបានឆ្លើយថា លោក ខៀវ សំផន បានបង្រៀនពីរវគ្គ ឬក៏យ៉ាងម៉េច? លោកស្រីនិយាយវគ្គទី២ គឺវគ្គដែលបង្រៀនដោយលោក នួន ជា ហ្នឹង ឬក៏មិនមែនទេ? សូមលោកស្រីបញ្ជាក់ឲ្យបានច្បាស់ទៅមើលនូវចម្លើយលោកស្រីអម្បាញ់មិញនេះ។

**ឆ៖** ខ្ញុំថាបានទៅរៀននៅបុរីកីឡាពីរដង។ ចាស វគ្គទី១ និងវគ្គទី២។ វគ្គទី១ រៀននៅចុងឆ្នាំ១៩៧៦ ដើមឆ្នាំ៧៧ ជំនាន់នុ៎ងគឺមិនទាន់មានទេ មានចាប់ មានក្បត់នោះឡើយទេ។ ដល់ឆ្នាំ៧៨ បានមាន។ ដូច្នេះ ការប្រជុំលើកទី១ វាមាន -- គាត់លើកឡើងអត់មានពាក់ព័ន្ធរឿងមានក្បត់មានអីទេ អាហ្នឹងគ្រាន់ថាគាត់រៀនសូត្រពីការជួយពង្រឹងកម្មករទាំងអស់ឲ្យខំប្រឹង។ ដូចខ្ញុំលើកឡើងអ៊ីចឹងថា សាមគ្គីគ្នាពួតដៃគ្នាឲ្យវារីកចម្រើន ប្រទេសជាតិយើងចាស ហ្នឹងនៅឆ្នាំ១៩៧៦ ចុងឆ្នាំ អ៊ំ! ដើមឆ្នាំ១៩៧៧ ចាស។ រៀនលើកទី២ បានមានពាក់ព័ន្ធចាស។

[១៤:១២:១៣]

**ស៖** ចុះវគ្គរៀនសូត្រទី២ ហ្នឹងអ្នកណាជាអ្នកធ្វើបទឧទ្ទេសនាម អ្នកណាជាអ្នកបង្រៀន?

**ឆ៖** វគ្គទី២គឺ លោកអ៊ំ ខៀវ សំផន ចាស។ វគ្គទី១ គឺលោកអ៊ំ នួន ជា។

**ស៖** លោកស្រី កាលពីពេលព្រឹកមិញនេះ លោកស្រីដូចជាផ្តល់ចម្លើយផ្ទុយទៅវិញទេ។ តំណាងសហព្រះរាជអាជ្ញាបានអានសម្រង់ចម្លើយរបស់លោកស្រី គឺកំណត់ហេតុនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨។ នៅក្នុងកំណត់ហេតុនោះលោកស្រីបានឆ្លើយថា លើកទី១ គឺវគ្គទី១ ធ្វើឡើងនៅបុរីកីឡា នៅឆ្នាំ

១៩៧៦ ដោយមានខៀវ សំផន ជាអ្នកដឹកនាំប្រជុំរៀនសូត្រ។ ហើយនៅទំព័រដដែលហ្នឹងគឺទំព័រទី៤ លោកស្រីបាននិយាយថា នួន ជា ធ្លាប់ដឹកនាំប្រជុំរៀនសូត្រនៅបុរីកីឡាដែរ គឺនៅឆ្នាំ១៩៧៨។ ខ្ញុំដឹងហើយថារឿងហេតុហ្នឹងវាកើតឡើងតាំងពីយូរមកហើយ ប៉ុន្តែខ្ញុំចង់ដឹងអំពីខ្លឹមសារពិតប្រាកដនៃចម្លើយរបស់លោកស្រីពាក់ព័ន្ធនឹងកាលបរិច្ឆេទនេះ តើត្រូវប្រកាន់យកនូវចម្លើយរបស់លោកស្រីនៅក្នុងកំណត់ហេតុដែលលោកស្រីបានឆ្លើយកាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឬក៏យ៉ាងណា? ព្រោះចម្លើយលោកស្រីអម្បាញ់មិញនេះគឺផ្ទុយគ្នា។ ម្តងលោកស្រីថាលើកទី១ ខៀវ សំផន, លើកទី២ នួន ជា។ ឥឡូវនេះលោកស្រីថាលើកទី១ នួន ជា ហើយលើកទី២ គឺ ខៀវ សំផន ទៅវិញ?

[១៤:១៤:១៧]

**ឆ៖** នេះគ្រាន់ថាឆ្លើយខុសសំណួរទី -- លើកទី១ លើកទី២។ គ្រាន់ថាវាយូរហើយដូចជានិយាយរួមការភ្លេចភ្លាំងខ្លះដែរ មិនមែនថាមិនភ្លេចទេ ព្រោះវាយូរហើយ។ ព្រោះតាំងពីក្មេងរហូតដល់ចំណាស់នេះហើយ វាអាចភ្លេចភ្លាំងខ្លះ។ ដូច្នេះសំណួរមានតែពីរហ្នឹង គ្រាន់ថាច្រឡំមនុស្សអីក៏ថាអ៊ីចឹងទៅចុះ។ ប៉ុន្តែមានតែពីរហ្នឹងទេ ធ្លាប់ទៅរៀនសូត្រជាមួយគាត់ចាស។

**ស៖** បាទខ្ញុំសួរសំណួរលោកស្រីហ្នឹងគឺថាជាលក្ខណៈទូទៅទេ តែលោកស្រីសូមឆ្លើយឲ្យច្បាស់តើលោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាតើសម្តីណាជារបស់លោក ខៀវ សំផន សម្តីណារបស់ នួន ជា នោះ? ចំពោះលោកស្រីអាចទេ អាចធ្វើបានទេ ឬក៏ជាការលំបាកសម្រាប់លោកស្រី?

**ឆ៖** ដូច្នេះសម្រេចថាលើកទី១ លោកអ៊ំ នួន ជា, លើកទី២ លោកអ៊ំ ខៀវ សំផន។

[១៤:១៦:០០]

**ស៖** បាទ ខ្ញុំដូចជាភ្ញាក់ផ្អើលណាស់ លោកស្រីនិយាយផ្ទុយគ្នា។ លោកស្រីថាមិនសូវច្បាស់ហើយម្តងថាច្បាស់។ មុនពេលដែលខ្ញុំចាប់ផ្តើមសួរអំពីកាលបរិច្ឆេទនៃវគ្គរៀនសូត្រនេះ គឺថាលោកស្រីបានឆ្លើយរួចទៅហើយទៅនឹងតំណាងសហព្រះរាជអាជ្ញា។ លោកស្រីបានបញ្ជាក់ថាលោក ខៀវ សំផន បានបង្រៀន ហើយពេលដែលបង្រៀនហ្នឹងគឺថាគាត់បានបញ្ជាក់ថាសង្គ្រាមជិតចប់ហើយ-- ទើបតែចប់ (សូមទោស)។ ហើយលោកស្រីក៏ឆ្លើយថា លោកស្រីមិនធ្លាប់ឮពាក្យក្បត់ទេមុនហ្នឹង។ ហើយប្រសិនបើវគ្គរៀនសូត្ររបស់ នួន ជា កើតមុនពេលវគ្គរៀនសូត្រដោយលោក ខៀវ សំផន នោះ លោកធ្លាប់ឮពាក្យថាក្បត់ហើយ ពីព្រោះលោកស្រីបានឆ្លើយថា នួន ជា បាននិយាយអំពីពាក្យក្បត់។ ដូច្នេះតើលោកស្រីច្បាស់ទេឥឡូវនេះ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចាស ពេលនុ៎ងក៏គាត់លើកឡើងមានអ៊ីចឹងដែរ។ គាត់លើកឡើងថា ភូមិភាគបូព៌ា -- អ៎! ភូមិភាគឧត្តរ មិនមែនភូមិភាគបូព៌ាទេណា ច្រឡំ។ ភូមិភាគឧត្តរក្បត់ ចាស។ នេះគ្រាន់ថាបានគាត់លើកឡើងថាភូមិភាគឧត្តរក្បត់ទេណា។ តែមិនដឹងថាអ្នកក្បត់ហ្នឹងជាអ្នកណា អីអ្នកណាអី ក៏មិនដឹងដែរ។

**ស៖** នៅពេលដែលលោកស្រីនិយាយថាគាត់ហ្នឹង លោកស្រីសំដៅលើកអ្នកណាមួយ លោក នួន ជា ឬក៏លោក ខៀវ សំផន?

**ឆ៖** ខ្ញុំចង់និយាយថាលោក ខៀវ សំផន។

[១៤:១៧:៥៥]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន! ខ្ញុំសូមការអនុញ្ញាតចាក់ខ្សែអាត់នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ពីព្រោះថាយើងទាំងអស់គ្នានៅទីនេះ យើងដឹងហើយថាកំណត់ហេតុស្ដាប់ចម្លើយសាក្សីសរសេរនេះជាសេចក្ដីសង្ខេបនៃខ្សែអាត់ ហើយគាត់បានចុះហត្ថលេខា ក៏ប៉ុន្តែក្នុងករណីខ្លះនោះយើងឃើញថាការសម្ភាស និងរបៀបនៃការសម្ភាសនោះធ្វើឲ្យយើងដឹងច្រើនអំពីលក្ខខណ្ឌនៃសាក្សីដែលគាត់និយាយអំពីប្រធានបទណាមួយ។ ក្នុងករណីនេះ ខ្ញុំគិតថាពាក់ព័ន្ធទៅនឹងបញ្ហាដែលថាលោក ខៀវ សំផន ទំនងជានិយាយ ឬក៏នៅក្នុងវគ្គប្រជុំរៀនសូត្រដែលខ្ញុំលើកឡើងនេះ។ ការស្ដាប់ខ្សែអាត់នេះ គឺមានសារៈសំខាន់ណាស់ គឺថាវាអាចឲ្យយើងយល់ច្បាស់អំពីខ្លឹមសារនៃសក្ខីកម្មរបស់គាត់នៅពេលដែលគាត់ឆ្លើយជូនអ្នកស៊ើបអង្កេត។

ខ្ញុំសូមបញ្ជាក់ផងដែរថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះក្នុងការកោះហៅសាក្សីនេះគឺថាថ្មីៗនេះទេ។ ដូច្នេះហើយវាឆាប់ពេក ដូច្នេះយើងមិនទាន់មានឱកាសក្នុងការស្នើសុំបកប្រែប្រតិចារឹកខ្សែអាត់នេះទេ យើងមិនទាន់បានធ្វើទេ ដូចកាលពីយើងធ្វើដូចមុនទេ។ ដូច្នេះ ការបកប្រែនេះធ្វើឡើងដោយអ្នកបកប្រែក្រៅផ្លូវការទេដែលបកប្រែឲ្យខ្ញុំស្ដាប់នោះ។ ដូច្នេះខ្ញុំបានប្រាប់ទៅផ្នែកបច្ចេកទេសរួចហើយថាយើងនឹងស្ដាប់ខ្សែអាត់នៃចម្លើយរបស់គាត់កាលពីថ្ងៃទី០៥ ខែមីនាឆ្នាំ ២០០៨ដែលគាត់បានលើកឡើងអំពីវគ្គរៀនសូត្រទាំងអស់នោះ។ គឺថានៅឆ្នាំ១៩៧៦ ដែលបង្រៀនដោយលោក ខៀវ សំផន។ ដូច្នេះខ្ញុំសូមការ អនុញ្ញាតពិលោកប្រធានដើម្បីអនុញ្ញាតឲ្យចាក់ខ្សែអាត់នេះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចបញ្ជាក់ឲ្យបានច្បាស់លាស់ជាងនេះបានទេ តើគោលបំណងនៃការស្នើសុំចាក់

ខ្សែអាត់សំឡេងនេះដើម្បីប្រយោជន៍អ្វីទៅ? ហើយតើការចាក់នេះគោលបំណងនៃការបង្ហាញភស្តុតាងលើអង្គហេតុណាមួយ? ហើយការចាក់នេះផ្នែក មីនុត ឬក៏ម៉ោង ទីប៉ុន្មាននៃខ្សែអាត់សំឡេងដើម្បីមានភាពច្បាស់លាស់ចំណុចណាមួយដែលមានបំណងចង់ឲ្យស្នើសុំឲ្យអង្គជំនុំជម្រះអនុញ្ញាត ហើយនិងឲ្យអង្គជំនុំជម្រះបង្គាប់រៀបចំចាត់ចែងដូច្នេះ?

[១៤:២១:៥៥]

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំនឹងអនុវត្តតាម។ គឺថាប្រធានបទនោះពាក់ព័ន្ធទៅនឹងការស្នើសុំកោះហៅសាក្សីរបស់សហព្រះរាជអាជ្ញា។ ខ្ញុំសូមអាននូវការជូនដំណឹងរបស់សហព្រះរាជអាជ្ញានៅពេលឆ្លើយតបទៅនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣។ គឺឯកសារលេខ E288/3 ការិយាល័យសហព្រះរាជអាជ្ញាស្នើសុំឲ្យកោះហៅសាក្សីរូបនេះដែលបញ្ជាក់ថា TCW-164 ហ្នឹងនិយាយអំពីវគ្គប្រជុំរៀនសូត្រនៅបុរីកីឡា ដែលក្នុងនោះលោកខៀវ សំផន បាននិយាយអំពីការចាប់ខ្លួន ប៉ង់ នៃមន្ទីរ៨៧០ ពីព្រោះគាត់ជាមនុស្សក្បត់ចូលដៃចូលជើងជាមួយយួន។ ដូច្នេះប្រតិចារឹកដែលខ្ញុំចង់ឲ្យអង្គជំនុំជម្រះបង្ហាញចាក់នោះគឺថា វាពាក់ព័ន្ធទៅនឹងចំណុចកន្លែងហ្នឹងហើយគឺពាក់ព័ន្ធទៅនឹងចម្លើយសាក្សីដែលគាត់ឆ្លើយអំពីវគ្គរៀនសូត្រនោះ។ ចំពោះម៉ោងនៃខ្សែអាត់នោះ -- ឯកសារ -- សូមទោស -- គឺឯកសារនោះគឺ D94/8R នេះជាឯកសារខ្សែអាត់។ ការសម្ភាសនោះគឺចាប់តាំងពីនាទី ៣៤:៣១វិនាទី រហូតទៅដល់ ៣៧នាទី, ៥២វិនាទី។

[១៤:២៣:៥០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

អ្វីដែលអង្គជំនុំជម្រះចង់ដឹងនោះលោកមេធាវី វែកគែន លោកស្តាប់ខ្ញុំឮទេ? លោកស្តាប់ខ្ញុំឮទេលោកមេធាវី? មួយ ពីរ បី លោកឮទេ ឮខ្ញុំទេ? តើអ្នកទាំងអស់គ្នាស្តាប់ឮខ្ញុំទេ? បាទ មិនមែនបញ្ហាថ្មទេ គឺបញ្ហាប្រព័ន្ធសំឡេង។

**លោក អាកទូរ វែកគែន៖**

លោកចៅក្រម យើងអត់មានឮសំឡេងលោកចៅក្រមជាភាសាបារាំងទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ចុះបើខ្ញុំដូរមីក្រូឮទេ? ឮខ្ញុំទេ? បាទ អត់ដដែលអ៊ីចឹងប្រហែលជាបញ្ហាហើយមើលទៅ។

ឥឡូវនេះឮទេ? ឮខ្ញុំនិយាយទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានបញ្ហាបច្ចេកទេសខាងចែកចាយសំឡេង។ ឥឡូវគេកំពុងតែធ្វើការត្រួតពិនិត្យ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:២៦:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ឥឡូវនេះ ឮហើយឬនៅ? បាទអ្វីដែលអង្គជំនុំជម្រះចង់បាននោះ គឺលោក វែកគែន គឺដូចតទៅ៖ លោកបានស្នើសុំចាក់ខ្សែអាត់ពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សីរូបនេះ។ ដូច្នេះអង្គជំនុំជម្រះចង់ដឹងថា តើមូលហេតុអ្វីជាក់លាក់ដែលលោកចង់ឲ្យចាក់ខ្សែអាត់ស្តាប់ចម្លើយរបស់គាត់? តើមានភាពខុសគ្នា មានភាពខ្វាស់ខ្វែងគ្នាទៅលើខ្លឹមសារនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរ នឹងខ្សែអាត់សំឡេង? ឬក៏គ្រាន់តែជាបញ្ហានៃសំឡេង ឬក៏ការលើកដាក់សំឡេងក្នុងការចោទសួរសាក្សីនៅពេលនោះ? អ្វីដែលលោកចង់នោះ សូមលោកបញ្ជាក់។ បើគ្រាន់តែជាបញ្ហាលើកដាក់សំឡេងទោះបីជាយើងស្តាប់ទៅក៏យើងពិបាកយល់អំពីលើកដាក់សំឡេងដែរ។

**លោក អាកទូរ វែកគែន៖**

បាទ លោកចៅក្រម គឺពិតហើយមានភាពខុសគ្នារវាងកំណត់ហេតុជាលាយលក្ខណ៍អក្សរហើយនិងខ្សែអាត់។ មិនត្រឹមតែខុសគ្នាទេ គឺយើងមើលទៅដូចជាមានបញ្ហាថែមទៀតផង គឺខ្ញុំមិននិយាយអំពីការលើកដាក់សំឡេងនៃការសួរសំណួរសាក្សីនៅពេលនោះទេ។

[១៤:២៧:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៨:២៧]

**ប្រធានអង្គជំនុំ៖**

លើសំណើសុំនេះ តើខាងសហព្រះរាជអាជ្ញាមានអ្វីចង់លើកឡើង ឬក៏កត់សម្គាល់អីដែរទេ?

**លោក ឃីត រេយ៉ន័រ៖**

យើងមិនជំទាស់ទេ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ចាក់នូវវីដេអូ ផ្នែកដែលពាក់ព័ន្ធទៅនឹងសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដែលបានស្នើសុំអម្បាញ់មិញនេះ គឺឯកសារ D94/8R ត្រង់នាទី ៣៣:៣១ រហូតដល់ ៣៧:៥៧ បាទ តាមសំណើសុំរបស់មេធាវីនៅលើអេក្រង់ទូរទស្សន៍។

**លោក អាកទូរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំសូមបញ្ជាក់ម្តងទៀត ចាប់ផ្តើមគឺនាទីទី៣៤ វិនាទីទី៣១ ហើយបញ្ចប់នៅនាទីទី៣៧ និងវិនាទី៥២ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ កែសម្រួលបាន ដូចសំណើសុំរបស់គាត់ ៣៤នាទី៣១វិនាទី ទៅដល់នាទី ៣៧:៥២វិនាទី។

**លោក អាកទូរ វែកកែន៖**

សូមអភ័យទោសលោកប្រធានគឺខ្ញុំ -- គឺថានាទីទី ៣៧:៥២វិនាទី។

**ប្រធានអង្គជំនុំ៖**

ដូចត្រឹមត្រូវហើយ មិនមានអីខុសទេ។ បកប្រែច្រឡំ ឬក៏យ៉ាងម៉េច? ច្បាស់ហើយ ហើយច្បាស់ហ្នឹងគឺចាក់តាមសំណើសុំរបស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន នូវខ្សែវីដេអូដែលគាត់បានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ!

[១៤:៣១:០៧]

*(ការបង្ហាញឯកសារសំឡេង)*

*"សួរ៖ លោក ខៀវ សំផន នៅឆ្នាំណា? ឆ្លើយ៖ តាំងពីឆ្នាំ៧៦ សួរ៖ ៧៦? ឆ្លើយ៖ ចាស។ សួរ៖ កាលនុំង ខៀវ សំផន មកម្នាក់ឯង? ឆ្លើយ៖ ចាស។ សួរ៖ ខៀវ សំផន ហ្នឹងមើលទៅគាត់អ្នកមានអំណាចទេ? ឆ្លើយ៖ មើលទៅគាត់ដូចជាមនុស្សយើងដូច--។ សួរ៖ ស្លូត ឬកាច ឬអីម៉េច? ឆ្លើយ៖ មិន*

*ជាកាចទេ។ សួរ៖ មិនកាចទេ? ឆ្លើយ៖ មើលទៅដូចធម្មតាៗ ឃើញយើងក្នុងរោងចក្រហ្នឹងហូបចុក ខ្វះខាតអីគាត់ចូលទៅមើលហ្នឹង គាត់អាចមើលគាត់ថា--។ សួរ៖ ឥឡូវខ្ញុំសួរនេះសិន--*

**ប្រធានអង្គជំនុំ៖**

មិនឃើញមានរូបទេ! ម៉េចអត់ឃើញរូប! មានតែសំឡេងទេ?

*"--សួរ៖ ទាក់ទិននឹងលោក ខៀវ សំផន គាត់មកបង្រៀនឆ្នាំ៧៦ គាត់បង្រៀននោះមានកម្មករ បុគ្គលិកចូលរួមប៉ុន្មាន? នៅឯណាដែរ បុរីកីឡា ឬស្តាត? ឆ្លើយ៖ នៅបុរីកីឡា..."។*

[១៤:៣១:៤៤]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកខាងផ្នែកខាងសោតទស្សន៍!

សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វ៉ែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ គឺអត់មានរូបទេ ហើយមានបញ្ហាបន្តិចពាក់ព័ន្ធទៅនឹងសំឡេង។ ឃ្លាទី១ គឺពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទ ហើយអត់មានការបកប្រែទេអម្បាញ់មិញនេះលោកប្រធាននៅពេលដែលចាក់នោះ។ ដូច្នេះសូមឲ្យខាល់មកចាក់ឡើងវិញ ដើម្បីឲ្យអ្នកបកប្រែគាត់អាចបកប្រែនូវសម្តីរបស់សាក្សីដែលឆ្លើយតាំងពីដំបូង។

**ប្រធានអង្គជំនុំ៖**

ខាងផ្នែកសោតទស្សន៍ចាក់ផ្សាយនូវខ្សែអាត់សំឡេងនេះសាជាថ្មីម្តងទៀត!

[១៤:៣២:៤៥]

*(ការបង្ហាញឯកសារសំឡេង)*

*"សួរ៖ លោក ខៀវ សំផន នៅឆ្នាំណា? ឆ្លើយ៖ តាំងពីឆ្នាំចិត ៧៦ សួរ៖ ៧៦? ឆ្លើយ៖ ចាស។ សួរ៖ កាលនុ៎ង ខៀវ សំផន មកម្នាក់ឯង? ឆ្លើយ៖ ចាស។ សួរ៖ ខៀវ សំផន ហ្នឹងមើលទៅគាត់អ្នកមានអំណាចទេ? ឆ្លើយ៖ មើលទៅគាត់ដូចជាមនុស្សយើងដូច--។ សួរ៖ ស្លូត ឬកាច ឬអីម៉េច? ឆ្លើយ៖ មិនជាកាចទេ។ សួរ៖ មិនកាចទេ? ឆ្លើយ៖ មើលទៅដូចធម្មតាៗ ឃើញយើងក្នុងរោងចក្រហ្នឹងហូបចុកខ្វះខាតអី គាត់ចូលទៅមើលហ្នឹង គាត់អាចមើលគាត់ថា--។ សួរ៖ ឥឡូវខ្ញុំសួរនេះសិន ទាក់ទិននឹងលោក ខៀវ សំផន គាត់មកបង្រៀនឆ្នាំ៧៦ គាត់បង្រៀននោះ មានកម្មករ បុគ្គលិកចូលរួមប៉ុន្មាន? នៅ*

ឯណាដែរ បុរីកីឡា ឬស្តាត? ឆ្លើយ៖ នៅបុរីកីឡាដដែល។ សួរ៖ បុរីកីឡាដដែល។ គាត់ប្រជុំពីអី? ឆ្លើយ៖ ដូចតែគ្នាលោកគ្រូ។ សួរ៖ ខ្លឹមសារដូចគ្នា? ឆ្លើយ៖ ចាស។ សួរ៖ ស្អីខ្លះដូចគ្នាហ្នឹង ជួនកាលគាត់និយាយខុសគ្នា? ឆ្លើយ៖ អ្ហ៎! អារឿង១ឆ្នាំប្រជុំម្តងគ្មានអីឲ្យខំធ្វើការទេ។ សួរ៖ គាត់មាននិយាយពីរឿងពួកក្បត់ពួកអីទេ? ឆ្លើយ៖ អត់ទេ។

[១៤:៣៣:៣៩]

សួរ៖ មិននិយាយពីរឿងពួកក្បត់ទេ? ឆ្លើយ៖ ហ្នឹងហើយ ឲ្យទាន់ផែនការមួយហិកតាប៉ុន្មានតោនជំនាន់នុ៎ង។ សួរ៖ និយាយថាខំធ្វើការទៅ? ឆ្លើយ៖ ចាស ឲ្យយើងសន្សំសំចៃ ឲ្យមានដើមទុនអ៊ីចឹង។ សួរ៖ ម៉េចទៀតទៅ? ឆ្លើយ៖ ដូចថារៀននុ៎ង ការពីព្រឹកហ្នឹង ប៉ុន្តែទៅប្រជុំពាក់ព័ន្ធខ្លួនឯងហ្នឹងតមបួនប្រាំថ្ងៃ ធ្វើបានទាន់ផែនការអត់ បើយើងធ្វើទាន់យើងប្រាប់គេថាទាន់ បើយើងមិនទាន់ទេ គុណវិបត្តិយើងវាម៉េចបានជាមិនទាន់ ដេរមិនគ្រប់ចំនួនអ៊ីចឹងលោកគ្រូ។ សួរ៖ អ៊ីចឹងគាត់និយាយតែពីរឿងបញ្ហាការងារ? ឆ្លើយ៖ ចាស។ សួរ៖ អត់និយាយរឿងនយោបាយទេ? ឆ្លើយ៖ អត់ទេ។ សួរ៖ អ៊ីចឹងរឿងនយោបាយគាត់អត់និយាយទេ? ឆ្លើយ៖ នយោបាយមានដែរថា យើងមានស៊ីមានចុក វាមិនពឹងពាក់បរទេសអីអ៊ីចឹង អាហ្នឹងចូលនយោបាយដែរណ៎ាគ្រូណ៎ា។ សួរ៖ ចុះមាននិយាយពួកវៀតណាមឈ្លានពានអីយ៉ាងម៉េចៗទេ? ឆ្លើយ៖ អត់ទេ។ សួរ៖ ពួកណាក្បត់អីអត់និយាយទេ? ឆ្លើយ៖ អត់ សួរ៖ អ៊ីចឹងគាត់និយាយខុស នួន ជា? និយាយខុសគ្នាអ៊ីចឹង? ឆ្លើយ៖ (សើច) សួ៖អ៊ីចឹង? ប្រាប់ខ្ញុំអំមិញថានិយាយដូចគ្នា ប៉ុន្តែ នួន ជា និយាយរឿងក្បត់រឿងអីណាច្រើនណាស់។ អ៊ីចឹងប្រជុំបានតែពីរដងទេ? ឆ្លើយ៖ ភូមិភាគឧត្តរក្បត់ផ្សេង ភូមិភាគបូព៌ាក្បត់ អើ! គាត់និយាយដែរពីជំនាន់នុ៎ង ចាប់នៅមន្ទីរគាត់ គេហៅមន្ទីរ៨៧០ តែឮគេនិយាយទេ។ សួរ៖ គាត់និយាយថាម៉េច? ខៀវ សំផន និយាយថាម៉េច? ឆ្លើយ៖ មេឈ្មោះអាអីឈ្មោះ ប៉ង់ អ៊ីចឹងក្បត់ រត់ទៅចូលយួនចូលអីអ៊ីចឹងណ៎ា ខ្សែរយៈហ្នឹង។ សួរ៖ ចាប់មេប៉ង់? ឆ្លើយ៖ ហ្នឹងហើយ ប្រធានមន្ទីរ៨៧០។ សួរ៖ ប្រធានមន្ទីរ៨៧០ គាត់ថាគេចាប់ឈ្មោះ ប៉ង់ អ៊ីចឹង? ឆ្លើយ៖ ហ្នឹងហើយ គាត់ថាអ៊ីចឹង។ សួរ៖ ដោយសារថា ដោយសារតែម៉េច? ឆ្លើយ៖ ដោយសារក្បត់។ សួរ៖ ដោយសារក្បត់ ចូលឯណា? ឆ្លើយ៖ ចូលដៃ ចូលជើង-- សួរ៖ ចូលដៃជាមួយយួន? ឆ្លើយ៖ហ្នឹងហើយ។ សួរ៖ គេយក-- គេមានប្រាប់ថាយក ប៉ង់ ទៅណាទេ? ឆ្លើយ៖ ប្រាប់ថាគេចាប់យកទៅបាត់ហើយ។ សួរ៖ គ្រាន់ប្រាប់ប៉ុណ្ណឹង។ យកទៅបាត់ហើយ? ឆ្លើយ៖ ចាស។ សួរ៖ មន្ទីរ៨៧០ កាលសម័យហ្នឹងមីងស្គាល់ថាជាស្អី ៨៧០? ឆ្លើយ៖ អត់! ឮតែគេថា ឮតែគាត់លើកមកមន្ទីរ៨៧០។ សួរ៖ មិនដឹងថា

*មន្ទីរ ៨៧០ហ្នឹងស្អីទេ? ឆ្លើយ៖ ប៉ុន្តែមន្ទីរ៨៧០ហ្នឹងវាទាក់ទងមកអង្គភាពខ្ញុំហ្នឹងដែរ អង្គភាពកន្លែងកាត់ដេរហ្នឹង គេថាមន្ទីរធំតែមួយ គ្រាន់តែសាខាខុសគ្នាលោកគ្រូ។ សួរ៖ គាត់លើកអ៊ីចឹង? ឆ្លើយ៖ចាស។ សួរ៖ តាំងពីនុំងមកមានដែលលើកអីទៀត ពីរឿងចាប់ រឿងចង រឿងធ្វើអី? ឆ្លើយ៖ អត់។ សួរ៖ អត់ដែលមានឮអីទេ? ឆ្លើយ៖ ទេ រហូតដល់ជិតរត់ហ្នឹងលោកគ្រូ នៅតែមានចាប់នៅរពុយៗដែរ។ សួរ៖ អ៊ីចឹង? ឆ្លើយ៖ ចាស។”*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង)*

[១៤:៣៦:២៨]

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធាន ឃ្លាដែលខ្ញុំចង់លើកនិយាយនោះគឺថាអត់ត្រូវបានបកប្រែជាភាសាបារាំងទេ ខ្ញុំដឹងពីព្រោះថាក្រុមរបស់ខ្ញុំស្តាប់ជាភាសាខ្មែរ ហើយគាត់បានបញ្ជាក់ថាគាត់បានឮឃ្លាហ្នឹងជាភាសាខ្មែរ ក៏ប៉ុន្តែការបកប្រែជាភាសាបារាំងគឺមានឃ្លាពីរ ខ្ញុំអត់បានឮទេ គឺអ្នកបកប្រែបានរំលង។ ដូច្នេះខ្ញុំមិនដឹងថា តើធ្វើយ៉ាងម៉េចចំពោះចំណុចនេះ? ខ្ញុំដឹងថាយើងគួរតែស្តាប់ឡើងវិញ ឬក៏ខ្ញុំគួរតែប្រគល់ការបកប្រែជាភាសាបារាំង ដែលត្រូវបានធ្វើឡើងដោយអ្នកបកប្រែនៃការិយាល័យរបស់យើងខ្ញុំដោយសហការជាមួយនឹងអ្នកបកប្រែនៃតុលាការ។ ដូច្នេះតើលោកប្រធានណែនាំ តើខ្ញុំគួរធ្វើយ៉ាងម៉េច? ឬមួយក៏ខ្ញុំត្រូវអានឃ្លាពីរដែលខ្ញុំចង់លើកមកនិយាយតែមិនត្រូវបានបកប្រែជាភាសាបារាំងនោះ?

[១៤:៣៧:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤០:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ឆ្លើយតបទៅនឹងការលើកឡើងចុងក្រោយដោយមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន អម្បាញ់មិញនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អ្វីដែលយើងចង់ឲ្យលោកយល់នោះ គឺថាតើលោកមានបានស្នើសុំការបកប្រែផ្លូវការនៃផ្នែកដែលលោកចង់ឲ្យលោកបកប្រែទាំងស្រុងហ្នឹងដែរឬទេ? ក៏ប៉ុន្តែនៅពេលថ្ងៃនេះហ្នឹង យើងមិនអាចផ្អែកទៅលើការបកប្រែក្រៅផ្លូវការទេ។ ទាល់តែលោកមានការបកប្រែផ្លូវការពីផ្នែក

បកប្រែតុលាការ ទើបយើងអាចធ្វើអ៊ីចឹងបាន។

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំដឹងលោកចៅក្រម គឺថាជាការលំបាកខាងក្រុមយើង។ យើងបានដឹងអំពីការប្រជុំអំពីពាក់ព័ន្ធទៅនឹងទំព័រនៃសារណាបញ្ចប់ ហើយយើងអត់មានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការបែបនេះទេ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកស្រី ខ្ញុំបានបង្ហាញអំពីផ្នែកដំបូងនៃកិច្ចសម្ភាសន៍របស់លោកស្រីដែលគេបាន សម្ភាស កាលពីខែមីនា ឆ្នាំ២០០៨។ លោកស្រីបានឆ្លើយថា វគ្គរៀនសូត្រដែលបង្រៀនដោយលោក ខៀវ សំផន នោះគឺថានៅឆ្នាំ១៩៧៦ ហើយលោកស្រីក៏បានឆ្លើយបញ្ជាក់ជូនសហព្រះរាជអាជ្ញាផងដែរ។ ហើយលោកស្រីក៏បានឆ្លើយជូនខ្ញុំនៅពេលដែលខ្ញុំចាប់ផ្តើមសួរ។ ដូច្នេះ ខ្ញុំសួរលោកស្រីម្តងទៀត។ តើចម្លើយរបស់លោកស្រីគឺមួយណាពាក់ព័ន្ធទៅនឹងឆ្នាំដែលលោកស្រីបានចូលរួមនៅក្នុងវគ្គរៀនសូត្រ ដែលទំនងជាបង្រៀនដោយលោក ខៀវ សំផន នោះ?

[១៤:៤២:៣២]

**លោកស្រី ឯក ហេន៖**

**ឆ៖** បើនិយាយទៅវាយូរដែរហើយ។ ការចងចាំក៏មានភ្លេចភ្លាំងខ្លះចាស។ ប៉ុន្តែការរៀនសូត្រវាមានពីរវគ្គ ដូចខ្ញុំលើកឡើងអ៊ីចឹង។ ប៉ុន្តែវគ្គទី១ មិនទាន់មានខ្សែរយៈក្បត់ទេចាស។ វគ្គទី២បានមាន។ វគ្គទី២បានមានខ្សែរយៈលើកឡើងថា ភូមិភាគឧត្តរក្បត់ហ្នឹង ចាសបានមាន។ វគ្គទី១ហ្នឹង នៅឡើយទេអត់ទាន់មានទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី អរគុណសាក្សី។ ដោយឡែកដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំនៅរង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក។ ហើយសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក អាកទ្វរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទ្វរ វែកគែន៖**

**ស៖** លោកស្រីសាក្សីមុនពេលសម្រាកនេះបន្តិច លោកស្រីបានឆ្លើយថា នៅពេលប្រជុំរៀនសូត្រដែលលោកស្រីបានចូលរួមនោះ ឥឡូវនេះលោកនិយាយថា លោក ខៀវ សំផន ជាអ្នកបង្រៀន ហើយគាត់បាននិយាយអំពីការក្បត់របស់មនុស្សនៅភូមិភាគឧត្តរ។ បើអ៊ីចឹងឥឡូវខ្ញុំសូមអានសម្រង់មួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីថ្ងៃទី០៥ មីនា ឆ្នាំ២០០៨, ឯកសារ E3/474, ERNជាភាសាបារាំង គឺ 00205054, ជាភាសាខ្មែរគឺ 00172064 ដល់ 65, ជាភាសាអង់គ្លេសគឺ 00205049 ដល់ 50។ លោកស្រីបានលើកឡើងដូចតទៅនេះ -- លើកចំណុចពីរ។ ទី១ លោកស្រីនិយាយថា ការប្រជុំរៀនសូត្រទី១ដែលមានធ្វើនៅបុរីកីឡា គឺលោក ខៀវ សំផន ជាអ្នកបង្រៀន ហើយខាងក្រោមហ្នឹងបន្តិចទំព័រដដែល គឺថាលោក នួន ជា ក៏បង្រៀនម្តងដែរនៅបុរីកីឡានៅឆ្នាំ១៩៧៨។ ហើយក្រោមហ្នឹងបន្តិចទៀតគឺថាពួកគាត់ក៏បានលើកឡើងអំពីការក្បត់របស់បុគ្គលមួយចំនួននៅភូមិភាគឧត្តរ ហើយសុំកុំឲ្យកម្មករកម្មការិនីចូលរួមអំពើក្បត់ទាំងអស់នេះ។ ដូច្នេះ លោកស្រី អ្វីដែលលោកស្រីបាននិយាយឥឡូវនេះ ដូចជាមិនដូចអ្វីដែលលោកស្រីបាននិយាយនៅថ្ងៃទី០៥ មីនា ឆ្នាំ២០០៨ ទៅអ្នកស៊ើបអង្កេតនៃតុលាការយើងនេះទេ។ អ៊ីចឹងខ្ញុំសូមឲ្យអ្នកស្រីពន្យល់ពីចំណុចខុសគ្នានេះជូនតុលាការ។ សូមអញ្ជើញ!

[១៥:០៤:៤៣]

**លោកស្រី ឯក ហេន៖**

**ឆ៖** ខ្ញុំសូមគោរពលោកតុលាការ។ ការនិយាយសំណួរទាំងពីរនេះបានន័យថាវាពាក់ព័ន្ធច្រឡំគ្នា។

ដូច្នេះការពាក់ព័ន្ធច្រឡំគ្នា ដូច្នេះវា បើនិយាយទៅវាយូរមកហើយ វាអាចភាន់ច្រឡំខ្លះដែរ មិនមែនមិនថាភ័ន្តច្រឡំទេ។ ដូចថា រៀនវគ្គទី១ និងវគ្គទី២។ ដូច្នេះវាវគ្គទី១ គឺផ្សេង។ វគ្គទី២ គឺផ្សេង។ វគ្គទី១ ពីជំនាន់នុំងមិនទាន់មានទេ ខ្សែរយ:ក្បត់។ វគ្គទី២ ទើបមាន។ ដូច្នេះវាច្រឡំសំណួរគ្នា។ សំណួររៀនឆ្នាំលើកទី១, រៀនលើកទី២ ចាស។

**ស៖** បាទ លោកស្រីមិនប្រែប្រួលទេ ត្រង់ចំណុចថា មានការប្រជុំពីរដងនេះ ក៏ប៉ុន្តែលោកស្រីត្រូវដឹងថាអ្វីដែលខ្ញុំចាប់អារម្មណ៍ចង់ដឹងនោះ គឺថាតើអ្នកស្រីអាច ឬក៏មិនអាច, បើមិនអាចទេ ប្រាប់ខ្ញុំតាមត្រង់ទៅព្រោះថា ៤០ឆ្នាំបានកន្លងផុតទៅហើយ។ តើអ្នកស្រីអាចជម្រាបជូនតុលាការនៅថ្ងៃនេះបានដែរឬទេថា អ្នកណាជាអ្នកបង្រៀននៅពេលប្រជុំលើកទី១ ហើយអ្នកណាជាអ្នកបង្រៀននៅពេលប្រជុំលើកទី២?

**ឆ៖** ចាស ដូច្នេះវគ្គទី១ គឺលោក នួន ជា។ វគ្គទី២ គឺលោក ខៀវ សំផន នៅឆ្នាំ៧៨ ចាស។

[១៥:០៦:៤៧]

**ស៖** បាទ លោកស្រី ៗទើបតែនិយាយថា អង្គហេតុទាំងអស់នោះបានកន្លង -- រឿងហេតុទាំងអស់នោះបានកើតឡើងតាំងពីយូរណាស់មកហើយ ហើយ៤០ឆ្នាំហើយ ហើយបួនឆ្នាំមុននេះៗ លោកស្រីបាននិយាយខុសអំពីអ្វីដែលលោកស្រីទើបតែនិយាយអម្បាញ់មិញនេះ។ បួនឆ្នាំមុន លោកស្រីបាននិយាយថា "ក្នុងពេលបង្រៀនលើកទី១ គឺលោក ខៀវ សំផន ហើយលើកទី២ គឺជាលោក នួន ជា គឺជាអ្នកបង្រៀន"។ អ៊ីចឹងតើលោកស្រីអាចច្រឡំបានទេ នៅពេលដែលលោកស្រីអះអាងយ៉ាងដាច់អហង្ការបែបនេះ ឬក៏លោក ឬក៏លោកស្រីអាចមានការមន្ទិលសង្ស័យណាមួយទាក់ទងទៅនឹងអ្នកបង្រៀនលើកទី១ និងលើកទី២ នេះដែរឬទេ?

**ឆ៖** ការរៀន គឺមានរៀនពិតមែន គ្រាន់តែថាវាយល់ច្រឡំទាំងពីរហ្នឹង ដូចថា មិនដឹងថា លោកអ៊ំ -- ខ្ញុំថា ដូចថាចងចាំ ថាលោកអ៊ំ នួន ជា ហ្នឹងគាត់បានបង្រៀនមុន។ បន្ទាប់ក្រោយមកគឺលោកអ៊ំ ខៀវ សំផន ហ្នឹងគាត់បង្រៀនក្រោយចាស។

[១៥:០៨:១២]

**ស៖** កាលពីព្រឹកមិញនៅពេលដែលលោកស្រីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ពេលដែលអ្នកស្រីចាប់ផ្តើមនិយាយអំពីវគ្គរៀនសូត្រដែលលោក ខៀវ សំផន ជាអ្នកបង្រៀន លោកស្រីបានឆ្លើយថា ខៀវ សំផន បានប្រាប់អ្នកដែលចូលរួមរៀននោះ ថាត្រូវតែសាមគ្គីគ្នា ពីព្រោះថាសង្គ្រាមចប់

ហើយ។ តើការកត់សម្គាល់របស់លោកស្រីកាលព្រឹកមិញនេះ វាមិនអាចជាចំណងផ្សារភ្ជាប់ជាមួយនឹងការដែលថា លោក ខៀវ សំផន បានមកចូលរួមធ្វើសេចក្តី -- មកបង្រៀនហ្នឹងគ្រាន់តែថា មុន នួន ជា ដោយសារសង្គ្រាមចប់ភ្លាមលោក ខៀវ សំផន មកបង្រៀនភ្លាម។ ព្រោះថា លោក ខៀវ សំផន បាននិយាយថា សង្គ្រាមទើបនឹងចប់។ យ៉ាងម៉េចដែរ លោកស្រីយល់យ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:០៩:២៦]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធាន ខ្ញុំយល់ឃើញថារបៀបចោទសំណួររបស់សហភាតារបស់ខ្ញុំនេះ ជាការសួរនាំមុខ ហើយដោយសារគាត់ចង់ឲ្យសាក្សីនឹងត្រឡប់មកកែប្រែចម្លើយរបស់ខ្លួនកាលពីព្រឹកមិញនោះ។ អ៊ីចឹងខ្ញុំយល់ឃើញថា របៀបសួរនេះមិនសមស្របទេ មិនអាចសួរអ៊ីចឹងបានទេលោកប្រធាន។

**លោក អាកឡូវ វែកគែន៖**

បាទ លោកប្រធានខ្ញុំសូមឆ្លើយតប។ ខ្ញុំសូមរំឭកថាកាលពីព្រឹកមិញសហព្រះរាជអាជ្ញាបានអានចម្លើយខែមីនា ឆ្នាំ២០០៨ របស់លោកស្រីសាក្សី។ ហើយនៅក្នុងវគ្គដែលគាត់អាននុ៎ង សាក្សីឆ្លើយថា ប្រជុំលើកទី១ គឺលោក ខៀវ សំផន នៅឆ្នាំ១៩៧៦ ហើយវគ្គរៀនសូត្រទី២ នៅឆ្នាំ១៩៧៨ គឺលោក នួន ជា ជាអ្នកបង្រៀន។ អ៊ីចឹងនៅពេលដែលខ្ញុំសួរគាត់ឥឡូវនេះមានរឿងរ៉ាវផ្ទុយគ្នាច្រើន។ អ៊ីចឹងខ្ញុំខំព្យាយាមឲ្យយល់អំពីអ្វីដែលកើតឡើង គឺថាយល់ពីចម្លើយរបស់សាក្សីនេះ ដើម្បីឲ្យយល់អ៊ីចឹងវាត្រូវបំភ្លឺអំពីកាលបរិច្ឆេទមួយចំនួន។ អ៊ីចឹងទាញចេញ -- លើកឡើងអំពីការប្រជុំរបស់លោក ខៀវ សំផន នេះជាមួយនឹងជោគជ័យ ជ័យជម្នះថ្ងៃទី១៧ មេសា ៧៥នេះភ្លាមៗ ដោយចង់បញ្ជាក់ថាកិច្ចប្រជុំ ឬក៏វគ្គរៀនសូត្រដែលលោក ខៀវ សំផន បង្រៀននោះគឺវានៅជិតថ្ងៃជ័យជម្នះទេ។ អ៊ីចឹងខ្ញុំគិតថា ជាការសមហេតុសមផលណាស់ដែលយើងលើកបញ្ហានេះមកនិយាយវែកញែក។

[១៥:១១:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១២:៣០]

**ប្រធានអង្គជំនុំ៖**

សំណួរដែលលោកមេធាវីបានសួរនេះ អង្គជំនុំជម្រះបានស្តាប់ច្រើនលើកច្រើនសាមកហើយ សមល្មមនឹងអាចអង្គជំនុំជម្រះយកទៅពិចារណាបានហើយ។ ហើយប្រសិនបើមានសំណួរផ្សេងទៀត សូមលោកបន្តនូវសំណួរថ្មីបន្តទៅទៀតទៅ លោកមេធាវី!

**លោក អាកទ្ធូរ វែកគែន៖**

បាទ លោកប្រធានខ្ញុំកត់ត្រាទុក។ ខ្ញុំឥឡូវចូលទៅនិយាយពីចំណុចផ្សេងទៀត។

**សួរដោយលោក អាកទ្ធូរ វែកគែន៖**

**ស៖** លោកស្រីសាក្សីនៅពេលដែលលោកស្រីឆ្លើយទៅព្រះរាជអាជ្ញាកាលព្រឹកមិញ លោកស្រីបាននិយាយថា លោកស្រីពុំបានចូលរួមវគ្គរៀនសូត្រដែល ប៉ង់ បានបង្រៀនទេ។ តើលោកស្រីមានបានចាំអំពីអ្វីដែលលោកស្រីបាននិយាយកាលពីព្រឹកមិញហ្នឹងទេ?

[១៥:១៣:៣៩]

**លោកស្រី ឯក ហេន៖**

**ឆ៖** ចាំនូវសំណួរណាទៅ?

**ស៖** លោកស្រី ខ្ញុំមិនអាចឲ្យម៉ោងច្បាស់លាស់បានទេ គឺទំព័រ១៦ នៃកំណត់ត្រារបស់ខ្ញុំរហូតដល់ទំព័រ១៨ ១៦ដល់១៨-- អ៎! ១៧ដល់១៨ គឺថានៅភាគបញ្ចប់នៃចម្លើយរបស់លោកស្រី នៅក្នុងចំណោមសំណួរចុងក្រោយដែលគេសួរទៅលោកស្រី នៅពេលដែលគេទៅស៊ើបអង្កេតនោះ។

ខ្ញុំកត់សម្គាល់ឃើញថា លោកស្រីបានឆ្លើយថា “ខ្ញុំពុំបានចូលរួមរៀនជាមួយ ប៉ង់ នោះទេ ក៏ប៉ុន្តែខ្ញុំបានចូលរៀន រៀនសូត្រពេលដែល នួន ជា ហើយ ខៀវ សំផន បង្រៀនតែប៉ុនន៎ុងទេ”។ បាទ ឥឡូវនេះលោកស្រីអាចនិយាយផ្សេងពីហ្នឹង ឬក៏អាចលោកស្រីបានចូលរួមរៀនសូត្រជាមួយ ប៉ង់ ឬក៏មិនចូលរួម? តើអ្នកស្រីបានចូលរួម ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ទេ ខ្ញុំដូចជាមិនដែលបានចូលរួមរៀនជាមួយគាត់ផង។

**ស៖** យើងបានលើកឡើងហើយនៅថ្ងៃទី០៦ កក្កដា ឆ្នាំ២០០៣ លោកស្រីបានជួបលោក ឡុង ដានី ដែលនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់បានសួរលោកដូចតទៅនេះ -- គាត់បានសួរលោកស្រីដូចតទៅនេះ -- នៅទំព័រទី៧ នៃកិច្ចសម្ភាសន៍របស់លោកស្រី ដូចដែលមានសរសេរជាភាសាបារាំង ERN 00795296, អង់គ្លេសគឺ 00662015 ហើយជាភាសាខ្មែរគឺ 00019582។ នេះជាចម្លើយរបស់លោក

ស្រីឆ្លើយទៅ ឡុង ដានី នៅឆ្នាំ -- ខែកក្កដា ២០០៣។ សំណួរ ស៊ី.ឌី.ខេម ដូចតទៅនេះ៖

[១៥:១៦:៤០]

“ដូច្នេះមាន ខៀវ សំផន នួន ជា ចុះអ្នកផ្សេងទៀត? ចម្លើយ៖ មានតែ ប៉ង់ នៅមន្ទីរ៨៧០។ ហើយអ៊ីចឹងមានតែ ប៉ង់ នៅមន្ទីរ៨៧០? ចម្លើយ៖ ចាស។ សំណួរ៖ តើគាត់ទៅបង្រៀននៅកន្លែងហ្នឹងដែរ? ចម្លើយ៖ ចាស។ ថាតើគាត់បង្រៀនអីដែរនៅទីនោះ? ចម្លើយ៖ “បង្រៀនពីរឿងការតស៊ូកុម្មុយនីស្តអ៊ីចឹង។ មាននិយាយរឿងផ្សេងទៀតដែរ តែខ្ញុំភ្លេចអស់ហើយ”។

លោកស្រី មើលតាមរយៈចម្លើយរបស់លោកស្រីនេះ នៅឆ្នាំ២០០៣ នោះលោកស្រីបានចាំថា លោកស្រីបានចូលរួមរៀនសូត្រដែល ប៉ង់ ជាអ្នកបង្រៀន ហើយលោកស្រីថែមទាំងនិយាយអំពីខ្លឹមសារនៃវគ្គរៀនសូត្រហ្នឹងទៀតផង។ អ៊ីចឹងលោកស្រីពន្យល់ពីហេតុផលយ៉ាងម៉េច ចំពោះការដែលថាថ្ងៃនេះៗ លោកស្រីនិយាយថាលោកស្រីមិនបានចូលរួមរៀនសូត្រជាមួយ ប៉ង់ នោះទេ។ អ្នកស្រីអាចបំភ្លឺតុលាការបន្តិចបានទេ?

[១៥:១៧:៥៥]

**ឆ៖** សូមគោរពលោកតុលាការ! កន្លែងណាខ្ញុំចាំគឺខ្ញុំឆ្លើយ កន្លែងណាមិនចាំគឺខ្ញុំមិនបានឆ្លើយ។ ដូច្នេះ ការចងចាំមិនបានគឺចាត់ទុកថាខ្ញុំអត់បានដឹង។ ព្រោះវាអត់ចាំ វាកន្លងយូរឆ្នាំហើយ ដូចឃើញស្រាប់ហើយ។

**ស៖** កាលពីព្រឹកមិញ សហព្រះរាជអាជ្ញាបានសួរលោកស្រីថា តើការរៀនសូត្រហ្នឹងអស់រយៈពេលប៉ុន្មាន គឺការរៀនសូត្រដែលលោកស្រីបានចូលរួម។ ការរៀនសូត្រដែលលោក ខៀវ សំផន ជាអ្នកបង្រៀននោះ។ ហើយលោកស្រីឆ្លើយថា ១ថ្ងៃ។ ហើយបន្ទាប់ពីវគ្គដែលខ្ញុំទើបបានដកស្រង់អម្បាញ់មិញពីកិច្ចសម្ភាសន៍របស់លោកស្រីដែលផ្តល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថ្ងៃទី០៦ កក្កដា ឆ្នាំ២០០៣ គឺសំណួរបន្តហ្នឹងបន្តិចទៀតនោះ ដែលខ្ញុំទើបអានអំមិញហ្នឹង សម្រង់ដែលខ្ញុំទើបអានអំមិញហ្នឹង។ ដានីសួរលោកស្រី៖ “ចុះអ្នកទាំងអស់នុ៎ង ខៀវ សំផន, នួន ជា និង ប៉ង់ ហ្នឹងមកបង្រៀនរយៈពេលប៉ុន្មានរាល់ដងនោះ? ចម្លើយ៖ រៀនម្តងមួយអាទិត្យ”។ លោកស្រី សំណួរខ្ញុំដូចគ្នាដដែលទេ។ តើអ្នកស្រីមានការកត់សម្គាល់យ៉ាងម៉េចដែរទៅលើភាពខុសគ្នានេះ ទាក់ទងទៅនឹងរយៈពេលនៃការបង្រៀនដែលមនុស្សទាំងបីហ្នឹងដែលខ្ញុំទើបនឹងរៀបរាប់ឈ្មោះអម្បាញ់មិញហ្នឹង គាត់បានបង្រៀននេះ។ លោកស្រីមានមតិយោបល់យ៉ាងម៉េចដែរ?

**ឆ៖** ការរៀនសូត្រគឺមានដូចខ្ញុំថាអ៊ីចឹង ប៉ុន្តែចេញទៅតាមកង តាមក្រុមដល់ម៉ោងធ្វើការៗ រួចពីការងារអាចប្រជុំដកស្រង់រៀនសូត្រពីគ្នាទៅវិញទៅមក រយៈកាលមួយអាទិត្យមែន។ តែវិលត្រឡប់ទៅកន្លែងវិញរយៈកាលក្នុងមួយអាទិត្យហ្នឹងទើបចប់។ តែរៀនរយៈកាលតែមួយព្រឹកទេ ចេញទៅរៀនខ្លួនឯងតាមក្រុមមួយអាទិត្យទៀត។ ប្រជុំមួយអាទិត្យទៀតចាស។

[១៥:២១:០១]

**ស៖** អ៊ីចឹងបានន័យថា អ្នកចូលរួមរៀនសូត្រនោះត្រឡប់ទៅរៀនវិញនៅថ្ងៃបន្ទាប់ ហើយគ្រូបង្រៀនហ្នឹងមកបង្រៀនដដែល ឬក៏យ៉ាងម៉េច? លោកស្រីចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** គ្រូបង្រៀនអត់មានមកទៀតទេ។ ពួកនាងខ្ញុំវិលត្រឡប់ទៅវិញ គឺរៀនមើលកំហុសគ្នាទៅវិញទៅមកចាស។ លើកពីគុណសម្បត្តិ គុណវិបត្តិខ្លួនឯង។ យើងខ្វះខាតអី យើងរាយការណ៍ជូនសមូហភាពទៅ។ ខ្ញុំមានគុណសម្បត្តិធំ ខ្ញុំមានគុណវិបត្តតូច។ យើងលើកឡើងពាក់ព័ន្ធគ្នាម្តងម្នាក់ ខ្វះខាតជួយទិតៀនកសាងគ្នា គឺសម័យហ្នឹងគឺអ៊ីចឹង។ ចាស មានប៉ុណ្ណឹង។

**ស៖** ប៉ុន្តែថ្ងៃបន្ទាប់ហ្នឹង មានគ្រូបង្រៀនថ្មីទៀតទេ ឬក៏អត់មានទេ?

**ឆ៖** ចាស អត់មានទេ។

**ស៖** អ៊ីចឹងគឺថាវគ្គរៀនសូត្រដែលលោកស្រីបានចូលរួមនោះមានរយៈពេលតែ១ថ្ងៃ ឬក៏មានរយៈពេលមួយសប្តាហ៍?

**ឆ៖** ដូចខ្ញុំលើកឡើងអ៊ីចឹងថា រៀនតែ១ថ្ងៃ តែចេញទៅវិញប្រជុំកសាងគ្នាមួយអាទិត្យ។ ឆ្លៀតចន្លោះពេលទំនេរប្រជុំពីរបីម៉ោងអ៊ីចឹងទៅ រំសាយទៅការងារវិញ។ ដូច្នេះ មួយអាទិត្យទើបចប់។ ដោះស្រាយបញ្ហាម្តងម្នាក់។

**ស៖** ហើយការធ្វើអ៊ីចឹងជួបប្រជុំគ្នាឯងហ្នឹង ពេញ១ឆ្នាំតែម្តង ឬក៏គ្រាន់តែថាបន្ទាប់ពីប្រជុំហ្នឹងទេ រយៈពេលខ្លីបន្ទាប់ពីប្រជុំ ឬក៏ធ្វើពេញ១ឆ្នាំហ្នឹង ធ្វើអ៊ីចឹងរហូត?

[១៥:២៣:៤២]

**ឆ៖** ក្នុង១ឆ្នាំគឺម្តង។ អាហ្នឹងគេហៅថាប្រជុំផ្លងជីវទស្សន៍ពាក់ព័ន្ធកំហុសខ្លួនឯង លើកគុណសម្បត្តិ វិបត្តិខ្លួនឯងតែម្តងចាស។

**ស៖** លោកស្រី តើលោកស្រីចាំដែរឬទេថាតើលោក ខៀវ សំផន ប្រហែលជាបានមកធ្វើទស្សនកិច្ចនៅរោងចក្ររបស់លោកស្រីហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** បើតាមខ្ញុំដឹង គាត់ចូលពីរ ឬបីដងប៉ុណ្ណឹងទេចាស។

**ស៖** បាទកាលពីព្រឹកមិញលោកស្រីបាននិយាយថា គាត់បានមកបី ឬបួនដង។ ឥឡូវនិយាយថាពីរ ឬបីដង។ អ៊ីចឹងបានន័យថាបើតាមការចងចាំរបស់លោកស្រីហ្នឹងមិនសូវជាច្បាស់ទេ ចន្លោះពីពីរទៅបួនដងហ្នឹងឬក៏យ៉ាងម៉េច? គឺថាលោកស្រីមិនសូវជាចាំច្បាស់លាស់ទេ។

**ឆ៖** លោកថាអ៊ីចឹងក៏ថាបាន ព្រោះសម័យនោះមកដល់បច្ចុប្បន្នមិនមែនច្បាស់ដូចថ្មីៗនេះឯណា ជំនាន់ពីក្មេងមកដល់សម័យនេះអាយុជិតទៅវិញទៅហើយ។ បានន័យថាការចងចាំក៏វាមានអន់ថយទៅដែរ។

[១៥:២៦:០៩]

**ស៖** បាទ ដូច្នេះបន្តពីអ្វីដែលលោកស្រីបានឆ្លើយហ្នឹងគឺថា ប្រហែលជាលោកស្រីអាចចាំកាលប្រវត្តិហ្នឹង ៤ឆ្នាំមុននឹងលោកស្រីចាំច្បាស់ជាងឥឡូវហ្នឹងអ៊ីចឹងមែនទេ? ខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** អារឿងកន្លងហួសទៅហើយវាមិនអាចចាំដូចថ្មីៗទេចាស។ កាលណាយើងសរសេរហើយអានដាក់ទុកចុះក៏អាចភ្លេចបានដែរ ចំណាស់នេះទៅហើយអាចភ្លេចមុខភ្លេចក្រោយហើយចាស។

**ស៖** អ៊ីចឹងបានន័យថា យើងយល់ស្របគ្នាហើយឬក៏យ៉ាងម៉េច?

**ឆ៖** យល់ស្របយ៉ាងម៉េចទៅ?

**ស៖** ឥឡូវអ៊ីចឹងយើងយល់ស្របនឹងគ្នាថាលោកស្រីហ្នឹងកាលពីឆ្នាំ២០០៨ លោកស្រីនៅចាំរឿងរ៉ាវដែលកើតឡើងសម័យខ្មែរក្រហមច្បាស់ជាងឥឡូវនេះ។ អ៊ីចឹងមែនទេ?

**ឆ៖** កាលនោះវានៅច្បាស់តែឥឡូវវាមិនទាន់ច្បាស់ទេ វាអាចចង់ភ្លេចភ្លាំងអស់ទៅហើយ។ អាយុវាកាន់តែច្រើនហើយចូល ៦០ ស្អែកៗទៅហើយចាំស្អីទៀត មើលអក្សរមិនច្បាស់ផង។

**លោក អាកឡូរ វែកកែន៖**

បាទ លោកស្រីខ្ញុំសូមអរគុណលោកស្រី។

លោកប្រធានខ្ញុំសួរចប់ហើយ។ សូមអរគុណលោកប្រធាន។

[១៥:២៨:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន។ ដោយហេតុថាបញ្ហាទាំងខ្ញុំ ទាំងលោក កូប៉េ ដែលបញ្ជាក់ពីឈ្មោះ កុយ ធួន និង កុយ ឃួន ពីដើមនៃសក្ខីកម្មនេះ ខ្ញុំសូមអនុញ្ញាតជម្រាបដើម្បីកត់កំណត់ត្រាតុលាការហ្នឹង គឺចម្លើយសារភាពរបស់ កុយ ធួន គឺ 5.-- ហើយមានឈ្មោះគឺឯកសារ D5.39។ នៅទីនោះមានដាក់ឈ្មោះ ថាជាចម្លើយសារភាពរបស់ កុយ ឃួន ឬក៏ហៅ កុយ ធួន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកស្រី ឯក ហេន ការស្តាប់សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រីដែលបានលះបង់ពេលវេលាដ៏មានតម្លៃ អញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល១ថ្ងៃកន្លងមកនេះ ដោយភាពអត់ធ្មត់ ខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយសូមជូនពរលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ ហើយបានសេចក្តីសុខសេចក្តីចម្រើន។ ហើយវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រីត្រឡប់ទៅកាន់ទីកន្លែងគោលដៅដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។

ហើយជាបន្តទៅនេះអង្គជំនុំជម្រះបន្តសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-689។

លោកស្រីអាចចាកចេញទៅបានហើយ សូមអញ្ជើញលោកស្រី ឯក ហេន!

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីបម្រុងចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:៣២:១១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំបាទឈ្មោះ ស៊ុម អាឡាត់។

**ស៖** អរគុណលោក ស៊ុម អាឡាត។ តើលោកមានអាយុប៉ុន្មាន?

**ឆ៖** មកដល់ឆ្នាំនេះ ខ្ញុំអាយុ៦០ឆ្នាំ។

**ស៖** អរគុណលោក អាឡាត់ ហើយសព្វថ្ងៃនេះតើលោកមានទីកន្លែង ទីលំនៅ នៅទីកន្លែងណា?

**ឆ៖** ទីលំនៅសព្វថ្ងៃខ្ញុំបាទ នៅភូមិកញ្ជើបាយដាច ឃុំវាល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

**ស៖** អរគុណ។ ហើយតើលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ? ហើយឪពុករបស់លោកគាត់ឈ្មោះអី? ហើយម្ដាយរបស់លោកគាត់ឈ្មោះអី?

**ឆ៖** បាទ ខ្ញុំបាទធ្វើការនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ប៉ុន្តែបច្ចុប្បនេះខ្ញុំបាទចូលនិវត្តន៍ហើយ។ ឪពុកឈ្មោះ សុង ស៊ុម (ស្លាប់)។ ម្ដាយឈ្មោះ ស្លឹង អឿង (ស្លាប់) បាទ។

**ស៖** អរគុណ ហើយចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ លី គន្ធា បាទ។ ខ្ញុំមានកូនប្រាំពីរនាក់។

[១៥:៣៣:៥៧]

**ស៖** អរគុណលោក អាឡាត់។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដី០០២នេះទេ។ ហើយក៏មិនជាប់ញាតិលោកហិតជាមួយជនជាប់ចោទ -- ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបដែរ គឺលោក នួន ជា និងលោក ខៀវ សំផន ហើយថាលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយនៅព្រឹកមិញនេះ។ តើជាការពិតដែរឬទេ?

**ឆ៖** នេះជាការពិតបាទ។

**ស៖** បាទ អរគុណ។ ហើយជាបន្តទៅនេះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចចំពោះលោកក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោកអាឡាត់ នៅក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកមានសិទ្ធិអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយទន្ទឹមនឹងនេះលោកមានករណីយកិច្ចត្រូវតែឆ្លើយ

តបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក លើកលែងតែក្នុងករណីដែលឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយម្យ៉ាងទៀតគឺលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិការណ៍ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

[១៥:៣៥:៥២]

លោក អាឡាត់ តើលោកមានដែលធ្លាប់ផ្តល់សក្ខីកម្ម ឬក៏កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ?

**ឆ៖** លើបញ្ហានេះ គឺមានគេចុះទៅស៊ើបអង្កេតនៅទៅដល់ខេត្ត។ ខ្ញុំបានឲ្យជាព័ត៌មានដូចនៅក្នុងព័ត៌មានដែលបានជូនមកនេះបាទ។

**ស៖** លោកចាំទេ ថាលោកបានធ្វើផ្តល់កិច្ចសម្ភាសន៍ហ្នឹងជាមួយអ្នកស៊ើបអង្កេតហ្នឹងប៉ុន្មានដង? ហើយលោកធ្វើនៅទីកន្លែងណា? ហើយនៅពេលណាដែរ?

**ឆ៖** គឺធ្វើនៅក្នុងឆ្នាំ២០០៨ ក្នុងការិយាល័យនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់។

**ស៖** អរគុណលោក ស៊ុម អាឡាត់។ មុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យ ឬក៏បានអាន ឬក៏បានស្តាប់ការអានពីអ្នកណាម្នាក់នូវកំណត់ហេតុដែលលោកបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលលោកអះអាងថាធ្វើនៅមន្ទីរវប្បធម៌ វិចិត្រសិល្បៈខេត្តកាលពីឆ្នាំ២០០៨ ដើម្បីរំឭកការចងចាំដែរឬទេ?

[១៥:៣៧:២៧]

**ឆ៖** មុននឹងបានចូលមកដល់នៅទីនេះ ខ្ញុំបានអាន ខ្ញុំបានទទួលការណែនាំពីមេធាវី ហើយបានបញ្ជាក់ពីឯកសាររំឭកឡើងវិញហើយ។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងអាចចងចាំ តើលោកអាចបញ្ជាក់បានដែលទេថា កំណត់ហេតុដែលកត់ត្រានូវកិច្ចសម្ភាសន៍ដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះគឺពិតជាត្រឹមត្រូវ និងស៊ីសង្វាក់ស្របគ្នាទៅនឹងចម្លើយរបស់លោកដែលបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៨ នោះដែរឬទេ?

**ឆ៖** បាទ ប្រការទាំងអស់នេះជាការត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោក ស៊ុម អាឡាត់ សូមលោកទុកបញ្ហានេះម្ដុំ ហើយលោកចាំស្ដាប់នូវសំណួរដែលភាគីនឹងសួរចំពោះលោក។ លើកលែងតែក្នុងករណីមួយចំនួន ដែលមានការចង្អុលបង្ហាញ សូមលោកពិនិត្យឯកសារដែលមានការពាក់ព័ន្ធ។

ហើយនៅក្នុងការស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវី ហើយនិងភាគីទាំងអស់ ហើយសូមជម្រាបសួរលោកសាក្សី ស៊ុម អាឡាត់ ផងដែរ។ ខ្ញុំឈ្មោះ វីល្លៀម ស្មីត ហើយខ្ញុំយើងខ្ញុំមានពីរនាក់ មានលោក វេង ហ៊ាត់ ផងដែរ ហើយដើម្បីយើងខ្ញុំសួរ ដើម្បីទាញយករកឲ្យឃើញការពិតដែលកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនៅក្នុងខេត្តពោធិ៍សាត់។ យើងសង្ឃឹមថាលោកអាចនឹងជួយបំភ្លឺយើងខ្ញុំបាន ជូនតុលាការ។

[១៥:៣៩:៣១]

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ល្ងាចនេះ ខ្ញុំនឹងសួរលោកសំណួរបឋមមួយចំនួនទាក់ទងទៅនឹងសមាជិកក្រុមគ្រួសាររបស់លោក ប្រវត្តិអាជីពការងាររបស់លោក ហើយនិងសួរផងដែរអំពីថាលោកបានធ្វើអ្វីមុនឆ្នាំ១៩៧៥? លោកមានតួនាទីអ្វីខ្លះនៅក្នុងពេលមានសង្គ្រាមរវាង លន់ នល់ ហើយនិងកងកម្លាំងបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យ? ហើយថ្ងៃស្អែក ហើយថ្ងៃស្អែកយើងនឹងបន្តពិភាក្សាអំពីបញ្ហាមួយចំនួនដែលលោកបានបញ្ជាក់នៅក្នុងកំណត់ហេតុទាក់ទងទៅនឹងការចុះចាញ់ ការលើកទង់ជ័យសរបស់ទាហាន លន់ នល់ ដែលគេប្រមូលផ្ដុំ។ ហើយទាក់ទងនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ ហើយនិងបញ្ហាពាក់ព័ន្ធនឹងអង្គហេតុនោះ។ លោកបាននិយាយថាលោកមានកូនប្រាំពីរនាក់។ សូមលោកប្រាប់តុលាការថា តើកូនទាំងនោះប៉ុន្មាននាក់បានកើតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ រហូតមកដល់ឆ្នាំ១៩៧៩?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** កូនប្រាំពីរនាក់ កូនច្បងបានកើត -- មិនកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែ

ចូលមកដល់វៀតណាម -- ចូលមកដល់រំដោះហើយទើបកើត អ៊ីចឹងទេទម្ងន់តាំងពីនៅរបបកម្ពុជាប្រជាធិបតេយ្យ។ ផុតពីហ្នឹងគឺកូនប្រាំមួយនាក់ទៀតកើតនៅក្នុងសម័យឥឡូវនេះ។

[១៥:៤១:២៣]

**សៈ** សូមអរគុណ។ លោកបានបញ្ជាក់ថា ឪពុកម្តាយរបស់លោកបានស្លាប់ តើពួកគាត់ស្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏គាត់ស្លាប់ក្រោយពីសម័យហ្នឹង គឺក្រោយឆ្នាំ១៩៧៩?

**ឆៈ** ក្រុមគ្រួសារខ្ញុំបាទ ឪពុកស្លាប់តាំងពីនៅកុមារភាព គាត់អាយុបាន ៤៥ឆ្នាំ អង្កាល់នោះខ្ញុំនៅអាយុ ៩ឆ្នាំនៅឡើយទេ។ ម្តាយខ្ញុំគាត់មកទទួលមរណភាពនៅក្នុងសម័យយើងឥឡូវនេះ ក្រោយរំដោះនេះបាទ។

**សៈ** សូមអរគុណ។ លោកក៏បានបញ្ជាក់ផងដែរថា លោកមានការងារជាអនុប្រធានទី១ នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់។ តើលោកនិវត្តន៍បានន័យថា ចូលរ៉ឺត្រេតពីការងារនេះ ពីពេលណាដែរ?

**ឆៈ** ខ្ញុំបាទបានចូលនិវត្តន៍លើការងារធ្វើការនៅមន្ទីរវប្បធម៌វិចិត្រសិល្បៈខេត្តពោធិ៍សាត់រយៈពេលបាន១ឆ្នាំហើយ។

**សៈ** តាមចម្លើយរបស់លោក ហើយលោកកាន់តំណែងនោះតាំងពីឆ្នាំ១៩៨៦មក។ តើត្រឹមត្រូវដែរឬទេ?

[១៥:៤២:៥៣]

**ឆៈ** កាន់តំណែងនៃមន្ទីរវប្បធម៌វិចិត្រសិល្បៈខេត្ត គឺឆ្នាំ១៩៨៦។

**សៈ** ដូច្នេះ លោកធ្វើការងារនោះក្នុងរយៈពេលវែង គឺថា២៧ឆ្នាំ។ តើលោកអាចជម្រាបតុលាការបានទេ តើលក្ខណៈការងារដូចម្តេច ហើយនិងគោលបំណងនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈហ្នឹងដូចម្តេចដែរ ដើម្បីជាតួនាទីរបស់លោក ដើម្បីបំពេញការងារនោះ?

**ឆៈ** នៅមុនឆ្នាំ១៩៧៩ ខ្ញុំចូលជា -- ធ្វើការនៅក្រសួងអប់រំ មន្ទីរអប់រំខេត្ត ប៉ុន្តែនៅឆ្នាំ១៩៨៦ ខ្ញុំបានផ្លាស់ភារកិច្ចមកកាន់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់ ក្នុងនាមខ្ញុំជាអនុប្រធានមន្ទីរ ទទួលបច្ចេកទេសរួមលើការងារសិល្បៈ និងលើការងារភាពយន្ត ផ្សព្វផ្សាយ អ្វីដែលទាក់ទងនឹងតន្ត្រីយារម្មណ៍ទាំងប៉ុន្មានទៅលើស្មារតីមនុស្ស តាមជំនាញរបស់វិចិត្រសិល្បៈ។

[១៥:៤៤:២៣]

**សៈ** តើមន្ទីរនោះមានតួនាទីអ្វីទាក់ទងទៅនឹងការអភិរក្សប្រវត្តិសាស្ត្រកម្ពុជាដែរទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏ពេលណាមួយដែរឬទេ?

**ឆៈ** តួនាទីសំខាន់នៃស្ថាប័នវប្បធម៌ មានតួនាទីសំខាន់ការពារអ្វីៗទាំងអស់ដែលជាមរតកវប្បធម៌ជាតិ។

**សៈ** សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយនៅក្នុងចម្លើយទៅអ្នកស៊ើបអង្កេតរបស់តុលាការនេះ។ ខ្ញុំយោងទៅរកនៅចម្លើយដូចខាងក្រោម E00242128 ជាអង់គ្លេស, ខ្មែរ 00196814, បារាំង 00274134។ នៅក្នុងចម្លើយនោះគឺថាផ្នែកមួយដែលលោកនិយាយយោងទៅដល់តួនាទីរបស់លោកក្នុងការប្រមូលភស្តុតាងពីបទឧក្រិដ្ឋដែលបានកើតឡើងនៅក្នុងខេត្តពោធិ៍សាត់ តំបន់ពោធិ៍សាត់។ ខ្ញុំសូមដកស្រង់ "គេបានសួរ៖ បន្ទាប់ពីឆ្នាំ១៩៧៩ តើលោកធ្វើអ្វីទាក់ទិននឹងមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស? លោកបានឆ្លើយថា៖ នៅដើមឆ្នាំ១៩៨០ ខ្ញុំបានចូលរួមសន្និបាតអប់រំនៅភ្នំពេញ។ នៅក្នុងនោះគេបានឲ្យតំណាងខេត្តនីមួយៗ មានប្រាំនាក់ឡើងនិយាយប្រាប់អំពីរបៀបរៀបចំប្រមូលភស្តុតាងក្នុងសម័យខ្មែរក្រហម ដែលបានកាប់សម្លាប់មនុស្សយ៉ាងរង្គាល និងការសម្លាប់ដោយរបៀបប្រយោល។ ការប្រមែប្រមូលពាក្យសម្ដី និងរឿងរ៉ាវនេះគឺសរសេរចងក្រងធ្វើជាភស្តុតាង និងសម្រាប់ផ្សព្វផ្សាយអប់រំ។ ឯកសារទាំងនោះគេបានតម្កល់ទុកនៅទួលស្លែង និងក្រសួងអប់រំ។ ហើយខ្ញុំមិនមានឯកសារទាំងនេះជាមួយខ្ញុំទេបច្ចុប្បន្ននេះ"។ នេះជាចម្លើយដែលលោកបានប្រាប់ទៅអ្នកស៊ើបអង្កេតរបស់សាលាក្តី។ សួរលោកថា តើលោកបានស្ម័គ្រចិត្តចូលរួមការវគ្គសិក្សាអប់រំនៅភ្នំពេញកាលណោះទេ ឬក៏គេជ្រើសរើសឲ្យលោកអញ្ជើញមក?

[១៥:៤៧:០៩]

**ឆៈ** បាទសូមស្រាយបំភ្លឺ បញ្ហាដែលយើងធ្វើការនៅមន្ទីរអប់រំនេះ ជាបឋមនៅក្នុងខេត្តពោធិ៍-សាត់ទាំងមូល ក្រោយពេលដែលយើងបានរំដោះថ្ងៃ០៧ មករា ស្ថាប័នអប់រំ ក៏ដូចស្ថាប័នផ្សេងៗទាំងអស់ត្រូវការរៀបចំសាថ្មី។ តំណាងឲ្យខេត្តពោធិ៍សាត់គឺយើងខ្ញុំប្រាំនាក់ ជាសក្ខីកម្ម គឺជាក្បាលម៉ាស៊ីនសម្រាប់អប់រំ។ ដូច្នេះគេត្រូវចាត់តាំងឲ្យយើងទៅចូលរួមវគ្គបណ្ដុះបណ្ដាល និងវិក្រិតការនៅក្នុងសាលាជាតិ គឺថានៅខាងអប់រំជាតិ។ ដូច្នេះ ក្នុងវគ្គសិក្សានោះ គេបានចងក្រងជាឯកសារ។ ដូច្នេះតំណាងឲ្យខេត្តពោធិ៍សាត់មានប្រាំនាក់ គឺរូបខ្ញុំមានមួយផងដែរ បានជាសាក្សី ក៏ជាអ្នកបំភ្លឺក្នុងឯកសារនេះបាទនៅខេត្តពោធិ៍សាត់ ដូចមានបានការអះអាងដែលលោកបានបញ្ជាក់នេះមែន។

**សៈ** ដើម្បីឲ្យច្បាស់ តើការធ្វើសន្និបាតនោះ គឺនិយាយការពីការបង្ហាញអំពីភស្តុតាងបទឧក្រិដ្ឋនៃការសម្លាប់រង្គាល ឧក្រិដ្ឋកម្ម តើមានការពិភាក្សា ឬក៏ការកំណត់ថាតើត្រូវប្រមូលភស្តុតាងបែបណា ឬក៏និយាយម្យ៉ាងទៀតថា តើលោកបានប្រមូលភស្តុតាងរួចហើយ ឬក៏ដើម្បីមកបង្ហាញ ឬក៏ត្រូវប្រមូលភស្តុតាងហ្នឹងក្រោយពីសន្និបាតចប់?

[១៥:៤៨:៤៦]

**ឆៈ** ក្រោយសន្និបាតគឺយើងបានធ្វើស្រាយបំភ្លឺ អំពីចំនួនៗ នៃអ្នកដែលត្រូវគេសម្លាប់នៅក្នុងទឹកដីខេត្តពោធិ៍សាត់ និងទីកន្លែង។

**សៈ** សូមអរគុណ។ លោកបាននិយាយថាសន្និបាតនេះបានកើតឡើងនៅដើមឆ្នាំ១៩៨០ ប្រហែលជា១ឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ។ តើលោកធ្វើការងារអ្វីខ្លះក្នុងការប្រមូលភស្តុតាង និងព័ត៌មានអំពីអ្វីដែលកើតឡើងនៅពោធិ៍សាត់នៅក្នុងឆ្នាំនោះ? សូមលោកជម្រាបតុលាការថាតើការចូលរួមរបស់លោកហ្នឹង គឺការងារធ្វើអ្វីខ្លះក្នុងការប្រមូលភស្តុតាង ឬក៏ថាគេយកភស្តុតាងទាំងអស់ហ្នឹងមកឲ្យលោកដើម្បីឲ្យលោករៀបចំទុកដាក់ ឬក៏ធ្វើការផ្សព្វផ្សាយយ៉ាងម៉េច?

**ឆៈ** នៅក្នុងអង្គសន្និបាតទាំងមូលនោះ គឺគ្រប់ខេត្តទាំងអស់ ក្នុងនោះមានភាគីគ្រប់ខេត្តដែលត្រូវឡើងធ្វើការធានាអះអាងពីបញ្ហាការសម្លាប់រង្គាលនោះ ដោយយើងផ្ដល់ជាព័ត៌មាន។ ហើយស្ថាប័នអប់រំហ្នឹងឯង គឺជាអ្នកចងក្រងឯកសារ ចេញជាសៀវភៅមួយគឺក្នុងឆ្នាំ១៩៨០, ៨១។ គឺមានចេញហើយដំបូងអើយបំផុតអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ សៀវភៅហ្នឹង។ ក្នុងនោះគឺ មានឈ្មោះខ្ញុំហ្នឹងឯង។ ប្រាំនាក់គឺមាននៅក្នុងនោះដែរ។

**សៈ** តើរូបលោកផ្ទាល់លោកបានពាក់ព័ន្ធនៅក្នុងការប្រមូលព័ត៌មានទាំងនោះទេ មុនពេលសន្និ-បាតដែលថា ឬក៏អ្នកផ្សេងទៀតប្រគល់មកឲ្យលោកនូវភស្តុតាងទាំងនោះ?

**ឆៈ** នៅក្នុងសន្និបាត គឺភាគីយើងតំណាងឲ្យខេត្តនីមួយៗដែលបានដឹង បានឮ ឃើញជាក់ស្ដែងនឹងភ្នែកប្រគល់ព័ត៌មាននោះ ផ្ដល់ព័ត៌មាននោះទៅក្នុងវគ្គបណ្ដុះបណ្ដាលនោះឯង នៅក្នុងសន្និបាតនោះឯង។

[១៥:៥១:២៣]

**សៈ** តើលោកត្រូវប្រើពេលប៉ុន្មានដើម្បីប្រមូលភស្តុតាងនៅក្នុងខេត្តពោធិ៍សាត់ដែលជាតំបន់របស់លោកធ្វើការនោះ?

**ឆ៖** ក្នុងអង្គសន្និបាតគឺយើងបានប្រើពេលវេលាយ៉ាងយូររយៈពេល១ថ្ងៃ ដែលពិភាក្សាគ្នាប្រាំនាក់តំណាងឲ្យខេត្តនោះឯង។ ម្នាក់ៗដឹងរឿង ព្រោះអីតំណាងខេត្តពោធិ៍សាត់ដែលទៅប្រាំនាក់នេះគឺថានៅដោយឡែកៗគ្នាតាមស្រុក ដូច្នេះយើងយកព័ត៌មានតាមដឹងហ្នឹងបញ្ចូលនៅក្នុងធ្វើជាទិន្នន័យសម្រាប់ចងក្រងជាសៀវភៅនេះឯង។

**ស៖** តើលោកយល់ស្របជាមួយតំណាងផ្សេងៗទៀតទេមុនពេលសន្និបាតនោះ ដែលថាលោកត្រូវប្រមូលព័ត៌មានទាំងអស់នោះនៅក្នុងខេត្តរបស់លោក?

**ឆ៖** យើងបានពិភាក្សាគ្នា ហើយក៏បានឯកភាពទៅលើព័ត៌មានទាំងអស់នោះ។

**ស៖** ខ្ញុំនឹងបញ្ចប់ប្រធានបទនេះនៅពេលនេះ។ សួរថាតើលោកខ្លួនឯងទទួលបានព័ត៌មាននោះដោយវិធីណាមកពីស្រុកដែលលោកទទួលខុសត្រូវ? តើលោកទទួលព័ត៌មានដោយរបៀបណាតាមរយៈពិភាក្សាជាមួយអ្នកផ្សេងតាមរយៈសម្ភាស ថាតើលោកប្រមូលព័ត៌មានដោយវិធីណា?

[១៥:៥៣:៣០]

**ឆ៖** ការប្រមូលព័ត៌មាន ដោយទី១ ពិភាក្សាទៅលើការផ្តល់ព័ត៌មានពីភាគីទាំងប្រាំ។ ទី២ ផ្តល់ទៅឃើញការជាក់ស្តែងដែលយើងបានឃើញផ្ទាល់ភ្នែក។ នេះយកទាំងពីរនេះមកពិភាក្សាគ្នា យកជាការពិតបាន។

**ស៖** សូមអរគុណ។ ដើម្បីឲ្យយើងច្បាស់គឺថាលោកបាននិយាយពីឈ្មោះស្រុកមួយចំនួននៅក្នុងចម្លើយដែលលោកបានឆ្លើយពាក់ព័ន្ធនឹងខេត្តពោធិ៍សាត់។ សូមលោកជួយពន្យល់តុលាការ ហើយរំឭកដល់យើងខ្ញុំ ថាតើស្រុកហ្នឹងមានប៉ុន្មាន ហើយមានឈ្មោះអ្វីខ្លះ? មានស្រុកប៉ុន្មាននៅក្នុងខេត្តពោធិ៍សាត់?

**ឆ៖** នៅដើមឆ្នាំ១៩៧៩។ ខេត្តពោធិ៍សាត់មានស្រុកកណ្តៀង ស្រុកបាកាន ស្រុកក្រគរ ស្រុកភ្នំក្រវាញ និងទីរួមខេត្ត តែប្រាំស្រុកទេ។ហ្នឹងក្នុងឆ្នាំ១៩៧៩។ តែក្រោយមកទៀតបានបង្កើតថ្មីគឺស្រុកវាលវែង។

**ស៖** សូមអរគុណ។ តើត្រូវទេ បើក្នុងការនិយាយថាលោកបានរស់នៅក្នុងខេត្តពោធិ៍សាត់តាំងពីលោកកើតមករហូតដល់អាយុប៉ុណ្ណេះមកដល់ពេលនេះ?

**ឆ៖** តាមការពិត គឺខ្ញុំកើតនៅពោធិ៍សាត់តែម្តង ពុំបានកើតនៅឯងណាទេ គឺស្រុកកំណើតនៅខេត្តពោធិ៍សាត់រហូតតូចមកទល់អាយុ ៦០ឆ្នាំនេះ។

[១៥:៥៥:៣១]

**ស៖** តើលោកស្គាល់ភូមិសាស្ត្រទីក្រុង ហើយនិងភូមិ ហើយនិងទីតាំងដែលជាសញ្ញាសម្គាល់សំខាន់ៗរបស់ខេត្តនោះដែរឬទេ?

**ឆ៖** សញ្ញាសំខាន់ៗរបស់ខេត្ត យើងភាគីច្រើន គឺស្គាល់ច្រើន។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយអំពីប្រធានបទនេះ ហេតុអ្វីជាគេជ្រើសរើសលោកឲ្យធ្វើជាតំណាងនៅខេត្តពោធិ៍សាត់នៅក្នុងសន្និបាតមួយ ដែលលោកថាត្រូវអញ្ជើញមកប្រជុំនោះ?

**ឆ៖** សូមទោស សូមសួរម្តងទៀត។

**ស៖** លោកបានបញ្ជាក់ថា មានតំណាងប្រាំរូបមកពីខេត្តនីមួយៗ ដើម្បីផ្តល់ព័ត៌មាននៅអំពីការសម្លាប់រង្គាលនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ សួរលោកថា ហេតុអីបានជាគេជ្រើសរើសលោកជាតំណាងឲ្យខេត្តពោធិ៍សាត់ដើម្បីធ្វើការងារនោះ?

[១៥:៥៦:៥៦]

**ឆ៖** ចំពោះបញ្ហានេះ គឺផ្នែកខាងអប់រំវគ្គបណ្តុះបណ្តាលនេះ គេបានធ្វើសន្និបាតគ្រប់តំណាងខេត្តហ្នឹង គឺជំនាន់ទី១ ហ្នឹងគឺបើកវគ្គដំបូងបំផុតហ្នឹង គឺផ្លូវគមនាគមន៍យើងមិនអាចទៅមកបានទេ មានការលំបាក។ ដូច្នេះអ្វីដែលប្រាំនាក់បញ្ជូនមកដល់ភ្នំពេញហើយ គេយកតំណាងប្រាំនាក់ជាបញ្ញវន្ត។ គ្រូនេះឯងមកធ្វើជាសន្និបាត បង្ហាញបញ្ជាក់ជូនអំពីឧក្រិដ្ឋកម្មនេះឯងបាទ។ អ៊ីចឹងហើយបានថាក្នុងប្រាំនាក់នេះ ដូចជាសក្ខីបណ្ណ ឬក៏ជាសាក្សីបំភ្លឺនៅក្នុងការប្រជុំនោះឯង។

**ស៖** ដើម្បីបញ្ចប់ផ្នែកនេះ លោកនិយាយថា លោកបង្រៀន និងអប់រំដល់ប្រជាជន។ សូមលោកជម្រាបតុលាការអំពីការ និយាយពីការអប់រំរបស់លោក លោកទៅសិក្សានៅឧត្តមសិក្សា ឬក៏អ្វីទៀតក្រោយពីឧត្តមសិក្សាហ្នឹងដែរឬទេ?

**ឆ៖** នៅពេលចេញពីគ្រូ នៅអប់រំ, ចេញពីអប់រំ ខ្ញុំបានធ្លាប់ទៅបំពេញខាងវិស័យវប្បធម៌វិចិត្រសិល្បៈនៅសហភាពសូវៀតចំនួនជាង១ខែ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំបានបញ្ចប់ប្រធានបទនេះហើយ ខ្ញុំនឹងនិយាយអំពីតួនាទីក្នុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប៉ុន្តែខ្ញុំចង់ជម្រាបថា អាចនឹងប្រើពេលវេលាវែង។ អ៊ីចឹងគួរអនុញ្ញាតឲ្យខ្ញុំបន្តពេល ឬក៏ពេលនេះ ឬក៏លោកប្រធានពិចារណាដូចម្តេចបាទ។

[១៥:៥៩:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ ហើយតែមុននឹងសម្រាកអង្គជំនុំជម្រះសូមចង់បានព័ត៌មានមួយចំនួនដើម្បីរៀបចំនៅកាលវិភាគសវនាការឲ្យបានសមស្របនៅក្នុងសប្ដាហ៍ក្រោយ។ ដូច្នេះ អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ថាតើក្រុមមេធាវីការពារក្ដី ខៀវ សំផន ហ្នឹងនឹងប្រើប្រាស់ពេលវេលាកន្លះថ្ងៃដែលអង្គជំនុំជម្រះបែងចែកឲ្យសម្រាប់ការធ្វើអត្ថាធិប្បាយ ឬក៏កត់សម្គាល់តបទៅនឹងបណ្ដាឯកសារគន្លឹះ ដែលបានដាក់ដោយភាគី សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកន្លងមកដែរឬទេនៅសប្ដាហ៍ក្រោយនេះ? ក្រុមមេធាវីការពារក្ដី ខៀវ សំផន បាទ។

**លោក អាកខូវ វែកគែន៖**

បាទ លោកប្រធានខ្ញុំត្រូវពិភាក្សាជាមួយក្រុមខ្ញុំសិន ដើម្បីឲ្យយើងអាចដឹង។ ខ្ញុំប្រហែលជាអាចជូនដំណឹងដល់អង្គជំនុំជម្រះនៅស្អែកលោកប្រធាន ពេលនេះគឺមិនទាន់បានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសូមផ្ដល់ព័ត៌មានឲ្យបានឆាប់នៅពេលព្រឹក ដោយសារមូលហេតុអង្គជំនុំជម្រះត្រូវរៀបចំកាលវិភាគសម្រាប់សប្ដាហ៍ក្រោយហ្នឹងឲ្យមានប្រសិទ្ធភាព ហើយនិងប្រើប្រាស់ពេលវេលាទាំងឡាយហ្នឹងឲ្យមានប្រសិទ្ធភាព។ អានេះគឺដូច្នេះទេបាទ។

[១៦:០០:៤៧]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៤ ខែកក្កដា ឆ្នាំ២០១៣។ ហើយនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ស៊ុម អាឡាត់ ដែលនឹងសួរដេញដោលដោយភាគីពាក់ព័ន្ធនៃរឿងក្ដី។ ហើយសូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះសាលាដំបូង ហើយនិងសាធារណជនជ្រាប។

លោក ស៊ុម អាឡាត់ ការស្ដាប់សក្ខីកម្មរបស់លោកមិនចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមកោះអញ្ជើញមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នក

ជំនាញក្នុងការជូនលោក ស៊ុម អាឡាត់ ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះ ក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។ ហើយសូមអញ្ជើញលោកមេធាវី ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សីមកចូលរួមនៅក្នុងសវនាការដូចគ្នានឹងសាក្សីរូបនេះដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ដែលឃុំខ្លួនមួយនៅខាងក្រោមសាលសវនាការនេះ ដែលរៀបចំនូវឧបករណ៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*